# ព្រឹត្តិបត្រមេធាវី
# លេខ ២០
# ខែ មករា-មីនា ឆ្នាំ ២០១៩

រក្សាសិទ្ធិ © 2019 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសម្តែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនបញ្ជាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល" ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

# មាតិកា

ទំព័រ

**សារពីប្រធានគណៈមេធាវី** ..... IV

**ច្បាប់ភូមិបាល**

**ការវិវត្តច្បាប់ស្តីពី ការលក់ដីធ្លីនៅកម្ពុជា** ..... 1

ជំពូកទី១៖ ការវិវត្តស្តីពីការលក់ដីធ្លីពីឆ្នាំ១៩៨៩ ដល់ឆ្នាំ២០០១ ..... 2

១. ការទិញលក់ដីធ្លីក្នុង ឆ្នាំ១៩៨៩ ដល់ឆ្នាំ២០០១ ..... 2

២. ការវិវត្តស្តីពីការលក់ដីធ្លីពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣ ..... 4

៣. ការវិវត្តស្តីពីការលក់ដីធ្លីពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០១ ..... 7

ជំពូកទី២៖ ការវិវត្តច្បាប់ស្តីពីការលក់ដីធ្លីពីឆ្នាំ២០០១ រហូតដល់បច្ចុប្បន្ន ..... 9

១. ការវិវត្តស្តីពីការលក់ដីធ្លីពីឆ្នាំ២០០១ ដល់២០១០ ..... 9

២.ការវិវត្តក្រោយពីក្រមរដ្ឋប្បវេណីចូលជាធរមានរហូតដល់បច្ចុប្បន្ន ..... 11

**អគារសហកម្មសិទ្ធិ** ..... 15

ជំពូកទី ១ ទម្រង់ទូទៅនៃកម្មសិទ្ធិ និង អគារសហកម្មសិទ្ធិ ..... 15

១.១ ទម្រង់ទូទៅនៃកម្មសិទ្ធិ ..... 15

១.២.អគារសហកម្មសិទ្ធិ ..... 23

ជំពូកទី២៖ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ ..... 26

២.១. សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរ ..... 26

២.២. សហកម្មសិទ្ធិករជាជនបរទេស ..... 30

សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ..... 35

**នីតិវិធីជំនុំជម្រះក្តីលើកទី១** ..... 39

ជំពូកទី ១: ការដាក់ពាក្យបណ្តឹង ..... 39

១.១ របៀបដាក់ពាក្យបណ្តឹង ..... 39

១.២ ការទទួលពាក្យបណ្តឹង ........................................................ 45

១.៣ ការបែងចែករឿងក្តី ........................................................ 48

១.៤ ការពិនិត្យពាក្យបណ្តឹង ........................................................ 49

ជំពូកទី២ ដំណើរការនៃនីតិវិធីជំនុំជម្រះក្នុងរឿងក្តីរដ្ឋប្បវេណី ........................................................ 50

២.១នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................................ 50

២.២ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង ........................................................ 60

ជំពូកទី៣ ការសះជាតាមផ្លូវបណ្តឹង ........................................................ 65

៣.១ អត្ថន័យនៃការសះជាតាមផ្លូវបណ្តឹង ........................................................ 65

៣.២ ផលប្រយោជន៍នៃការសះជាតាមផ្លូវបណ្តឹង ........................................................ 65

៣.៣ ការសាកល្បងផ្សះផ្សា ........................................................ 66

៣.៤ ការផ្សះផ្សាក្រៅតុលាការ ........................................................ 67

៣.៥ អានុភាព និងកំណត់ហេតុនៃការសះជា ........................................................ 67

ជំពូកទី៤ ការសម្រេចសេចក្តីជាសាលក្រម ........................................................ 68

៤.១សាលក្រមចំពោះមុខ ........................................................ 68

៤.២សាលក្រមកំបាំងមុខ ........................................................ 70

## សកម្មភាពគណៈមេធាវីប្រចាំ ត្រីមាសទី១ ឆ្នាំ២០១៩

**១.ទំនាក់ទំនងជាតិ និងអន្តរជាតិ** ........................................................ 81

១.១.ទំនាក់ទំនងជាតិ ........................................................ 81

១.២.ទំនាក់ទំនងអន្តរជាតិ ........................................................ 89

**២.ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា** ........................................................ 99

**៣.កិច្ចប្រជុំបុគ្គលិក** ........................................................ 105

**៤.កិច្ចប្រជុំគណៈកម្មការជំនាញ** ........................................................ 106

**៥.ផ្សេងៗ** ........................................................ 107

# សារពីប្រធានគណៈមេធាវី




គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ២០ សម្រាប់ត្រីមាសទី១ ខែមករា-មីនា ឆ្នាំ២០១៩។ ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធ នីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធ ដែលបានរួមចំណែកវិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធានបុគ្គលិក និងអ្នកស្ម័គ្រចិត្តនៃនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានា ដូចជា ភូមិបាល អគារសហកម្មសិទ្ធិ និងនីតិវិធីនៃការជម្រះក្តីលើកទី១នៃរឿងក្តីរដ្ឋប្បវេណី។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើរការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ "ពង្រឹង និងការពារវិជ្ជាជីវៈ" នៃផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្ត

ដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយ ដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាគា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **ភុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាគា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃសុក្រ ៩រោច ខែផល្គុន ឆ្នាំ ច សំរឹទ្ធស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

**សួន វិសាល**
ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# ច្បាប់ភូមិបាល

# ការវិវត្តច្បាប់ស្ដីពី ការលក់ដីធ្លីនៅកម្ពុជា

ដោយលោក ខន សុខេង*

## សេចក្ដីផ្ដើម

របបដីបានផ្លាស់ប្ដូរយ៉ាងគំហុកពីឆ្នាំ ១៩៧៥-១៩៧៩។ ជាប្រវត្តិសាស្ត្រកម្ពុជា ក្នុងសម័យនោះចំណុចសំខាន់តែមួយគត់ដែលលើកឡើងនោះគឺ មិនមានច្បាប់ស្ដីពីសិទ្ធិលើទ្រព្យសម្បត្តិនោះទេ ហើយរាល់ឯកសារកំណត់ត្រាដីធ្លីនានាត្រូវបានបំផ្លាញចោលអស់ផងដែរ។ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់។ អចលនវត្ថុរួមជាមួយមធ្យោបាយផលិតកម្មសំខាន់ៗជាទូទៅផ្សេងៗទៀតត្រូវបានដាក់ជា "កម្មសិទ្ធិរបស់ប្រជាជន និងកម្មសិទ្ធិរួមរបស់ប្រជាជនសមូហភាព"។

បន្ទាប់មកទៀតស្ទើរតែពេញសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា សិទ្ធិលើទ្រព្យផ្ទាល់ខ្លួនរបស់បុគ្គលមិនត្រូវបានច្បាប់ទទួលស្គាល់ឡើយ។ ប៉ុន្តែមានការកែទម្រង់ក្នុងឆ្នាំ ១៩៨៩ (មុនមានការអនុម័តនូវរដ្ឋធម្មនុញ្ញថ្មី ឆ្នាំ១៩៩៣ តែបន្តិច) តាមរយៈការអនុម័តនូវ អនុក្រឹត្យស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះជូនប្រជាពលរដ្ឋ (គឺអនុក្រឹត្យលេខ២៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩)។ មាត្រា១ នៃអនុក្រឹត្យនេះចែងឡើងវិញអំពីរូបភាពនៃកម្មសិទ្ធិសមូហភាពលើដីលំនៅឋាន។

មានការកែប្រែដ៏សំខាន់មួយត្រូវបានធ្វើឡើងតាមរយៈមាត្រា ០២ នៃអនុក្រឹត្យលេខ ២៥ នេះ ដែលចែងថា កម្មសិទ្ធិលើផ្ទះសម្បែងអាចចេញឱ្យបុគ្គលនានាបាន ហើយកម្មសិទ្ធិលើផ្ទះសម្បែងនោះ អាចធ្វើការផ្ទេរតាមរយៈ មត៌កសាសន៍ ឬការលក់ បានដោយស្របច្បាប់។ អត្ថបទខាងក្រោមនេះ នឹងលើកយកការពិភាក្សាអំពីការវិវត្តច្បាប់នៃការលក់ពីឆ្នាំ១៩៨៩ រហូតដល់ក្រមរដ្ឋប្បវេណីបច្ចុប្បន្នចូលជាធរមាន។[1]

---

* អ្នកនិពន្ធបច្ចុប្បន្នជា ប្រធានការិយាល័យស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ នៅគណៈមេធាវីកម្ពុជា លោកក៏ជាសាស្ត្រាចារ្យច្បាប់ និងជាអតីតព្រឹទ្ធបុរសឧបការី នៅសាកលវិទ្យាល័យកម្ពុជា។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិភូមិបាល និងបេតិកភ័ណ្ឌដែលសហប្រតិការរវាង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣។ លោកក៏ទទួលបាននូវសញ្ញាបត្រ High Diploma ផ្នែកនីតិភូមិបាល និងបេតិកភ័ណ្ឌពីសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង៣ ផងដែរ។ អ្នកនិពន្ធបានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាត្របត្រភាសាអង់គ្លេស TEFL ពីសាកលវិទ្យាល័យធនធានមនុស្ស។

[1] ច្បាប់អចលនវត្ថុនៅកម្ពុជា រៀបរៀងដោយ East-West Management Institute

## ជំពូកទី១៖ ការវិវត្តស្ដីពីការលក់ដីធ្លីពីឆ្នាំ១៩៨៩ ដល់ឆ្នាំ២០០១

### ១. ការទិញលក់ដីធ្លីក្នុង ឆ្នាំ១៩៨៩ ដល់ឆ្នាំ២០០១

អនុក្រឹត្យលេខ២៥ ឆ្នាំ១៩៨៩ រដ្ឋាភិបាលបានផ្ដល់នូវរបបកម្មសិទ្ធិជូនដល់ប្រជាជនលើផ្ទះដែលខ្លួនបានកំពុងកាន់កាប់ផ្ទាល់ ក៏ប៉ុន្តែការផ្ដល់នេះហាក់នៅមានកម្រិតនៅឡើយ។ ក្រោយមកនៅឆ្នាំ១៩៩២ ច្បាប់ថ្មីមួយត្រូវបានប្រកាសឱ្យប្រើក្នុងគោលដៅដើម្បីកំណត់អំពីអចលនវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា នោះគឺច្បាប់ភូមិបាល[2]។ ច្បាប់នេះយើងអាចចាត់ទុកថាជាច្បាប់ពិសេសនៅក្នុងសម័យកាលនោះ។

សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការលក់ដូរដីធ្លីត្រូវបានផ្ដល់ឱ្យតាមរយៈច្បាប់នេះ។ ប៉ុន្តែសិទ្ធិក្នុងការដោះដូរ ឬលក់ ឬចាត់ចែងនូវអចលនវត្ថុរបស់ខ្លួនមាន និងកំពុងកាន់កាប់ដោយសេរីបាន តែកុំឱ្យតែការលក់នោះខុសនឹងបញ្ញត្តិច្បាប់បានហាមឃាត់។

ការលក់អចលនវត្ថុត្រូវបានឱ្យនិយមន័យយ៉ាងច្បាស់ក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ ថាគឺជា "**កិច្ចសន្យា ដែលជនម្នាក់ហៅថា អ្នកលក់ត្រូវផ្ទេរនូវសិទ្ធិនៃអចលនវត្ថុនោះ ឬកម្មសិទ្ធិណាមួយជារបស់ខ្លួនឱ្យទៅជនម្នាក់ទៀត ហៅថាអ្នកទិញដែលត្រូវចេញថ្លៃជាប្រាក់តាមតម្លៃនៃវត្ថុនោះ ឬសិទ្ធិនោះឱ្យអ្នកលក់**"។[3] ការអនុគ្រោះនេះបានបើកឱ្យប្រជាពលរដ្ឋអាចលក់នូវអចលនវត្ថុបាន តែលុះត្រាខ្លួនជាម្ចាស់កម្មសិទ្ធិករលើទ្រព្យនោះ។ ក៏ប៉ុន្តែករណីខ្លះបើសិនមានច្បាប់ហាមមិនឱ្យលក់ គាត់ក៏មិនអាចលក់បានដែរ។[4]

---

[2] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២។

[3] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧៧។

[4] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧៨។

## តារាងការវិវត្តនៃសិទ្ធិកម្មសិទ្ធិលើដីធ្លីនៅកម្ពុជា[5]




ច្បាប់ភូមិបាលឆ្នាំ១៩៩២ បានឆ្លុះបញ្ចាំងលើការវិវត្តយ៉ាងទូលំទូលាយលើការលក់អចលនទ្រព្យមានដីធ្លី ឬលំនៅឋានជាដើម។ ក្នុងនោះដើម្បីការលក់អចលនវត្ថុមានសុពលភាព លុះត្រាតែធ្វើតាមទម្រង់លិខិតយថាភូត[6] ពោលគឺមានកិច្ចសន្យាលក់អចលនវត្ថុ ដែលគោរពតាមបទដ្ឋាន ដែលច្បាប់ទទួលស្គាល់ និងមានការដឹងឮពីអាជ្ញាធរសាធារណៈ។

បើមិនគោរពនោះ កិច្ចសន្យាលក់នោះត្រូវបានសន្មតថាមិនស្របច្បាប់។ ដើម្បីកាន់តែមានភាពជាក់ច្បាស់យើង និងធ្វើការបែងចែកការពិភាក្សាជាដំណាក់កាលនៃការវិវត្តលើបទប្បញ្ញត្តិលក់នៅកម្ពុជាចាប់ពីឆ្នាំ១៩៨៩ ដល់១៩៩៣ និង ១៩៩៣ ដល់២០០១។

---

[5] សិន្និសីទស្រាវជ្រាវវិទ្យាសាស្ត្រលើប្រធានបទ សិទ្ធិកម្មសិទ្ធិលើដីធ្លីនៅកម្ពុជា ដោយ បណ្ឌិត ហាប់ ផល្លី ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៩

[6] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧៩។

## ២. ការវិវត្តស្ដីពីការលក់ដីធ្លីពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣

មានបទប្បញ្ញត្តិចំនួន០៣ ដែលបានបង្កើតឡើងក្នុងចន្លោះឆ្នាំ១៩៨៩ ដល់១៩៩៣ ក្នុងនោះមានអនុក្រឹត្យលេខ២៥ ស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើផ្ទះជូនប្រជាពលរដ្ឋ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩។ រដ្ឋធម្មនុញ្ញចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ និងច្បាប់ភូមិបាល ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ១៩៩២ ដែលបទប្បញ្ញត្តិទាំងនោះបានចែងអំពីរិធានគ្រប់គ្រង និងការលក់ដូរដីធ្លី និងលំនៅឋាន។

នៅក្នុងបទប្បញ្ញត្តិនៃអនុក្រឹត្យស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើផ្ទះជូនប្រជាជន តាមរយៈអនុក្រឹត្យលេខ២៥ បានកំណត់ថា ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រងដីលំនៅឋានស្របទៅតាមច្បាប់ នៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ហើយរដ្ឋបានធ្វើការបែងចែកកម្មសិទ្ធិផ្ដាច់មុខឱ្យទៅគ្រួសារលើលំនៅឋានរបស់ខ្លួនដែលកំពុងរស់នៅក្នុងឃុំ/សង្កាត់ទូទាំងប្រទេស ដែលត្រូវបានរដ្ឋអំណាចទទួលស្គាល់។

អនុក្រឹត្យនេះបានបើកសិទ្ធិឱ្យកម្មសិទ្ធិករ អាចធ្វើការបែងចែងទ្រព្យទាំងនោះបានឱ្យទៅទាយាទរបស់ខ្លួនបាន តាមរយៈការធ្វើជាមត៌ក ឬការធ្វើអំណោយឱ្យទៅបងប្អូនសាច់ញាតិ ឬលក់ឱ្យទៅអ្នកដ៏ទៃបាន។ ប៉ុន្តែមានចំណុចមួយ ដែលរឹតត្បឹតនោះ គឺកម្មសិទ្ធិករមិនអាចលក់លំនៅឋានឱ្យទៅជនបរទេសបានឡើយ។[7] មាត្រា១៥ នៃអនុក្រឹត្យដដែលនេះបានចែងបន្ថែមទៀតថា ក្រៅពីកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ដែលកំពុងរស់នៅលើលំនៅឋានណាមួយ ត្រូវសុំទិញលំនៅឋាន ឬដីសង់លំនៅឋាននោះផ្ដាច់ពីរដ្ឋទុកជាកម្មសិទ្ធិផ្ទាល់ខ្លួន លើកលែងតែក្នុងករណីចេញថវិកាសង់លំនៅឋានផ្ទាល់ខ្លួន និងលំនៅឋានសង់ដោយខ្លួនឯង ត្រូវចាត់ទុកជាកម្មសិទ្ធិផ្ទាល់ខ្លួន។ រាល់ការលក់ដូរផ្ទះ ឬធ្វើអំណោយផ្ទះត្រូវធ្វើឡើងដោយកិច្ចសន្យា ដែលអ្នកទិញ ឬអ្នកទទួលអំណោយត្រូវយកទៅចុះបញ្ជីប្រថាប់ត្រាចំនួន១០ភាគរយ នៃតម្លៃផ្ទះតាមប្រភេទផ្ទះសម្រាប់ធ្វើអាជីវកម្ម សេវាកម្ម សិប្បកម្ម ឬឧស្សាហកម្ម។

---

[7] អនុក្រឹត្យស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា,លេខ២៥អនក្រ,២២ មេសា១៩៨៩, មាត្រា២។

## តារាងពន្ធប្រថាប់ត្រា[8]




| Year | Stamp Duty (%) |
|---|---|
| 1989 | 10 |
| 1991 | 6 |
| 1995-now | 4 |

ទន្ទឹមនឹងនេះដែរ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ បានចែងថា “ពលរដ្ឋកម្ពុជា មានសិទ្ធិពេញទីក្នុងការកាន់កាប់ ប្រើប្រាស់ដីធ្លី និងមានសិទ្ធិតំណមត៌កលើដីធ្លី ដែលរដ្ឋបានប្រគល់ឱ្យសម្រាប់រស់នៅ និងធ្វើអាជីវកម្ម”។[9] តាមស្មារតីនៃមាត្រានេះ គេអាចមើលឃើញថារដ្ឋគ្រាន់តែអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែប្រើប្រាស់ និងអាស្រ័យផលតែប៉ុណ្ណោះ។ ប៉ុន្តែអ្វីដែលប្លែកនោះ រដ្ឋបានធ្វើការហាមឃាត់ចំពោះការចាប់ដី ដែលទំនេរបង់ពន្ធទុក សម្រាប់លក់និងជួលឱ្យអ្នកដ៏ទៃ។ ក្នុងនោះជនណាក៏ដោយ មិនអាចប្រើប្រាស់ដីធ្លី កសិកម្ម ដីព្រៃ ដោយចិត្តឯងក្នុងគោលបំណងផ្សេងទៀតបានទេ បើគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។[10] ហេតុនេះយើងអាចសន្និដ្ឋានបានថា ក្រៅពីដីទំនេរ រដ្ឋឱ្យតែដីដែលរដ្ឋបានធ្វើការបែងចែកឱ្យប្រជាពលរដ្ឋហើយនោះ ពួកគេអាចធ្វើការលក់ដោះដូរ ឬជួលបានតាមគោលបំណងរបស់ខ្លួនបាន។

[8] ដកស្រង់ចេញពីមេរៀន ពន្ធលើដីធ្លី បង្រៀនដោយបណ្ឌិត ហាប់ផល្លី ឆ្នាំ ២០១៥

[9] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា១៥។

[10] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣ មាត្រា១៦។

ក្រៅពីនេះពាក់ព័ន្ធនឹងកិច្ចសន្យាលក់-ទិញ យើងអាចប្រើប្រាស់ក្រឹត្យច្បាប់លេខ៣៨ ដែលជាច្បាប់ទូទៅដែលពាក់ព័ន្ធនឹងការអនុវត្តលើកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

ចេញពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ យើងឃើញមានច្បាប់ភូមិបាលឆ្នាំ១៩៩២។ ច្បាប់ភូមិបាលនេះ បានចែងវិធានទាក់ទងនឹងការលក់មានចំនួន១២មាត្រា (មាត្រា១៧៧ ដល់ ១៨៨)។ ច្បាប់ដដែលនេះបានចែងស្រដៀងគ្នាថា ដីធ្លីជារបស់រដ្ឋ ហើយរដ្ឋផ្តល់ជូនប្រជាពលរដ្ឋនូវសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី។ រដ្ឋមិនទទួលស្គាល់ឡើយ នូវសិទ្ធិកម្មសិទ្ធិទាំងឡាយណាមុនឆ្នាំ១៩៧៩ ពោលគឺរដ្ឋទទួលស្គាល់សិទ្ធិកម្មសិទ្ធិទាំងឡាយណាដែលរដ្ឋបានផ្តល់ឱ្យតែប៉ុណ្ណោះ។ សិទ្ធិកម្មសិទ្ធិផ្សេងទៀត លើដីធ្លីត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់នេះ។[11] ទោះបីជាយ៉ាងណាច្បាប់ភូមិបាលនេះ មិនទាន់បានបើកសិទ្ធិកម្មសិទ្ធិពេញលេញសម្រាប់ពលរដ្ឋទេ ដោយយើងសង្កេតឃើញថាមាត្រា២ នៃច្បាប់នេះបានចែងថា “ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទីក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី និងមានសិទ្ធិតំណមត៌កលើដីធ្លីដែលរដ្ឋប្រគល់ឱ្យសម្រាប់រស់នៅ និងធ្វើអាជីវកម្ម”។ បំពេញបន្ថែមដោយមាត្រា៣ នៃច្បាប់នេះដដែលនោះ “រដ្ឋធានាឱ្យប្រើប្រាស់ដីធ្លីនូវសិទ្ធិកាន់កាប់ ប្រើប្រាស់ និង ទទួលផលស្របច្បាប់អំពីដីធ្លី។ ការប៉ះពាល់ដល់កម្មសិទ្ធិសិទ្ធិឯកជននៃពលរដ្ឋត្រូវហាមឃាត់មិនឱ្យមាន វៀរលែងតែប្រយោជន៍សារធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលមានចែងក្នុងច្បាប់”។ ពាក្យកម្មសិទ្ធិករ ត្រូវបានគេប្រើប្រាស់ក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ ហេតុនេះយើងអាចសន្មត់បានថា រដ្ឋហាក់កំពុងបានទទួលស្គាល់លើសិទ្ធិកម្មសិទ្ធិឯកជនលើដីធ្លី។ សញ្ញាណនៃការលក់អចលនវត្ថុ ក៏ត្រូវបានរំលេចឱ្យឃើញផងដែរ នៅក្នុងច្បាប់ភូមិបាល១៩៩២។ តួយ៉ាង មាត្រា១៨៨ នៃច្បាប់នេះបានចែងអំពីនីតិវិធីនៃការលក់ ដែលបានឱ្យនិយមន័យយ៉ាងច្បាស់ថា “ការលក់អចលនវត្ថុ ជាកិច្ចសន្យាដែលមានអ្នកលក់ និងអ្នកទិញ ហើយអ្នកលក់ត្រូវផ្ទេរនូវសិទ្ធិនៃអចលនវត្ថុនោះទៅឱ្យអ្នកទិញ ហើយអ្នកទិញត្រូវបង់ប្រាក់តាមតម្លៃនៃវត្ថុនោះឱ្យទៅអ្នកលក់វិញ ហើយកិច្ចសន្យាលក់អចលនវត្ថុត្រូវធ្វើឡើងក្រោមទម្រង់យថាភូតទើបមានលក្ខណៈស្របច្បាប់”។ បន្ថែមពីនេះ ច្បាប់ក៏បានបើកឱ្យម្ចាស់កម្មសិទ្ធិករអាចធ្វើការលក់ទ្រព្យរបស់ខ្លួន ដែលជាកម្មសិទ្ធិផ្ទាល់ឱ្យទៅអ្នកដ៏ទៃបាន។ ប៉ុន្តែក៏មានការកម្រិតសិទ្ធិក្នុងការលក់ដែរ ពោលគឺអាចលក់បានតែទ្រព្យផ្ទាច់មុខរបស់ខ្លួន ហើយការលក់នេះមិនខុសច្បាប់ ឬបទបញ្ញាណាដែលហាមឃាត់តែប៉ុណ្ណោះ។[12] ក្នុងនោះអ្វីដែលហាមឃាត់មានការលក់ទ្រព្យ ដែលមិនមានជារបស់ខ្លួន ការលក់អចលនវត្ថុពីប្តីទៅប្រពន្ធ

[11] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១។

[12] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧៨។

ឬពីប្រពន្ធទៅប្តី ឬការលក់ទ្រព្យដែលបំបែកគ្នាពុំបាន ដោយមិនមានការយល់ព្រមគ្នាពីសហកម្មសិទ្ធិករទាំងអស់។[13] ក្រៅពីនេះនូវមានសញ្ញាណមួយទៀតដែរ គឺពាក់ព័ន្ធនឹងកតិការភេទ[14]នៃការលក់ ប្រសិនបើអ្នកលក់បានលក់អចលនវត្ថុដែលមានតម្លៃទាបជាងពាក់កណ្តាលនៃថ្លៃដែលត្រូវលក់នោះអ្នកលក់អាចធ្វើការប្តឹងទាមទារតាមរយៈកតិការភេទនៃការលក់បាន។ បន្ទាប់ពីតុលាការបានទទួលនូវពាក្យបណ្តឹង ហើយតុលាការមានសិទ្ធិកាត់សេចក្តីឱ្យមោឃៈភាពការលក់នោះបាន ទោះបីក្នុងកិច្ចសន្យាបានចែងថាអ្នកលក់នឹងមិនទាមទារឱ្យមានការសើរើកតិការភេទក៏ដោយ។ ទាំងនេះជាការវិវត្តមួយនៃបទបញ្ញត្តិស្តីពីការលក់ដូរ ដែលយើងបានសង្កេតឃើញមាននៅក្នុងសម័យកាលនោះ។

## ៣. ការវិវត្តស្តីពីការលក់ដីធ្លីពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០១

ស្ថិតនៅក្នុងដំណាក់កាលពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០១នេះ គេសង្កេតឃើញនូវរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ភូមិបាលឆ្នាំ២០០១ ដែលចែងពាក់ព័ន្ធនឹងកម្មសិទ្ធិឯកជន និងបញ្ញត្តិនៃការលក់។សិទ្ធិកម្មសិទ្ធិនៅក្នុងដំណាក់កាលនេះមានការវិវត្តមួយ ដែលមានលក្ខណៈល្អប្រសើរជាងមុន ពោលគឺសិទ្ធិកម្មសិទ្ធិត្រូវបានផ្តល់ជូនប្រជាពលរដ្ឋខ្មែរយ៉ាងពេញលេញ ហើយពេលវេលានៃនត្ថិភាពនូវភោគៈ[15]ថ្មីៗចាប់ពីឆ្នាំ២០០១នេះ។ នៅក្នុងសម័យកាលនោះ បុគ្គលដែលមានសញ្ជាតិបរទេសនៅតែមិនបានផ្តល់សិទ្ធិកម្មសិទ្ធិលើដីដដែល[16] ដើម្បីពិនិត្យមើលនូវភាពខុសប្លែកនៃបញ្ញត្តិនៃការលក់នោះ យើងនឹងធ្វើការពិនិត្យមើលទៅលើបទប្បញ្ញត្តិទាំងនោះជាបន្តបន្ទាប់។

តាមរយៈជំពូកទី៦(អំពីរបៀបលទ្ធកម្មនៃកម្មសិទ្ធិ) ផ្នែកទី១(អំពីលទ្ធកម្មដោយការលក់អចលនវត្ថុ) នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានបញ្ញត្តិទាក់ទងនឹងការលក់នេះមានចំនួនតែ៦មាត្រាប៉ុណ្ណោះ(មាត្រា៦៤ ដល់មាត្រា៦៩) ហើយអ្វីដែលមានការប្រែប្រួលនោះ គឺទាក់ទងទៅ

---

[13] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៨០។

[14] សន្ទានុក្រមច្បាប់ភូមិបាល ឆ្នាំ២០០១ បានកំណត់អំពីអត្ថន័យនៃ កតិការភេទ គឺ កិរិយាបដិសេធកិច្ចសន្យាណាមួយ ដោយមកពីកិច្ចសន្យានោះមានវិការៈដល់ឬសគល់នៃការព្រមព្រៀងគ្នា។ ក្នុងទីនោះកតិការភេទមានន័យថា បដិសេធកិច្ចសន្យាលក់ចោល ដោយមកពីលក់អចលនវត្ថុមានវិការៈអាថ៌កំបាំង។

[15] ដើម្បីមានសុវត្ថិភាព និងភាពកក់ក្តៅ **ភោគីគួរតែក្លាយជាកម្មសិទ្ធិករ** ប្រសិនបើការកាន់កាប់នេះ ធ្វើឡើងដោយស្របច្បាប់ ដោយគោរពតាមលក្ខខណ្ឌ៥៖ ១)កាន់កាប់ដោយពិតប្រាកដ ២)កាន់កាប់ដោយគ្មានហិង្សា ៣)កាន់កាប់ដោយមានការដឹងឮជាសាធារណៈ៤)កាន់កាប់ដោយគ្មានការអាក់ខាន ៥) កាន់កាប់ដោយសុចរិត ។

[16] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣ មាត្រា៤៤ និងច្បាប់ភូមិបាល,លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៨។

នឹងការទិញលក់តែប៉ុណ្ណោះ។ អ្វីដែលខុសគ្នាជាដំបូងនេះ គឺនិយមន័យនៃការលក់ ដែលមានចែងក្នុងមាត្រា៦៤ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា "ការលក់អចលនវត្ថុ គឺជាកិច្ចសន្យាដែលអនុញ្ញាតឱ្យផ្ទេរសិទ្ធិនៃអចលនវត្ថុពីអ្នកលក់ទៅឱ្យអ្នកទិញ ដោយអ្នកទិញត្រូវបង់ថ្លៃប្រាក់អចលនវត្ថុនោះទៅឱ្យអ្នកលក់"។[17] ចំណែកឯនិយមន័យ នៃការលក់តាមបញ្ញត្តិក្នុងច្បាប់ភូមិបាល១៩៩២ ដូចមានចែងក្នុងមាត្រា១៧៧ "ការលក់អចលនវត្ថុ ជាកិច្ចសន្យាដែលជនម្នាក់ហៅថា អ្នកលក់ត្រូវផ្ទេរនូវសិទ្ធិនៃអចលនវត្ថុនោះ ឬកម្មសិទ្ធិណាមួយជារបស់ខ្លួនឱ្យទៅឱ្យអ្នកទិញ"។[18] លើសពីនេះទៅទៀត ច្បាប់ភូមិបាលឆ្នាំ១៩៩២ មានចែងពីកតិកាភេទ ច្បាស់លាស់ជាងច្បាប់ភូមិបាលឆ្នាំ២០០១។ នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ក៏មិនបានបញ្ញត្តិពីអ្នកទទួលបានបន្ទុកសោហ៊ុយក្នុងការធ្វើលិខិតលក់ និងបង់ពន្ធប្រថាប់ត្រានោះទេ ដូចដែរច្បាប់ភូមិបាល មាត្រា ១៨៨ ឆ្នាំ១៩៩២ បានបញ្ញត្តិ **សោហ៊ុយអំពីការធ្វើលិខិតលក់ និងសោហ៊ុយប្រថាប់ត្រាផ្សេងៗជាបន្ទុករបស់អ្នកទិញ។**[19] ករណីនេះវាអាចមកពីការប្រែប្រួលនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ដែលកម្ពុជាបានធ្វើការផ្លាស់ប្តូរ របបសេដ្ឋកិច្ចពីផែនការ ទៅរបបទីផ្សារសេរី ពោលគឺទុកលទ្ធភាពឱ្យគូភាគីជាអ្នកពិភាក្សា ឬចរចារហើយកំណត់តាមសេរីនៃការព្រមព្រៀងនោះ កុំឱ្យតែខុសច្បាប់។

ផ្សេងពីនេះវិញ យើងឃើញថាច្បាប់ភូមិបាលឆ្នាំ២០០១នេះ បានបញ្ញត្តិនូវបុគ្គលបីប្រភេទ ដែលមិនអាចក្លាយជាអ្នកលក់បាន បុគ្គលដែលមិនមែនជាកម្មសិទ្ធិករនៃទ្រព្យដែលត្រូវលក់ កម្មសិទ្ធិករនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករអវិភាគផ្សេងទៀត និងបុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស។ លើសពីនេះទៅទៀតមានបុគ្គលបួនប្រភេទទៀតដែលមិនក្លាយជាអ្នកទិញបានរួមមាន អាណាព្យាបាលមិនអាចទិញទ្រព្យរបស់បាលិត[20] ខ្លួន ហិតូបត្ថម្ភកៈមិនអាចទិញទ្រព្យដែលខ្លួនគ្រប់គ្រង ចៅក្រម ឬភ្នាក់ងាររដ្ឋបាលមិនអាចទិញទ្រព្យដែលយុត្តាធិការរបស់ខ្លួន ឬដែលខ្លួនមានបេសកកម្មលក់ បុគ្គលដែលមានទ្រព្យត្រូវរឹបអូសមិនអាចទិញទ្រព្យនោះវិញបានទេ[21]ហើយមានតែការលក់មួយ ប្រភេទដែលត្រូវចាត់ទុកជាមោឃៈ គឺការលក់រវាងសហព័ទ្ធ។[22]

---

[17] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា៦៤។

[18] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧៧។

[19] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២ មាត្រា១៨៨។

[20] កូនកំព្រាជាអនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលនៃជនម្នាក់

[21] ច្បាប់ភូមិបាល,លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៦៦។

[22] ច្បាប់ភូមិបាល,លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៦៧។

## ជំពូកទី២៖ ការវិវត្តច្បាប់ស្តីពីការលក់ដីធ្លីពីឆ្នាំ២០០១ រហូតដល់បច្ចុប្បន្ន

### ១. ការវិវត្តស្តីពីការលក់ដីធ្លីពីឆ្នាំ២០០១ ដល់២០១០

ការវិវត្តនៃការទិញលក់មានជាលំដាប់ រហូតដល់ឆ្នាំ២០០១ យើងមានច្បាប់ភូមិបាលឆ្នាំ២០០១ ដែលបានអនុម័តដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលបានបញ្ញត្តិពីការទិញលក់ នៅក្នុងផ្នែកទី១ នៃជំពូកទី៦ ស្តីពីលទ្ធកម្មដោយការលក់អចលនវត្ថុ ពីមាត្រា៦៤ ដល់មាត្រា៦៩ សរុបគឺ០៦មាត្រា។[23] រហូតដល់ឆ្នាំ២០០៧ បញ្ញត្តិករបានបង្កើតក្រមរដ្ឋប្បវេណី ដែលនេះជាការវិវត្តមួយថ្មី និងមានលក្ខណៈសំខាន់គួរឱ្យកត់សម្គាល់ ដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នេះ[24] ត្រូវបានប្រកាសឱ្យប្រើជំនួសច្បាប់ទាំងឡាយពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃការលក់អចលនវត្ថុ។

លក្ខខណ្ឌទូទៅនៃកិច្ចសន្យា ត្រូវបានកំណត់នៅក្នុងគន្ថីទី៤ ស្តីពីកាតព្វកិច្ចរវាងគូភាគី និងលក្ខខណ្ឌពិសេស ដែលគ្រប់កិច្ចសន្យាត្រូវយកមកអនុវត្ត ដែលមានលក្ខណៈបំពេញបន្ថែមក្នុងករណីគ្រប់បញ្ញត្តិ នៃគន្ថីទី៥ នៃក្រមរដ្ឋប្បវេណី២០០៧ ដែលស្តីពី កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល មិនបានលម្អិតនៅក្នុងចំណុចនៃកិច្ចសន្យាទាំងនោះ។ ដែលក្នុងនោះមានការចែងអំពីការលក់ទិញ ចាប់ពីមាត្រា៥១៥ ដល់មាត្រា៥៦៥ នៃក្រមរដ្ឋប្បវេណីថ្មីនេះ ដោយក្នុងនោះមានការចែងពីនិយមន័យ លក្ខខណ្ឌនៃការបង្កើត ការសន្យាលក់ទិញជាមុនដោយឯកតោភាគី នីតិវិធីនៃការបង់ប្រាក់ថ្លៃលក់ ប្រាក់កក់ និងសោហ៊ុយក្នុងការលក់ទិញ សមត្ថភាពនៃគូភាគី វត្ថុដែលអាចលក់បានការទទួលខុសត្រូវរបស់ភាគី និងការអនុវត្តកិច្ចសន្យាដោយអនុវត្តសិទ្ធិលោះ។[25]

ជាការពិតណាស់ក្រមរដ្ឋប្បវេណីត្រូវបានអនុម័តដោយរដ្ឋសភានាថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ តែរហូតដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ទើបក្រមរដ្ឋប្បវេណីចាប់អនុវត្ត។[26] ការបង្អង់ការអនុវត្តបែបនេះ ក្នុងគោលបំណងទុកពេលឱ្យសាធារណៈជនអាចមានឱកាសស្វែងយល់ពីក្រមថ្មីនេះជាមុនសិន។ តែទោះក្រមរដ្ឋប្បវេណីមិនទាន់ដាក់ឱ្យអនុវត្តក្តី យើងក៏ឃើញមានបទប្បញ្ញត្តិមួយចំនួនបានបង្កើតឡើងក្រោយពីក្រមនេះបានអនុម័តហើយដែរ ដូចជាច្បាប់

[23] ច្បាប់ភូមិបាល,លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៦៤ ដល់៦៩

[24] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[25] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥១៥ ដល់៥៦៥។

[26] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីលេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៨៤។

ស្ដីពីការផ្ដល់កម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស[27] និងអនុក្រឹត្យស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ[28]។

ដោយសារយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន ដែលមិនបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិលើដីធ្លី[29] បែបនេះទើបមានការបង្កើតជាច្បាប់ និងអនុក្រឹត្យនេះឡើង ដើម្បីអាចឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិលើអគារចាប់ពីជាន់ទី១។ ប៉ុន្តែការផ្ដល់សិទ្ធិកម្មសិទ្ធិនេះគឺអនុញ្ញាតតែទៅលើអគារសហកម្មសិទ្ធិ និងមានសិទ្ធិកម្មសិទ្ធិពេញលេញ ផ្ដាច់មុខតែទៅលើអគារដែលជាចំណែកឯកជន ហើយមានការរឹតត្បិតសិទ្ធិកម្មសិទ្ធិរបស់ជនបរទេស ទទួលបានតែសិទ្ធិប្រើប្រាស់ និងអាស្រ័យផលប៉ុណ្ណោះចំពោះចំណែករួមពោលគឺគ្មានសិទ្ធិចាត់ចែងទេ។[30] តែជាការចំឡែកមួយដែរ ដែលនៅពេល ជនបរទេសអាចបាត់បង់សិទ្ធិចាត់ចែងរបស់ខ្លួនលើចំណែករួម តែពេលជនបរទេសដដែលធ្វើលទ្ធកម្មកម្មសិទ្ធិ ចំពោះកម្មសិទ្ធិនៃអគារសហកម្មសិទ្ធិនោះ ប្រសិនបើអ្នកទិញ ជនជាតិខ្មែរ នាំឱ្យគាត់មានសិទ្ធិទទួលបានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងពេញលេញទាំងទៅលើចំណែកឯកជន និងចំណែករួមវិញ។ បន្ថែមទៀតនោះសម្រាប់អគារសហកម្មសិទ្ធិ អាចធ្វើការផ្ទេរកម្មសិទ្ធិបានមិនថាអ្នកទិញទេ ដែលត្រូវបំពេញតាមលក្ខខណ្ឌនានា តែសូម្បីអ្នកលក់ក៏ត្រូវតែគោរពតាមបទប្បញ្ញត្តិជាធរមានស្ដីពីការចុះបញ្ជីអគារជាអគារសហកម្មសិទ្ធិថែមទៀត នោះទើបជនបរទេសអាចមានសិទ្ធិក្នុងការទទួលបានកម្មសិទ្ធិ។ ការកម្រិតម្យ៉ាងទៀតនោះ សម្រាប់ជនបរទេសដដែល អាចទទួលបានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន លុះត្រាតែសមាមាត្រនៃចំណែកឯកជនមិនលើស ៧០ភាគរយ សម្រាប់ជនបរទេស ដោយត្រូវកត់ត្រាបញ្ចូលសមាមាត្រនៃផ្ទៃក្រឡាចំណែកឯកជន ដោយធៀបជាមួយចំណែកផ្ទៃក្រឡាចំណែកឯកជនទាំងមូល។[31]

តែយើងតាមករណីខាងលើនេះផងដែរ ក៏នៅតែមានបញ្ញត្តិនានា ដែលចែងស្ដីពីអគារសហកម្មសិទ្ធិនេះ តែនៅមិនទាន់មានការឯកភាពសម្រាប់ការបកស្រាយនោះដែរ ចំពោះករណីអគារដែលមានច្រើនជាន់ដែលបានសាងសង់តាំងពីមុនឆ្នាំ១៩៧៥ ហើយសល់រហូតមកដល់

---

[27] ច្បាប់ស្ដីពីការផ្ដល់កម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, លេខ នស/រកម/០៥១០/០០៦, ២៤ ឧសភា ២០១០។

[28] អនុក្រឹត្យស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ ១២៦ អនក្រ/បក, ១២ សីហា ឆ្នាំ២០០៩

[29] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣,មាត្រា៤៤

[30] ច្បាប់ស្ដីពីការផ្ដល់កម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, លេខ នស/រកម/០៥១០/០០៦, ២៤ ឧសភា ២០១០, មាត្រា១។

[31] អនុក្រឹត្យស្ដីពីការកំណត់ចំនួនសមាមាត្រ និងរបៀបគិតគូរចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសនៅក្នុងអគារសហកម្មសិទ្ធិ,លេខ ៨២ អនក្រ.បក, ២៩ កក្កដា ២០១០, មាត្រា១ ដល់៣។

បច្ចុប្បន្ន ថាតើគួរកំណត់អគារទាំងនោះជាអគារសហកម្មសិទ្ធិតែម្តង ដោយអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិក្នុងការក្លាយជាម្ចាស់កម្មសិទ្ធិករ តាមរយៈច្បាប់និងអនុក្រឹត្យដែលមានដូចយោងខាងលើ ឬក៏មិនអនុញ្ញាតទេ លុះត្រាតែម្ចាស់កម្មសិទ្ធិ ឬអ្នកលក់បានចុះបញ្ជីផ្ទះ ឬអគារទាំងមូលនោះ ជាអគារសហកម្មសិទ្ធិថែមទៀតទើបមានសិទ្ធិលក់។ អាស្រ័យដោយមិនទាន់មានបទប្បញ្ញត្តិ ឬយុត្តិសាស្ត្រនៃប្រទេសកម្ពុជាណាមួយ ដែលមានចែងពីបញ្ហាគតិយុត្តមួយនេះនៅឡើយ ដូច្នេះចំណោទនេះនៅតែជាចំណុចស្រពិចស្រពិល ដែលតាមរយៈការអនុវត្តចំពោះការទិញ លក់ផ្ទះសំបែងទៅឱ្យជនបរទេសមិនមានអ្វីធានាសុវត្ថិភាពគតិយុត្តសម្រាប់ពួកគេនៅឡើយ។

ពិតមែនថាយើងឃើញថាបទប្បញ្ញត្តិស្តីពីអគារសហកម្មសិទ្ធិមានលក្ខណៈប្រសើរហើយក្តី តែយើងក៏ឃើញដែរថា គឺមានការកែប្រែបន្តិចបន្តួចទៀត ដើម្បីឱ្យការអនុវត្តអនុក្រឹត្យកាន់តែប្រសើរផងដែរ ដោយក្នុងនោះគឺមានអនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារកម្មសិទ្ធិបន្ថែមទៀត ដោយក្នុងនោះគឺផ្តោតទៅលើនីតិវិធីនៃការចុះបញ្ជីចំណែកឯកជន។[32]

## ២.ការវិវត្តក្រោយពីក្រមរដ្ឋប្បវេណីចូលជាធរមានរហូតដល់បច្ចុប្បន្ន

ក៏ប៉ុន្តែដោយភាពខ្វះខាតការបញ្ជាក់ឱ្យបានច្បាស់ពីអានុភាពអនុវត្ត នាំឱ្យក្រមនេះមិនអាចអនុវត្តបានតែឯងទេ ដោយក្រមនេះ ត្រូវបានបំពេញបន្ថែមដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី[33] ជាបន្ថែមទៀតនោះ ថ្វីត្បិតតែក្រមរដ្ឋប្បវេណី បានអនុម័តតាំងពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ក្តី តែក្រមនេះចូលជាធរមាន និងអនុវត្តបាន គឺរាប់ពីថ្ងៃ២១ ខែធ្នូ ឆ្នាំ២០១១។[34] ដូច្នេះ ក្រោយពីក្រមរដ្ឋប្បវេណីបានចូលជាធរមាន និងមានអានុភាពអនុវត្តពេញលេញហើយនោះ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក៏ដល់ពេលអនុវត្តផងដែរ ដែលក្នុងនោះ មាត្រានៃច្បាប់ភូមិបាលឆ្នាំ២០០១ ស្តីពីលទ្ធកម្មដោយការលក់អចលនវត្ថុត្រូវបានលុបចោលចាប់ពីមាត្រា៦៤ ដល់មាត្រា៦៩កថាខណ្ឌទី១ ដោយទុកតែបញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រា៦៩ តែប៉ុណ្ណោះ។[35] ដោយក្នុងនោះ បាននៅសល់តែវិធានដែលអនុវត្តគឺ “កិច្ចសន្យាលក់អចលនវត្ថុ

[32] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារកម្មសិទ្ធិ,លេខ ១១៤ អនក្រ.បក, ១៤ មីនា ២០១៤, មាត្រា១។

[33] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

[34] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីលេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៨៤។

[35] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៨០។

នឹងអាចចុះបញ្ជីបាន លុះត្រាតែភាគីទាំងអស់បានបង្ហាញភស្តុតាងថារាល់ពន្ធដារលើទ្រព្យនោះត្រូវបានបង់រួច”។[36]ដូច្នេះ មានន័យថា ការទិញលក់ មានអានុភាពស្របតាមច្បាប់ជាធរមានលុះត្រាតែអ្នកទិញ បានគោរពកាតព្វកិច្ចបង់ពន្ធដារនានារួចហើយ។ យោងតាមបញ្ញត្តិនេះដែរ យើងឃើញថាការថែងដូចចំណុចនៃកថាខណ្ឌ២ នេះហាក់ចំទៀកដែលថា តម្រូវឱ្យបង់ពន្ធដារលើទ្រព្យដើម្បីយកកិច្ចសន្យាលក់អចលនវត្ថុទៅចុះបញ្ជីបាន ព្រោះដោយសារការទិញលក់អចលនវត្ថុនានា កិច្ចសន្យាគឺគ្រាន់ជាឯកសារភ្ជាប់យោងប៉ុណ្ណោះ តែការចុះបញ្ជីគឺដើម្បីបញ្ជាក់កម្មសិទ្ធិ។

មួយវិញទៀត ការយកពន្ធលើការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ មានភាពខុសគ្នាទៅតាមពីសម័យកាលមួយទៅសម័យកាលមួយ ហើយពន្ធប្រភេទនេះត្រូវបានគេឱ្យឈ្មោះថាពន្ធប្រថាប់ត្រា។ ចាប់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិអចលនវត្ថុ គឺ ៦ ភាគរយនៃតម្លៃអចលនវត្ថុ[37] ប៉ុន្តែពន្ធប្រថាប់ត្រាចំពោះការផ្ទេរអចលនវត្ថុត្រូវបានកែប្រែមកនៅត្រឹម ៤ភាគរយនៃតម្លៃអចលនវត្ថុវិញ ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ រហូតដល់បច្ចុប្បន្ន[38]។

លើសពីនេះ ពន្ធលើអចលនវត្ថុត្រូវបានបង្កើតឡើងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ មាត្រា១៣ ដោយតម្រូវឱ្យម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុទាំងអស់ដែលមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ត្រូវធ្វើការប្រកាសពន្ធប្រចាំឆ្នាំក្នុងអត្រាស្មើនឹង ០,១% នៃតម្លៃនៃអចលនវត្ថុរួមបញ្ចូលទាំងតម្លៃដី និងសំណង់អគារលើដីនោះ។ មាត្រា១៤ នៃច្បាប់នេះដដែល បានលើកលែងការយកពន្ធលើអចលនវត្ថុមួយចំនួន ដូចជាអចលនវត្ថុដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬស្ថាប័នរបស់រដ្ឋ ដីកសិកម្ម អចលនវត្ថុរបស់សហគមន៍ ឬឯកជនដែលត្រូវបានបង្កើតឡើងសម្រាប់សាសនា ឬសប្បុរសធម៌ដោយមិនយកប្រាក់ចំណេញ និងអចលនវត្ថុរបស់ទូត ឬកុងស៊ុល...។ ប្រសិនបើម្ចាស់កម្មសិទ្ធិករលើអចលនវត្ថុមិនបានធ្វើការបង់ពន្ធលើអចលនវត្ថុចាប់ពីឆ្នាំ២០១០មក ហើយគាត់បានធ្វើការលក់អចលនវត្ថុទៅបុគ្គលដ៏ទៃទៀតក្នុងឆ្នាំ២០១៣ សំណួរសួរថាតើបុគ្គលណាមួយដែលទទួលខុសត្រូវក្នុងការបង់ពន្ធលើអចលនវត្ថុ? ការទទួលខុសត្រូវនេះត្រូវជាបន្ទុកម្ចាស់កម្មសិទ្ធិករលើអចលនវត្ថុដែលទទួលប្រយោជន៍ចុងក្រោយ[39]។ មានន័យថាអ្នកទិញអចលនវត្ថុចុងក្រោយជាអ្នកទទួលបន្ទុកក្នុងការ

---

[36] ច្បាប់ភូមិបាល,លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៦៩ កថាខណ្ឌ២។

[37] ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រាឆ្នាំ១៩៩១,អត់មានលេខ, ០២ កុម្ភៈ ១៩៩១,មាត្រា២។

[38] ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥,លេខព្រះរាជក្រម ១១ ន.ស, ៣១ ធ្នូ ១៩៩៤, មាត្រា ៤០។

[39] ប្រកាសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនវត្ថុ, លេខ ៤៩៣ សហវ.ប្រក, ១៩ កក្កដា ២០១០,មាត្រា១០ កថាខណ្ឌ៤។

បង់ពន្ធលើអចលនវត្ថុ ប្រសិនបើម្ចាស់កម្មសិទ្ធិករលើអចលនវត្ថុដើមមិនបានធ្វើការបង់ពន្ធលើអចលនវត្ថុទេ។ ការកំណត់បែបនេះក្នុងន័យធ្វើឱ្យអ្នកទិញអចលនវត្ថុមានការប្រុងប្រយ័ត្នក្នុងការពិនិត្យឱ្យបានប្រាកដថា អចលនវត្ថុដែលខ្លួនបម្រុងនឹងទិញមិនមានជាប់បន្ទុកអ្វីទាំងអស់ជាពិសេសការមិនបង់ពន្ធលើអចលនវត្ថុ។

ជាសរុបមក ចាប់ពីឆ្នាំ២០១០ រាល់ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុត្រូវជាប់ពន្ធពីរប្រភេទគឺពន្ធប្រថាប់ត្រាស្មើនឹង ៤% នៃតម្លៃអចលនវត្ថុ និងពន្ធលើអចលនវត្ថុស្មើនឹង 0,១% នៃតម្លៃអចលនវត្ថុរួមបញ្ចូលទាំងតម្លៃដី និងសំណង់អគារលើដីនោះ ក្នុងករណីដែលម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុមុនមិនបានធ្វើការបង់ពន្ធលើអចលនវត្ថុ។

# អគារសហកម្មសិទ្ធិ

ដោយលោកមេធាវី វង្ស សម្បត្តិ*

## ជំពូកទី ១ ទម្រង់ទូទៅនៃកម្មសិទ្ធិ និង អគារសហកម្មសិទ្ធិ

### ១.១ ទម្រង់ទូទៅនៃកម្មសិទ្ធិ

#### ១.១.១. និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើភាពជាម្ចាស់លើទ្រព្យណាមួយ។ កម្មសិទ្ធិសំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាននៅក្នុងទំហំដែលច្បាប់បានកម្រិត។[40] មានន័យថា ម្ចាស់កម្មសិទ្ធិ ឬកម្មសិទ្ធិករមានសិទ្ធិផ្តាច់មុខ និងទូលំទូលាយក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើទ្រព្យរបស់ខ្លួនតាមការកំណត់របស់ច្បាប់ដែលស្របទៅនឹងមាត្រា៨៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ថា "កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និងទូលំទូលាយ កុំឱ្យតែយកទ្រព្យនោះទៅប្រើប្រាស់ក្នុងបទណាមួយដែលច្បាប់បានហាមឃាត់។

ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលជាច្បាប់គ្រឹះនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែង អំពីកម្មសិទ្ធិដែលសំដៅលើគោលដៅគាំពាររាល់សកម្មភាពឯកជនស្របច្បាប់ទាំងអស់មិនថាកម្មសិទ្ធិករជារូបវន្តបុគ្គល ឬនីតិបុគ្គលទេ។[41]

ដោយផ្អែកលើ និយមន័យទាំងឡាយនៃកម្មសិទ្ធិដែលបានលើកឡើងខាងលើ សុទ្ធតែផ្តោតជារួមទៅលើបុព្វសិទ្ធិសំខាន់ៗទាំងបី ដែលកម្មសិទ្ធិករគ្រប់រូបត្រូវទទួលយកបានតាមការកំណត់របស់ច្បាប់។ បុព្វសិទ្ធិនៃកម្មសិទ្ធិទាំងបីរួមមាន៖ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែង។

##### ១.១.១.១ សិទ្ធិប្រើប្រាស់

បុគ្គលដែលជាកម្មសិទ្ធិករ មានសិទ្ធិប្រើប្រាស់នូវទ្រព្យដែលជាកម្មសិទ្ធិរបស់ខ្លួនបានគ្រប់យ៉ាង មានន័យថា គាត់អាចប្រើប្រាស់ទ្រព្យទៅតាមធម្មជាតិរបស់វា ដូចជាការរស់នៅក្នុង

---

* អ្នកនិពន្ធបច្ចុប្បន្នជាមេធាវីនៅការិយាល័យ អេស ធី ជេ អន្តរជាតិ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិ ឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ អ្នកនិពន្ធក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

40 មាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

41 មាត្រា ៤៤ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

ផ្ទះ ឬការដាំដំណាំផ្សេងៗនៅលើដីដែលជាកម្មសិទ្ធិរបស់គាត់។ ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៣៨ កថាខណ្ឌ១ បានឱ្យនិយមន័យថា សិទ្ធិប្រើប្រាស់ គឺជាសិទ្ធិទទួលយកពីដីនូវបរិមាណដល់ចាំបាច់សម្រាប់សេចក្តីត្រូវការរបស់អត្តគាហកៈ[42] និងគ្រួសារខ្លួន។ និយមន័យនេះ ក៏ដូចជានិយមន័យ ដែលបានលើកឡើងខាងលើដដែល សិទ្ធិប្រើប្រាស់ គឺសំដៅទៅលើសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យ ដែលជាកម្មសិទ្ធិរបស់កម្មសិទ្ធិករនីមួយៗ ទោះបីជាទ្រព្យនោះជា ចលនទ្រព្យ ឬអចលនទ្រព្យក៏ដោយ។

### ១.១.១.២. សិទ្ធិអាស្រ័យផល

សិទ្ធិអាស្រ័យផល ឬសិទ្ធិទទួលផល ជាសិទ្ធិដែលអនុញ្ញាតឱ្យកម្មសិទ្ធិករទទួលបាននូវផលប្រយោជន៍ ឬចំណូលពីទ្រព្យរបស់ខ្លួនតាមរយៈផលស៊ីវិល ផលឧស្សាហកម្ម និង ផលធម្មជាតិ។[43]

- ផលស៊ីវិល សំដៅលើផល ដែលកើតពីទ្រព្យរបស់ខ្លួន ឬប្រាក់ ឬវត្ថុផ្សេងៗដែលទទួលជាថ្នូរចំពោះការប្រើវត្ថុអ្វីមួយ
- ផលឧស្សាហកម្ម ជាផលដែលកើតពីការងាររបស់មនុស្ស ឬមានអន្តរាគមន៍ពីមនុស្ស។
- ផលធម្មជាតិ ជាផលដែលកើតឡើងដោយឯកឯង ដោយមិនកើតពីការងាររបស់មនុស្ស

### ១.១.១.៣. សិទ្ធិចាត់ចែង

សិទ្ធិចាត់ចែង ជាសិទ្ធិដែលកម្មសិទ្ធិករធ្វើចំពោះទ្រព្យរបស់ខ្លួនតាមទំនើងចិត្ត ហើយការចាត់ចែងទ្រព្យនេះសម្តែងឡើងតាមរូបភាពពីរគឺ ៖

- កិច្ចជាសម្ភារៈ៖ កម្មសិទ្ធិករអាចបំផ្លាញ ឬ ផ្លាស់ប្តូររូបរាងអចលនវត្ថុបាន ដូចជាកាប់បំផ្លាញដំណាំ វាយបំផ្លាញសំណង់ចាស់ចោល សំណង់ថ្មី ជាដើម។
- កិច្ចគតិយុត្ត ៖ កម្មសិទ្ធិករមានសិទ្ធិចុះលិខិតពាក់ព័ន្ធនិងអចលនវត្ថុរបស់ខ្លួនស្តីពី ការបង្កើតសិទ្ធិដូចជា សិទ្ធិជួល លក់ បញ្ចាំ ជាដើម។

យោងតាមការបកស្រាយខាងលើ កម្មសិទ្ធិករមានសិទ្ធិយ៉ាងទូលំទូលាយក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងបានដោយសេរីទៅលើទ្រព្យដែលជាកម្មសិទ្ធិករមិនមានលក្ខណៈសម្គាល់ទេ គេអាចនឹងភ័ន្តច្រឡំទៅជាទម្រង់មួយផ្សេងទៀតនៃកម្មសិទ្ធិគឺ "សេរភាព"។ ដោយ

[42] អ្នក ដែលបានចំណេញ ឬ បានកម្រៃពីវត្ថុណាមួយ ពីគុណប្រយោជន៍អ្វីមួយ ឬ ពីឯកសិទ្ធិណាមួយ ។

[43] សទ្ទានុក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

សារតែនៅក្នុងសេវភាព សិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ សម្រាប់ផលប្រយោជន៍ដីរបស់ខ្លួន ដោយយោងតាមគោលបំណងដែលបានកំណត់នៅក្នុងកិច្ចសន្យា។[44]

### ១.១.២. លក្ខណៈនៃកម្មសិទ្ធិ

ជាទូទៅ សិទ្ធិកម្មសិទ្ធិមានលក្ខណៈសំខាន់ៗបីរួមមាន ៖ កម្មសិទ្ធិជាសិទ្ធិផ្តាច់មុខ កម្មសិទ្ធិជាសិទ្ធិផ្តាច់ការ និង កម្មសិទ្ធិជាសិទ្ធិអចិន្ត្រៃយ៍។

#### ១.១.២.១. កម្មសិទ្ធិជាសិទ្ធិផ្តាច់មុខ

កម្មសិទ្ធិជាសិទ្ធិផ្តាច់មុខ មានន័យថា គឺមានតែកម្មសិទ្ធិករតែម្នាក់គត់ ដែលមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែង លើទ្រព្យរបស់ខ្លួនបាន ហើយអ្នកដទៃគ្មានសិទ្ធិទាមទារឡើយ ដោយកម្មសិទ្ធិអាចលក់ ដូរ ជួល បញ្ចាំ ឬធ្វើសន្តិកម្មនូវទ្រព្យរបស់ខ្លួនដោយសេរី។ ប៉ុន្តែក្នុងករណីមួយចំនួន កម្មសិទ្ធិករត្រូវបានកម្រិតសិទ្ធិដែរដូចជា៖

- ទ្រព្យមួយដែលមានម្ចាស់ច្រើនរួមគ្នា ដូចជាករណី កម្មសិទ្ធិអវិភាគ សហកម្មសិទ្ធិ៖ សិទ្ធិរបស់កម្មសិទ្ធិករនឹងត្រូវបានកម្រិត នៅក្នុងរណីកម្មសិទ្ធិអវិភាគដែលកម្មសិទ្ធិករមិនអាចប្រើប្រាស់ទ្រព្យរបស់ខ្លួនដោយផ្តាច់មុខបានទៀតទេ។ កម្មសិទ្ធិករមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនបានស្របតាមសមាមាត្រនៃចំណែកកម្មសិទ្ធិដែលខ្លួនមាននៅលើទ្រព្យនោះ ហើយកម្មសិទ្ធិករនោះ ត្រូវបានគេហៅថា កម្មសិទ្ធិករនៃទ្រព្យអវិភាគទៅវិញ។ ចំណែកនៅក្នុងករណីសហកម្មសិទ្ធិ កម្មសិទ្ធិករត្រូវបានកម្រិតសិទ្ធិក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងរបស់ខ្លួនទៅលើចំណែករួម ព្រោះនៅក្នុងអគារសហកម្មសិទ្ធិ មានចំណែកពីរនៅក្នុងនោះ គឺចំណែករួម និងចំណែកឯកជន ហើយការអនុវត្តសិទ្ធិរបស់ខ្លួនសហកម្មសិទ្ធិករទៅលើចំណែករួម គឺមិនខុសគ្នាពីការអនុវត្តទៅលើទ្រព្យអវិភាគរបស់កម្មសិទ្ធិករអវិភាគនោះទេ។
- ជញ្ជាំងអឌ្ឍសិទ្ធិ៖ ចំពោះជញ្ជាំងអឌ្ឍសិទ្ធិក៏ដូចជាគ្នាដែរ កម្មសិទ្ធិករមិនអាចប្រើប្រាស់ជញ្ជាំងអឌ្ឍសិទ្ធិដោយផ្តាច់មុខតែឯងបានទេ។ ព្រោះទ្រព្យនោះមិនមែនជាកម្មសិទ្ធិរបស់គាត់តែម្នាក់ទេ តាមការកំណត់របស់ច្បាប់លើកលែងតែកម្មសិទ្ធិករផ្សេងទៀត បោះបង់សិទ្ធិរបស់ខ្លួនលើជញ្ជាំងអឌ្ឍសិទ្ធិនោះ។ រាល់ការអនុវត្តសិទ្ធិរបស់កម្មសិទ្ធិករនៃជញ្ជាំងអឌ្ឍសិទ្ធិត្រូវបានកំណត់ដោយច្បាប់។[45]

---

[44] មាត្រា ២៨៥ ចំណុច១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[45] មាត្រា ២១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

- ផលុបភោគ៖ សំដៅទៅលើការប្រើប្រាស់និងអាស្រ័យផលនៃអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគីទេ។[46] ផលលុបភោគ អាចបង្កើតឡើងដោយច្បាប់ឬដោយកិច្ចសន្យា[47] ហើយបញ្ចប់នៅពេលមរណៈរបស់ផលុបភោគី ឬអាចបញ្ចប់ដោយកិច្ចសន្យា។[48] យោងតាមនិយមន័យខាងលើក្នុងករណី ផលុបភោគ កម្មសិទ្ធិករមិនមានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ អាស្រ័យផល ទៅលើទ្រព្យជាកម្មសិទ្ធិរបស់ខ្លួនបានទេ ដោយសារតែសិទ្ធិទាំងនោះត្រូវបានផ្តល់ទៅឱ្យផលុបភោគី។

### ១.១.២.២. កម្មសិទ្ធិជាសិទ្ធិផ្តាច់ការ

កម្មសិទ្ធិជាសិទ្ធិផ្តាច់ការ មានន័យថាកម្មសិទ្ធិករអាចធ្វើអ្វីបានគ្រប់យ៉ាងលើអចលនវត្ថុរបស់ខ្លួន ដូចជាការសាងសង់សំណង់អគារផ្សេងៗ លើកលែងតែករណីច្បាប់បានហាមឃាត់ ដូចជា ច្បាប់មិនឱ្យសាងសង់អគារខ្ពស់ៗនៅតំបន់ព្រលានយន្តហោះ ដើម្បីធានាសុវត្ថិភាពក្នុងការធ្វើចរាចរផ្លូវអាកាសឬច្បាប់មិនឱ្យសាងសង់រោងចក្រនៅតំបន់ទេសចរ ដើម្បីធានាការប្រើប្រាស់ដីស្របតាមប្លង់គោលរបស់រដ្ឋជាដើម។ សិទ្ធិផ្តាច់ការអាចត្រូវបានកម្រិតនៅក្នុងករណីមួយចំនួនដូចខាងក្រោម ៖

- ការប្រើប្រាស់ទ្រព្យផ្ទុយនឹងស្មារតីច្បាប់៖ ក្នុងករណីដែលកម្មសិទ្ធិករបានប្រើប្រាស់ទ្រព្យផ្ទុយពីគោលដៅដែលច្បាប់បានកំណត់ រដ្ឋក៏មានសិទ្ធិដកហូត ឬ ឃាត់ទុកទ្រព្យនោះដាក់ជាទ្រព្យសម្បត្តិសាធារណៈ ឬអាចបំផ្លាញចោល។
- ការដកហូតទ្រព្យតាមច្បាប់៖ ចំណុចនេះត្រូវបានចែងដោយមាត្រា៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ថា គ្មានបុគ្គលណាត្រូវបានដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនោះ មិនមែនសម្រាប់ប្រយោជន៍សាធារណៈ។ ទោះជាកម្មសិទ្ធិករមានសិទ្ធិផ្តាច់មុខ ហើយគាត់អាចធ្វើអ្វីៗបានគ្រប់យ៉ាងនៅលើទ្រព្យក៏ដោយ ក៏រដ្ឋនៅតែមានបុព្វសិទ្ធិទៅលើបុគ្គលនោះដែរ តែបុគ្គលដែលជាកម្មសិទ្ធិករត្រូវបានទទួលស្គាល់យុត្តិធម៌ ដូចជាករណីអស្សាមិករណ៍ជាដើម។[49]
- ការបង្កើតសេវភាពដើម្បីផលប្រយោជន៍អ្នកជិតខាង៖ សេវភាពគឺជាសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ សម្រាប់ផលប្រយោជន៍របស់ខ្លួន ដោយយោងតាមគោលបំណង។

---

[46] មាត្រា ២៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[47] មាត្រា ២៥៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[48] មាត្រា ២៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[49] មាត្រា ៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើត។ ដីអ្នកដទៃដែលផ្តល់ផលប្រយោជន៍របស់ "ដីប្រើ" រីឯដីដែលធ្វើឱ្យកើនផលប្រយោជន៍របស់ខ្លួនហៅថា "ដីប្រើ"។[50] ប៉ុន្តែសេវភាពដែលមានខ្លឹមសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈពុំអាចបង្កើតឡើងបានឡើយ។ ម្យ៉ាងទៀត សេវភាពអាចកើតឡើងពីធម្មជាតិកើតឡើងពីច្បាប់ ឬកើតឡើងពីការព្រមព្រៀង។[51] សេវភាពគឺជាករណីដែលកម្មសិទ្ធិករម្នាក់ត្រូវបាត់បង់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់គាត់ ដោយសារតែគាត់បានព្រមព្រៀងប្រគល់សិទ្ធិទាំងនោះទៅឱ្យកម្មសិទ្ធិករផ្សេងទៀត ឬក៏ច្បាប់បានកំណត់ថាគាត់ត្រូវបង្កើតសេវភាពតែម្តង។

### ១.១.១.៣. កម្មសិទ្ធិអចិន្ត្រៃយ៍

កម្មសិទ្ធិករជាសិទ្ធិអចិន្ត្រៃយ៍ គឺជាសិទ្ធិកម្មសិទ្ធិដែលកម្មសិទ្ធិករមានរួចហើយ។ ហើយមិនអាចបាត់បង់ទៅវិញដោយសារតែការកំណត់អាជ្ញាយុកាល ការទទួលមរណៈភាពរបស់កម្មសិទ្ធិករឬតាមរយៈការបង្ខិតបង្ខំ ការដកហូតពីបុគ្គលឯកជនណាមួយឡើយ។[52]

ដូចដែលបានបង្ហាញខាងលើរួចហើយនូវនិយមន័យ លក្ខណៈនិងការកម្រិតសិទ្ធិរបស់កម្មសិទ្ធករ។ ថ្វីត្បិតតែ កម្មសិទ្ធិករជាម្ចាស់កម្មសិទ្ធិ មានសិទ្ធិយ៉ាងទូលំទូលាយក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើទ្រព្យរបស់ខ្លួនក៏ដោយ ក៏នៅពេលខ្លះ សិទ្ធិទាំងនោះត្រូវបានកម្រិតដោយច្បាប់ដែរ គឺជាច្បាប់ធ្វើយ៉ាងណាដើម្បី ឱ្យការប្រើប្រាស់មានភាពសម្រាប់ផ្តល់ផលប្រយោជន៍ទាំងបុគ្គលជាកម្មសិទ្ធិករផង និងមិនប៉ះពាល់ផលប្រយោជន៍សាធារណៈផង។ នេះជាស្មារតីច្បាប់ ហើយជាក់ស្តែងមាត្រាមួយចំនួននៅក្នុងច្បាប់ភូមិបាល និងក្រមរដ្ឋប្បវេណីក៏បានចែងអំពីការកម្រិតសិទ្ធិនេះដែរ ដែលការកម្រិតសិទ្ធិកម្មសិទ្ធិទាំងនោះមានដូចជា ៖

- កម្មសិទ្ធិករនៃទ្រព្យមិនអាចប្រើប្រាស់ទ្រព្យនៅក្នុងគោលដៅព្យាបាទឬរំខានដល់តតិយជននិងជាពិសេសដល់អ្នកជិតខាងរបស់ខ្លួនឡើយ។[53]
- កម្មសិទ្ធិសំដៅទៅលើសិទ្ធិ ដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាននៅក្នុងទំហំដែលច្បាប់បានកម្រិត។[54]

---

[50] មាត្រា ២៨៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[51] ទំព័រ ៥៤ នៃសៀវភៅមេរៀនច្បាប់ភូមិបាល រៀបចំដោយ សាស្ត្រាចារ្យ ញឹក វ៉ាន់ អគ្គនាយក នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឆ្នាំ២០០៧

[52] ទំព័រ ៤៩ ឯកសារស្រាវជ្រាវនីតិរដ្ឋប្បវេណី រៀបរៀងដោយ សាស្ត្រាចារ្យ ញឹក វុទ្ធី

[53] មាត្រា ១៣៩ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- កម្មសិទ្ធិករមិនអាចទាមទារយកជាកម្មសិទ្ធិនូវបដិមារករ ចម្លាក់ក្រឡោត ឬ បុរាណវត្ថុគ្រប់ប្រភេទដែលបានរកឃើញ[55] ទោះជារកបាននូវលើដីកម្មសិទ្ធិរបស់ខ្លួនក៏ដោយ។

សរុបសេចក្តីមក កម្មសិទ្ធិករដែលជាម្ចាស់នៃទ្រព្យមានសិទ្ធិកម្មសិទ្ធិយ៉ាងទូលំទូលាយក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួន ប៉ុន្តែសិទ្ធិទាំងនោះត្រូវបានកម្រិតដោយច្បាប់ដែរនៅក្នុងករណីមួយចំនួន ហើយរាល់ការដកហូតទ្រព្យកម្មសិទ្ធិត្រូវធ្វើឡើងតាមនីតិវិធីច្បាប់ជាធរមាន មិនអាចធ្វើឡើងដោយបុគ្គលឯកជនណាមួយទេ។ បន្ថែមលើនេះទៀត កម្មសិទ្ធិទាំងអស់មានច្រើនសណ្ឋានណាស់ ព្រោះកម្មសិទ្ធិករម្នាក់ៗតែងតែមានទំនាក់ទំនងកម្មសិទ្ធិទៅវិញទៅមករហូតដល់បង្កើតបាននូវទម្រង់នៃកម្មសិទ្ធិដែលមានម្ចាស់កម្មសិទ្ធិច្រើនរួមគ្នា ហើយទម្រង់នេះក៏មានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១។

### ១.១.៣. ទម្រង់នៃកម្មសិទ្ធិ

យោងតាមបទប្បញ្ញត្តិនៅក្នុងមាតិកាទី៤នៃច្បាប់ភូមិបាលឆ្នាំ២០០១ ទម្រង់នៃកម្មសិទ្ធិមានបីប្រភេទគឺ ៖

- កម្មសិទ្ធិអវិភាគ
- សហកម្មសិទ្ធិ
- អឌ្ឍសិទ្ធិភាព

#### ១.១.៣.១. កម្មសិទ្ធិអវិភាគ

កម្មសិទ្ធិអវិភាគ គឺជាស្ថានភាពមួយដែល បុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើ ទ្រព្យតែមួយ។[56]

ចំណែកមាត្រា ២០២ នៃក្រមរដ្ឋប្បវេណីក៏បានឱ្យនិយមន័យកម្មសិទ្ធិអវិភាគមិនខុសពីនិយមន័យខាងលើនេះដែរ ដោយបញ្ញត្តិថាស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថា កម្មសិទ្ធិអវិភាគ។

តាមនិយមន័យទាំងពីរខាងលើ កម្មសិទ្ធិអវិភាគទៅលើទ្រព្យ គឺអាចមានចលនទ្រព្យនិងអចលនទ្រព្យ ហើយទ្រព្យនោះមិនអាចពុះចែកគ្នាបានទៀត។ តាមន័យនេះ មិនមែនមានន័យ

---

[54] មាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[55] មាត្រា ១៤១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[56] មាត្រា ២០២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ថាច្បាប់មិនអនុញ្ញាតឱ្យកម្មសិទ្ធិករអវិភាគពុះទ្រព្យចែកគ្នានោះទេ។ ប៉ុន្តែច្បាប់គ្រាន់តែចង់ការពារនូវទង្វើនៃការពុះចែកគ្នា ដែលនាំឱ្យទ្រព្យថយតម្លៃច្រើនឬនាំឱ្យខូចទ្រង់ទ្រាយដើមនៃទ្រព្យតែប៉ុណ្ណោះ។

កម្មសិទ្ធិអវិភាគ គឺជាសិទ្ធិផ្តាច់មុខ ព្រោះថាការប្រើប្រាស់ និងអាស្រ័យផលរបស់កម្មសិទ្ធិករអវិភាគត្រូវស្ថិតនៅព្រំដែន ដែលមិនប៉ះពាល់ដល់កម្មសិទ្ធិនៃកម្មសិទ្ធិករអវិភាគឯទៀតហើយរាល់ការចាត់ចែង ការផ្ទេរសិទ្ធិ ការបង្កើតភណ្ឌិក ឬ ការជួសជុលធំៗ ទៅលើទ្រព្យត្រូវមានការព្រមព្រៀងលើសពាក់កណ្តាលនៃកម្មសិទ្ធិករអវិភាគផ្សេងទៀតជាចាំបាច់។[57]

### ១.១.៣.២. សហកម្មសិទ្ធិ

សហកម្មសិទ្ធិ គឺជាទម្រង់មួយនៃកម្មសិទ្ធិដែលមានច្រើនបំផុតនៅក្នុងទីក្រុងជាពិសេសក្នុងករណីអគារមួយដែលមានម្ចាស់កម្មសិទ្ធិច្រើននាក់រួមគ្នា។

លក្ខខណ្ឌនៃអគារសហកម្មសិទ្ធិគឺមានដូចខាងក្រោម ៖

- ជាអចលនទ្រព្យ ទាំងដី ទាំងអគារ
- សហកម្មសិទ្ធិករច្រើននាក់ចាប់ពីពីរនាក់ឡើងទៅ
- ឡូត៍ដែលមានចំណែកឯកជន និង ចំណែករួម

ជាធម្មតាពាក្យ សហ គឺសំដៅទៅលើអ្វីៗ ដែលជាចំនួនពហុវចនៈ គឺរាប់ចាប់ពីពីរឡើងទៅ ហើយសហកម្មសិទ្ធិករក៏មានន័យមិនខុសពីនេះដែរ។ អគារសហកម្មសិទ្ធិត្រូវតែមានសហ-កម្មសិទ្ធិចាប់ពីពីរនាក់ឡើងទៅទើបអាចចាត់ទុកថា នេះជាអគារសហកម្មសិទ្ធិបាន។ បើអគារនោះមានកម្មសិទ្ធិករតែម្នាក់ អគារនោះគ្រាន់តែជាអគារកម្មសិទ្ធិផ្តាច់មុខធម្មតាតែប៉ុណ្ណោះទោះជាអគារមានចំនួនច្រើនជាន់យ៉ាងណាក៏ដោយ។

ចំពោះលក្ខខណ្ឌចុងក្រោយរបស់អគារសហកម្មសិទ្ធិ គឺជាឡូត៍ដែលមានចំណែកឯក-ជននិងចំណែករួម។ ចំណែកឯកជន គឺជាចំណែកដែលអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដោយផ្តាច់មុខ ដោយសហកម្មសិទ្ធិករណាម្នាក់រីឯចំណែករួម គឺជាទ្រព្យរួមរបស់សហកម្មសិទ្ធិករទាំងអស់មិនអាចឱ្យសហកម្មសិទ្ធិករណាម្នាក់ប្រើប្រាស់តែឯងបានឡើយ។ ចំណែករួម និងចំណែកឯកជនមានលក្ខណៈដោយឡែកពីគ្នាដូចម្តេចខ្លះ? ហើយសហកម្មសិទ្ធិករមានសិទ្ធិនិងកាតព្វ-កិច្ចអ្វីខ្លះនៅលើចំណែករួមនិងចំណែកឯកជន? នៅក្នុងផ្នែកទី២ នៃជំពូកទី១ នេះលោកអ្នកនឹងបានដឹងអំពីលក្ខណៈនៃចំណែករួមនិងចំណែកឯនជន ហើយទាក់ទងទៅនឹងសិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករលើចំណែកទាំងពីរនេះ។ ប៉ុន្តែនៅចំណុចបន្ទាប់

[57] មាត្រា ២០៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

លោកអ្នកនឹងស្វែងយល់នូវទម្រង់ចុងក្រោយនៃកម្មសិទ្ធិ ដែលជាសហកម្មសិទ្ធិនោះ គឺ "អឡ្ឍសិទ្ធិភាព" ។

### ១.១.៣.៣. អឡ្ឍសិទ្ធិភាព

អឡ្ឍសិទ្ធិភាព គឺជាទម្រង់នៃកម្មសិទ្ធិរួមអនុវត្តទៅលើជញ្ជាំងនិងកំពែងដែលនៅត្រង់ព្រំខណ្ឌចែកកម្មសិទ្ធិពីជាប់គ្នា។ កំពែងគឺសំដៅទៅលើស្នាមភ្លោះ របង និងភ្លឺ។[58] ម្យ៉ាងវិញទៀត មាត្រា ២១៥ នៃក្រមរដ្ឋប្បវេណី បានចែងថា ស្ថានភាពដែលជនដែលមានកម្មសិទ្ធិលើដីជាប់គ្នាមានកម្មសិទ្ធិរួមដោយមានភាពអវិជ្ជមានជញ្ជាំង ឬកំពែងដូចជា ស្នាមភ្លោះ ភ្លឺ របស់ជាដើម ដែលនៅត្រង់ព្រំខណ្ឌដី ឬអគារលើដីនោះ ហៅថា អឡ្ឍសិទ្ធិភាព។

អឡ្ឍសិទ្ធិភាពកើតមានឡើង នៅពេលដែលមានកម្មសិទ្ធិលើដីជាប់គ្នា មានកម្មសិទ្ធិរួមដោយមានភាពអវិភាគលើជញ្ជាំង ឬកំពែងដូចជាស្នាមភ្លោះ ភ្លឺ របងជាអាទិ៍ ដែលនៅត្រង់ព្រំខណ្ឌដីឬអគារលើដីនោះ។[59] បញ្ហានៃសិទ្ធិប្រើប្រាស់និងការទទួលការខុសត្រូវលើការថែទាំទ្រព្យអឡ្ឍសិទ្ធិ មានលក្ខណៈដូចគ្នានិងសិទ្ធិប្រើប្រាស់និងការទទួលខុសត្រូវចំពោះចំណែករួមនៅក្នុងទ្រព្យសហកម្មសិទ្ធិដែរ។[60] ប៉ុន្តែសិទ្ធិនិងកាតព្វកិច្ចលើទ្រព្យអឡ្ឍសិទ្ធិខុសពីទ្រព្យសហកម្មសិទ្ធិត្រង់ថាជញ្ជាំង និងភ្លឺត្រូវបានកំណត់ដោយច្បាប់មិនមែនដោយកិច្ចសន្យាទេ។ ហើយអឡ្ឍសិទ្ធិភាពចាំបាច់មានអង្គការគ្រប់គ្រង ឬបទបញ្ជាណាមួយសម្រាប់យកទៅគ្រប់គ្រងឬប្រើប្រាស់ដែរ។ កម្មសិទ្ធិករម្នាក់ៗទទួលខុសត្រូវលើការជួសជុលនិងសាងសង់ជញ្ជាំងអឡ្ឍសិទ្ធិទៅតាមសមាមាត្រនៃសិទ្ធិកម្មសិទ្ធិរបស់ពួកគេ។[61]

កម្មសិទ្ធិករ នៃអឡ្ឍសិទ្ធិអាចសាងសង់បន្ថែមកម្ពស់ជញ្ជាំងអឡ្ឍសិទ្ធិដោយចេញថ្លៃពាក់កណ្តាលនៃថ្លៃដីដែលសង់ជញ្ជាំងពីលើនេះ។ ដូចគ្នានេះដែរ កម្មសិទ្ធិករក៏អាចរួតផុតពីបន្ទុកនៃការបង់សោហ៊ុយបានដែរ ដោយគ្រាន់តែលះបង់អឡ្ឍសិទ្ធិរបស់ខ្លួន។ ប៉ុន្តែបញ្ញត្តិចុងក្រោយនេះ មិនអាចយកមកអនុវត្តចំពោះជញ្ជាំងទល់ទ្រអគារ ដែលជារបស់គាត់នោះទេ។ មានន័យថា កម្មសិទ្ធិមិនអាចលះបង់សិទ្ធិអឡ្ឍសិទ្ធិដែលជាជញ្ជាំងទល់ទ្រអគារជាកម្មសិទ្ធិរបស់គាត់នោះទេ បើគាត់លះបង់ គឺប្រៀបដូចជាលះបង់កម្មសិទ្ធិរបស់ខ្លួនទៅឱ្យអ្នកដទៃដែរ។

---

[58] មាត្រា ២១៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[59] ទំព័រទី ៦១ នៃសៀវភៅមេរៀនច្បាប់ភូមិបាល រៀបចំដោយឯកឧត្តម លឹម វ៉ាន់ អគ្គនាយក នៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ ឆ្នាំ ២០០៧

[60] ទំព័រទី ១០៩ នៃសៀវភៅសិក្សានិងស្រាវជ្រាវ ច្បាប់ភូមិបាលកម្ពុជា រៀបចំដោយអង្គការ EWMI ឆ្នាំ២០០៣

[61] មាត្រា ២១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទាក់ទងនឹងអគារអឡ្ឌសិទ្ធិភាព គឺមានលក្ខណៈប្រហាក់ប្រហែលទៅនឹងកម្មសិទ្ធិលើចំណែករួមនៃសហកម្មសិទ្ធិដែរ គឺរាល់ការប្រើប្រាស់ ឬការជួសជុលផ្សេងៗ ត្រូវមានការព្រមព្រៀងពីកម្មសិទ្ធិករនៃអឡ្ឌសិទ្ធិម្ខាងទៀត ហើយក្នុងករណីខ្លះច្បាប់បានកំណត់កម្រិតនូវសិទ្ធិរបស់សហកម្មសិទ្ធិករតែម្តង។

## ១.២.អគារសហកម្មសិទ្ធិ

### ១.២.១ និយមន័យនៃអគារសហកម្មសិទ្ធិ

អគារសហកម្មសិទ្ធិ សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះ ជាកម្មសិទ្ធិផ្តាច់មុខ របស់សហកម្មសិទ្ធិនីមួយៗ ហៅថា "ចំណែកឯកជន" និង មានចំណែកខ្លះជាហូរហែរសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅ"ចំណែករួម"។[62]តើចំណែករួម និងចំណែកឯកជនមានអ្វីខ្លះ? ហើយកម្ម-សិទ្ធិករនិងកាតព្វកិច្ចអ្វីខ្លះនៅលើចំណែកទាំងនោះ?

#### ១.២.១.១. លក្ខណៈនៃចំណែកឯកជន

ចំណែកឯកជន សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់ជាឯកជនផ្តាច់មុខ។[63] ចំណែកឯនជននេះ គឺមានសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងកាន់កាប់ឬប្រើប្រាស់ ផ្តាច់មុខនូវចំណែកនេះដោយកម្មសិទ្ធិករនីមួយៗ ត្រូវមានវិញ្ញាបនបត្រមួយសម្រាប់សម្គាល់ភាពជាកម្មសិទ្ធិតាមលក្ខណៈច្បាប់ដែលក្នុងនោះមានបញ្ជាក់ពីប្រភេទនិងទំហំចំណែកកម្មសិទ្ធិឯកជនរបស់ខ្លួន។ ដើម្បីទទួលបាននូវប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិនោះ។ កម្មសិទ្ធិករម្នាក់ៗត្រូវចុះបញ្ជីនៅក្នុងរដ្ឋបាលសុរិយោដីដែលជាស្ថាប័នមានសមត្ថកិច្ចតែមួយគត់ក្នុងការទទួលចុះបញ្ជី។

ការកំណត់ប្រភេទ ទំហំ ឬព្រំខណ្ឌរបស់ចំណែកឯកជន គឺមានសារៈសំខាន់ណាស់។ ដោយយោងតាមមាត្រា៩ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិបានបញ្ញត្តិពីការកំណត់ព្រំខណ្ឌសំខាន់ៗ មួយចំនួនថា "ការកំណត់ព្រំខណ្ឌចំណែកឯកជនដែលមានជញ្ជាំងអឡ្ឌសិទ្ធិ ត្រូវបានកំណត់ត្រឹមពាក់កណ្តាលនៃកម្រាស់ជញ្ជាំងដែលខណ្ឌចំណែកឯកជននីមួយៗ។ យ៉ ឬរានហាលជាប់ជាមួយចំណែកឯកជន និងប្រើប្រាស់ចំណែកឯកជន ហើយមិនប៉ះពាល់ដល់ការប្រើប្រាស់ជារួមរបស់សហកម្មសិទ្ធិផ្សេងទៀត

[62]មាត្រា ៤ ចំណុច ១ នៃ អនុក្រឹត្យ ១២៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ឆ្នាំ ២០០៩

[63] មាត្រា ៤ ចំណុច ២ នៃ អនុក្រឹត្យ ១២៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ឆ្នាំ ២០០៩

ត្រូវចាត់ទុកជាផ្នែកឯកជន។″ មានន័យថា ចំណែកឯកជនដែលមានខណ្ឌចែកដោយជញ្ជាំងអឌ្ឍ-សិទ្ធិ គឺត្រូវបានកំណត់ព្រំខណ្ឌនៅត្រង់ចំណុចពាក់កណ្ដាលនៃកម្រាស់ជញ្ជាំងនោះ ហើយចំពោះយ៉ ឬរានហាល ដែលនៅជាប់នឹងចំណែកឯកជន និងប្រើប្រាស់ជាឯកជនត្រូវចាប់ទុកជាចំណែកឯកជនរបស់សហកម្មសិទ្ធិដែលមានសិទ្ធិលើចំណែកឯកជននោះ។

ចំណែកដែលនៅសល់ពីចំណែកឯកជននៃអគារសហកម្មសិទ្ធិ គឺត្រូវបានចាត់ទុកថាជា″ចំណែករួម″ទាំងអស់។ តើអ្វីខ្លះដែលត្រូវចាត់ទុកជាចំណែករួម ហើយចំណែករួមខុសពីចំណែកឯកជនដូចម្ដេចខ្លះ?

### ១.២.១.២. លក្ខណៈនៃចំណែករួម

ចំណែករួម សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលត្រូវចាត់ទុកថាជាកម្មវត្ថុសម្រាប់ប្រើប្រាស់ឬជាផលប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្ដើរ ឧទ្យាន និងសួនច្បារ ផ្លូវច្រកចេញចូល ជញ្ជាំងអឌ្ឍសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម។[64]

ជាមួយគ្នានេះដែរ មាត្រា១២ នៃអនុក្រឹត្យដដែល ក៏បានចែងបន្ថែមដើម្បីជាការបំពេញទៅលើមាត្រា៤ ខាងលើនេះថា រាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់រួម ឬសម្រាប់ជាប្រយោជន៍នៃសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិបង្កើតបានជាចំណែករួមដែលមានដូចជា

- ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវច្រកចេញចូល
- ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗ នៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្ដាញ ទឹក ភ្លើង បណ្ដាញឧស្ម័ន ប្រព័ន្ធលូទឹកស្អុយ ដែលអាចឆ្លងកាត់ចំណែកឯកជន
- ទូរួម បំពង់ និងក្បាលបំពង់ផ្សេងនិងដំបូល
- ទីកន្លែងសេវារួមផ្សេងៗ ដែលបានកំណត់ដោយឡែក ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុង
- សិទ្ធិបន្ទាប់បន្សំទាំងឡាយដូចមានចែងក្នុងមាត្រា១៧៩ នៃច្បាប់ភូមិបាល។

សហកម្មសិទ្ធិករនីមួយៗ មានត្រឹមតែសិទ្ធិប្រើប្រាស់តែប៉ុណ្ណោះ លើចំណែករួម។ គ្មានករណីណាមួយដែលកម្មសិទ្ធិករអគារសហកម្មសិទ្ធិជាន់លើបំផុត អាចបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬ លក់សិទ្ធិនៃការលើកបន្តនេះបានឡើយ។ រីឯសិទ្ធិបន្ទាប់បន្សំ ដែលបានលើកឡើងខាងលើនៅក្នុងច្បាប់ភូមិបាល ត្រង់មាត្រា ១៧៩ មានដូចជា ៖

- សិទ្ធិជីករុករកវត្ថុធាតុដើមដែលមានក្នុងដី
- សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យាន ឬសួនច្បារដែលជាចំណែករួម

---

[64] មាត្រា ៤ ចំណុច ៣ នៃអនុក្រឹត្យ ១២៦ ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ឆ្នាំ ២០០៩

- សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យាន ឬ សត្វច្បារទាំងនោះ
- សិទ្ធិនៃអឌ្ឍសិទ្ធិភាពដែលជាប់និងចំណែករួមទាំងឡាយ
- សិទ្ធិលើកបន្តឱ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើនបង្កើតបានជាចំណែកឯកជនផ្សេងគ្នា។

ចំណែករួមនៃអគារសហកម្មសិទ្ធិ គឺជាច្រើនដូចដែលបានលើកឡើងខាងលើនេះស្រាប់ហើយគួរបញ្ជាក់ផងដែរថា ចំណែករួមមិនមែនសុទ្ធ តែសម្រាប់ការប្រើប្រាស់រួម នៅលើអគារសហកម្មសិទ្ធិទាំងមូលទេ ដោយតែបម្រើផលប្រយោជន៍រួមរបស់សហកម្មសិទ្ធិនេះ គឺមានលក្ខណៈរួមដូចទៅនឹងកម្មសិទ្ធិអវិភាគ ដែលបានបកស្រាយខាងលើ ថាជាកម្មសិទ្ធិទៅលើទ្រព្យតែមួយរបស់បុគ្គលច្រើននាក់ ហើយទ្រព្យនោះមិនអាចពុះចែកគ្នាបានទេដោយជៀសវាងការថយតម្លៃ ឬ ធ្វើឱ្យខូចទ្រង់ទ្រាយដើមនៃទ្រព្យនោះ នោះមានន័យថា ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ។[65]

### ១.២.២. ប្រភេទនៃអគារសហកម្មសិទ្ធិ

#### ១.២.២.១. ប្រភពគតិយុត្ត

ប្រភពគតិយុត្តនៃអគារសហកម្មសិទ្ធិកើតឡើងតាមការកំណត់របស់ច្បាប់។ ករណីដែលគេបានជួបប្រទះជាញឹកញាប់ជាងគេ គឺទាក់ទាញនឹងសន្តតិកម្ម ដែលបង្កើតឱ្យមានការផ្ទេរសិទ្ធិដោយស្របច្បាប់។ ប៉ុន្តែដោយសារសន្តតិកម្មមានពីរប្រភេទគឺ សន្តតិកម្មតាមច្បាប់និងសន្តតិកម្មមានបណ្ដាំ (កើតពីឆន្ទៈរបស់មរតកជន)។[66]ដោយឡែក នៅក្នុងចំណុចនេះសន្តតិកម្មក្នុងករណីគ្មានឆន្ទៈនឹងត្រូវបានយកមកពិភាក្សា ដោយសារតែករណីនេះត្រូវបានគ្រប់គ្រងដោយច្បាប់។

សន្តតិកម្ម កើតឡើងបានលុះត្រាតែមានមរណភាពរបស់មរតកជន ហើយបន្តមត៌កគឺត្រូវទទួលយកទាំងសិទ្ធិនិងកាតព្វកិច្ចតាមសមាមាត្រនៃមរតកនោះ។ ជាធម្មតា បើមរតកនោះកើតនៅអគារ ចំណែកដែលសហកម្មសន្តតិកជនទទួលបានគឺជាចំណែកដែលអាចបែងចែកបាន និងចំណែកដែលមិនអាចបែងចែកបានហៅថា កម្មសិទ្ធិអវិភាគរបស់សហសន្តតិជន។ ចំណុចនេះគឺជាការកំណត់របស់ច្បាប់ ហើយវាកើតឡើងជាស្វ័យប្រវត្តិនៅពេលមានមរណភាពដោយបានបន្សល់ទុកនូវអគារជាមរតក និងសហសន្តតិជនជាអ្នកទទួលបន្តនូវមរតកនោះនាំឱ្យកើតមានអគារសហកម្មសិទ្ធិ។

---

[65] មាត្រា ១៤ វាក្យខណ្ឌ១ ១ នៃអនុក្រឹត្យ ១២៦ ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ឆ្នាំ ២០០៩

[66] មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

#### ១.២.២.២. ប្រភពឆន្ទៈ

ប្រភពនៃអគារសហកម្មសិទ្ធិដែលកើតឡើងតាមឆន្ទៈបុគ្គល គឺជាអគារសហកម្មសិទ្ធិដែលកើតឡើងតាមកិច្ចព្រមព្រៀងរបស់សហកម្មសិទ្ធិករ ហើយការព្រមព្រៀងនេះមានទម្រង់ជាកិច្ចសន្យា។ កិច្ចសន្យាភាគច្រើនដែលគេតែងតែជួបប្រទះរួមមាន ប្រទានកម្ម កិច្ចសន្យាលក់ទិញ កិច្ចសន្យាដូរ ដែលជានិច្ចជាកាល បង្កើតឱ្យមានការផ្ទេរសិទ្ធិ។

ទាក់ទងនិងប្រទានកម្មនិយមន័យរបស់វាត្រូវបានកំណត់ដោយមាត្រា៥៦៨ នៃក្រមរដ្ឋប្បវេណីថា ប្រទានកម្មសំដៅ ទៅលើកិច្ចសន្យាមួយដែលត្រូវមានអនុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។ ម្យ៉ាងទៀត ប្រទានកម្ម គឺជាបុព្វហេតុមួយដែលឱ្យកើតមាននូវសហកម្មសិទ្ធិទៅលើអគារ។ ហេតុនេះហើយបានជាសហកម្មសិទ្ធិករម្នាក់ៗ ត្រូវមានសិទ្ធិកាត- ព្វកិច្ចនិងការទទួលខុសត្រូវរួមទៅលើចំណែកដែលមិនអាចបែងចែកបាន ទន្ទឹមនឹងមានសិទ្ធិផ្តាច់មុខទៅចំណែកឯកជនរបស់ខ្លួន។

រាល់ប្រទានកម្ម កិច្ចសន្យាលក់ទិញ សុទ្ធតែបង្កើតឱ្យមានការផ្ទេរសិទ្ធិ ហើយវាកើតពីឆន្ទៈរបស់សហកម្មសិទ្ធិករ ពិសេសទៅលើអគារ ដែលបង្កើតឱ្យមាននូវអគារសហកម្មសិទ្ធិ។

## ជំពូកទី២៖ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ

### ២.១. សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរ

#### ២.១.១. សិទ្ធិរបស់សហកម្មសិទ្ធិករ

សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ មានសិទ្ធិសំខាន់ៗចំនួនពីរ តបនឹងភាពជាម្ចាស់កម្មសិទ្ធិរៀងៗខ្លួននៅក្នុងអគារសហកម្មសិទ្ធិមួយគឺ សិទ្ធិកម្មសិទ្ធិ និងសិទ្ធិគ្រប់គ្រង។ ដូចដែលបានបង្ហាញរួចមកហើយអំពីនិយមន័យនៃកម្មសិទ្ធិនៅក្នុងជំពូកទី១ ខាងលើដែលសិទ្ធិបានបើកឱ្យកម្មសិទ្ធិករទទួលបាននូវបុព្វសិទ្ធិនៃកម្មសិទ្ធិទាំង៣ គឺសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែង ហើយក៏បានសិក្សាផងដែលអំពីលក្ខណៈនៃបុព្វសិទ្ធិនៃកម្មសិទ្ធិទាំង៣នេះ។ ប៉ុន្តែបញ្ហាសំខាន់នោះ តើកម្មសិទ្ធិ និងសិទ្ធិគ្រប់គ្រងទាំងពីរខាងលើមានលក្ខណៈដូចម្តេចខ្លះនៅលើចំណែករួម និងចំណែកឯកជន? ហើយរវាងសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរ និងសហកម្មសិទ្ធិករជាជនបរទេសមានភាពខុសគ្នាដែរឬទេ? ម្យ៉ាងវិញទៀត តើសហកម្មសិទ្ធិករនីមួយៗនឹងទទួលបានសិទ្ធិជាកម្មសិទ្ធិលើចំណែករបស់គាត់

យ៉ាងណា? ហើយគាត់នឹងទទួលបានសិទ្ធិគ្រប់គ្រងទៅលើអគារ និងចំណែកដែលជាកម្មសិទ្ធិផ្តាច់មុខរបស់គាត់ក៏ដូចជាចំណែកនៃកម្មសិទ្ធិរួមយ៉ាងដូចម្តេច?

### ២.១.១.១. សិទ្ធិកម្មសិទ្ធិ

សិទ្ធិកម្មសិទ្ធិចែកចេញជាសិទ្ធិសំខាន់ៗ៣ គឺសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែង។ ដោយសារអគារសហកម្មសិទ្ធិ គឺជាអចលនទ្រព្យ ដូចនេះសហកម្មសិទ្ធិករត្រូវតែជាបុគ្គលមានសមត្ថភាពតាមផ្លូវច្បាប់ មានន័យថាគាត់ត្រូវតែជានីតិជន និងមានការយល់ដឹងខាងឆន្ទៈ ហើយត្រូវបានកម្រិតចំពោះជនបរទេស។[67]ប៉ុន្តែទោះជាយ៉ាងណាក៏ដោយករណីខាងលើក៏ត្រូវ បានលើកលែងដែរ ចំពោះការបន្តមរតករបស់ទាយាទដែរជាអនីតិជន ឬអសមត្ថជនដោយអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិបានត្រូវតែមានអាណាព្យាបាល ឬហិតូបត្ថម្ភកៈជាអ្នកកាន់កាប់ជំនួសរហូតដល់អនីតិជន ឬជនអសមត្ថភាពនោះមានសមត្ថភាពពេញលេញតាមផ្លូវច្បាប់វិញ ហើយក្នុងករណីនេះអាណាព្យាបាល ឬហិតូបត្ថម្ភកៈគ្មានសិទ្ធិចាត់ចែងចំណែកឯកជននោះបានឡើយលើកលែងតែមានការអនុញ្ញាតពីតុលាការ។

សិទ្ធិកម្មសិទ្ធិផ្តាច់មុខមានតែនៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិទេ ហើយសិទ្ធិកម្មសិទ្ធិត្រូវគោរពតាមលក្ខខណ្ឌបញ្ញត្តិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួន។ កម្មសិទ្ធិករអាចប្រើប្រាស់ អាស្រ័យផល ចាត់ចែងបានដោយសេរីនៅលើអគារដែលជាកម្មសិទ្ធិរបស់ខ្លួន តែត្រូវគោរពនូវលក្ខខណ្ឌមួយគឺ អាចធ្វើបាននៅលើចំណែកឯកជនទេ (មិនប៉ះពាល់ចំណែករួម ឬចំណែកឯកជនរបស់សហកម្មសិទ្ធិករដទៃទេ)[68]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយវាត្រូវបានកម្រិតលក្ខខណ្ឌដោយច្បាប់ឬបញ្ញត្តិផ្សេងទៀតដែរ ដូចជាមាននៅក្នុងមាត្រា១០នៃអនុក្រឹត្យ ១២៦ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិថា សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួន លើកលែងតែមានការកម្រិតលក្ខខណ្ឌដោយច្បាប់ ឬបញ្ញត្តិផ្សេងទៀត។ ជាក់ស្តែងមាត្រា១១ នៃអនុក្រឹត្យដដែល បានកម្រិតនូវសិទ្ធិចាត់ចែងរបស់សហកម្មសិទ្ធិករនៃ អគារសហកម្មសិទ្ធិពោលគឺ សហកម្មសិទ្ធិករនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានសិទ្ធិចាត់ចែងលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួម ដោយសហកម្មសិទ្ធិករដទៃទៀត និងធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំនៃសំណង់ និងសោភ័ណភាពនៃអគារ។ សិទ្ធិចាត់ចែងចំណែកឯកជនរបស់សហកម្មសិទ្ធិករ ដូចជាការលក់ ការដូរ ការជួលប្រទានកម្ម ការបន្តមរតក

---

[49] មាត្រា ៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] មាត្រា ១៧៧ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

ការជួលអចិន្ត្រៃយ៍ ការបង្កើតផលុបភោគ ការប្រើប្រាស់ និងអាស្រ័យនៅ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន តែសហកម្មសិទ្ធិករមិនអាចបង្កើតសេវភាពលើចំណែកឯកជនរបស់ខ្លួនបានទេ។

សេវភាពកើតមានសម្រាប់ជាប្រយោជន៍ដល់អចលនវត្ថុដែលជារបស់សហកម្មសិទ្ធិករផ្សេងទៀត ប៉ុន្តែក្នុងអគារសហកម្មសិទ្ធិគ្មានដីបម្រើ ឬដីប្រើទេគឺសហកម្មសិទ្ធិករទាំងអស់មានសិទ្ធិដូចៗគ្នាលើចំណែកនីមួយៗ និងលើទ្រព្យរួមទាំងមូល។ ដូច្នេះមិនអាចមានសេវភាពលើចំណែកឯកជនបានទេ ព្រោះថាបើបង្កើតឱ្យមានសេវភាពមានន័យថា "កម្មសិទ្ធិករដែលបង្កើតសេវភាពលើដីរបស់ខ្លួនត្រូវបានចាត់ទុកថា យល់ព្រមរាល់អ្វីដែលចាំបាច់សម្រាប់សេវភាពនោះ ដូចសេវភាពនៃការយកទឹកបង្កើតឡើង នៅកន្លែងប្រភពទឹកអនុញ្ញាតឱ្យអ្នកយកទឹកមានសិទ្ធិឆ្លងកាត់ដីដែលមានប្រភពទឹកនោះ។"

នៅលើចំណែករួមសហកម្មសិទ្ធិករអាចប្រើប្រាស់ និងអាស្រ័យផលបាន ប៉ុន្តែសហកម្មសិទ្ធិករមិនអាចចាត់ចែងបានទេ មានន័យថាសហកម្មសិទ្ធិករអាចប្រើប្រាស់ទីធ្លា ឧទ្យាន សួនច្បារ និងផ្លូវច្រកចេញចូលបាន ប៉ុន្តែសហកម្មសិទ្ធិករមិនអាចលក់ដូរ ឬជួលទីធ្លាដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ ជាក់ស្តែងដូចដែលបានបង្ហាញម្តងរួចមកហើយត្រង់ វាក្យខណ្ឌ១ កថាខណ្ឌចុងក្រោយនៃមាត្រា១២ នៃអនុក្រឹត្យ១២៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិដែលបានចែងថា "សហកម្មសិទ្ធិករនីមួយៗមានត្រឹមតែសិទ្ធិប្រើប្រាស់តែប៉ុណ្ណោះលើចំណែករួម" ហើយមាត្រា១៤ នៃអនុក្រឹត្យដដែលបានបញ្ញត្តិថា "សហកម្មសិទ្ធិករទាំងអស់ត្រូវធានាថែទាំចំណែករួម។ បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង"។

### ២.១.១.២. សិទ្ធិគ្រប់គ្រង

បន្ថែមទៅលើសិទ្ធិកម្មសិទ្ធិ ដែលកម្មសិទ្ធិករនីមួយៗមាននៅលើអគារសហកម្មសិទ្ធិដែលជាកម្មសិទ្ធិរបស់ខ្លួន កម្មសិទ្ធិករក៏នៅមានសិទ្ធិមួយទៀតដែលសំខាន់នោះគឺ "សិទ្ធិគ្រប់គ្រង"។ សិទ្ធិគ្រប់គ្រងនេះ សំដៅទៅលើសិទ្ធិនៃការចូលរួមចំណែកគ្រប់គ្រងអគារសហកម្មសិទ្ធិទាំងមូលរបស់សហកម្មសិទ្ធិករទាំងអស់។

ដើម្បីធានានូវការគ្រប់គ្រងឱ្យបានល្អទៅលើអគារសហកម្មសិទ្ធិ ត្រូវមានការគ្រប់គ្រងជាលាយលក្ខអក្សរពីសហកម្មសិទ្ធិករទាំងអស់ ហើយការព្រមព្រៀងនោះត្រូវស្របនឹងបទដ្ឋានគតិយុត្តមួយដែលត្រូវបានគេហៅថា បទបញ្ជាផ្ទៃក្នុង។ បន្ថែមលើនេះទៅទៀត សហកម្មសិទ្ធិ

ករអាចបង្កើតអង្គការគ្រប់គ្រង ដែលអាចជាក្រុមប្រឹក្សាភិបាល ឬ/និងគណៈកម្មការគ្រប់គ្រង ដើម្បីទទួលកិច្ចការសហកម្មសិទ្ធិ។ [69]

### ២.១.២. កាតព្វកិច្ច និងការទទួលខុសត្រូវ

សិទ្ធិ និងកាតព្វកិច្ចគឺជាកត្តាដ៏សំខាន់ ដែលត្រូវតែមានទំនាក់ទំនងគ្នាជានិច្ច។ ទន្ទឹម នឹងសិទ្ធិមួយចំនួនដែលសហកម្មសិទ្ធិករមានទៅលើអគារសហកម្មសិទ្ធិរបស់ខ្លួន សហកម្មសិទ្ធិករទាំងនោះក៏ត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវផងដែរ ដើម្បីចូលរួមថែរក្សាអគារសហកម្មសិទ្ធិឱ្យបានល្អ។

កាតព្វកិច្ចដំបូងរបស់សហកម្មសិទ្ធិករ គឺត្រូវគោរពបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រង និងថែទាំអគារសហកម្មសិទ្ធិ ដែលមានបញ្ជាក់ក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រង និងវិធានការនៃការថែទាំព្រមទាំងបំពេញកាតព្វកិច្ចផ្សេងទៀត។ ជាធម្មតានៅក្នុងអគារសហកម្មសិទ្ធិនីមួយៗត្រូវតែមានបទបញ្ជាផ្ទៃក្នុងមួយ ដែលនៅក្នុងនោះមានចែងអំពីសិទ្ធិ និងកាតព្វកិច្ច ការទទួលខុសត្រូវ ការចាត់ចែង និងការគ្រប់គ្រងអគារសហកម្មសិទ្ធិ។ បទបញ្ជាផ្ទៃក្នុងនោះ ត្រូវបានទទួលនូវការព្រមព្រៀងពីសហកម្មសិទ្ធិករទាំងអស់នៅពេលគាត់ទទួលយកចំណែកឯកជន មកធ្វើជាកម្មសិទ្ធិរៀងៗខ្លួន ដូច្នេះគាត់ត្រូវតែគោរពនូវលិខិតបទដ្ឋានគតិយុត្តនោះ ដើម្បីការគ្រប់គ្រងឱ្យបានល្អ។

ដើម្បីធានាដល់ការប្រើប្រាស់អគារសហកម្មសិទ្ធិឱ្យបានល្អ សហកម្មសិទ្ធិករទាំងអស់ត្រូវធានាថែទាំចំណែករួម ហើយបន្ទុកនៃការថែទាំនេះត្រូវចែកគ្នាទៅតាម សមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង។[70] ចំពោះចំណែកឯកជន សហកម្មសិទ្ធិករមានសិទ្ធិសម្រេចថែទាំ ឬមិនថែទាំទៅលើចំណែកឯកជនរបស់ខ្លួន ឱ្យតែមិនប៉ះពាល់ដល់ចំណែករួមដាច់ខាត សហកម្មសិទ្ធិករត្រូវថែទាំ ហើយទំហំនៃការអនុវត្តកាតព្វកិច្ចនេះ គឺអាស្រ័យតាមសមាមាត្រនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករនោះ។

---

[51] មាត្រា៨ កថាខណ្ឌ៣ នៃអនុក្រឹត្យ១២៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អាគារសហកម្មសិទ្ធិ ឆ្នាំ ២០០៩

[52] មាត្រា១៤ វាក្យខណ្ឌ២ និងវាក្យខណ្ឌ៣ នៃអនុក្រឹត្យ ១២៦ ស្តីពីការគ្រប់គ្រង និង ប្រើប្រាស់អាគារសហកម្មសិទ្ធិ ឆ្នាំ២០០៩

ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងនូវមហន្តរាយដោយប្រការណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុល ឬសាងសង់ឡើងវិញ ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃឡូត៍នីមួយៗ ឬតាមការព្រមព្រៀងគ្នាកន្លងមកដូចជា កិច្ចសន្យាដោយឡែក ឬបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ។[71] កិច្ចសន្យាដោយឡែកនេះ ត្រូវតែស្របតាមស្មារតី នៃបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិនីមួយៗ។

សហកម្មសិទ្ធិករត្រូវទទួលខុសត្រូវថែរក្សា និងថែទាំលើចំណែករួមតាមវិធានដែលអនុវត្តទៅលើកម្មសិទ្ធិអវិភាគដែរ ពោលគឺរាល់ការចំណាយទៅលើការជួសជុល ការថែទាំ ត្រូវធ្វើតាមសមាមាត្រនៃឡូត៍នីមួយៗ ឬអាចធ្វើតាមការព្រមព្រៀងដោយឡែកផ្សេងទៀត ហើយករណីសហកម្មសិទ្ធិករណាម្នាក់ល្មើសនឹងត្រូវទទួលទណ្ឌកម្មខុសពីចំណែកឯកជន ដែលសហកម្មសិទ្ធិករម្នាក់ៗអាចសម្រេចថែទាំ ឬមិនថែទាំឱ្យតែមិនប៉ះពាល់ដល់សហកម្មសិទ្ធិករដទៃទៀត។

## ២.២. សហកម្មសិទ្ធិករជាជនបរទេស

### ២.២.១. សិទ្ធិរបស់សហកម្មសិទ្ធិករ

ជនបរទេសសំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលបរទេសដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតពីពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើង។ [72]

តាមគោលការណ៍នៃនីតិអន្តរជាតិ គេបានកម្រិតនូវការកាន់កាប់កម្មសិទ្ធិ លើអចលនវត្ថុរបស់ជនបរទេសដើម្បីជានានូវអធិបតេយ្យភាពរបស់ប្រទេសនីមួយៗ ហើយគោលការណ៍នេះក៏ត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាដែរ។ ជាក់ស្តែងមាត្រា ៤៤ កថាខណ្ឌ១ វាក្យខណ្ឌ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថាមានតែរូបវន្តបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិដីធ្លី។ ដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិលើដីធ្លីនៃព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែរូបវន្តបុគ្គល ឬនីតិបុគ្គលនោះមានសញ្ជាតិខ្មែរ។ នេះបង្ហាញអំពីការកម្រិតសិទ្ធិរបស់ជនបរទេសទៅលើដីធ្លីនៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនបានកម្រិតសិទ្ធិកម្មសិទ្ធិលើអគារទេ ហើយក៏មិនមានន័យថាជនបរទេសអាចកាន់កាប់កម្មសិទ្ធិលើ

---

[53] មាត្រា ១៥ កថាខណ្ឌ២ វាក្យខណ្ឌ១ នៃអនុក្រឹត្យ ១២៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អាគារសហកម្មសិទ្ធិ ឆ្នាំ២០០៩

[54] មាត្រា ៤ ចំនុច១ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស ឆ្នាំ២០១០

អគារនៅជាន់ផ្ទាល់ដីដែរ ដើម្បីជៀសវាងការកាន់កាប់កម្មសិទ្ធិលើដីធ្លី គឺត្រូវកំណត់ចាប់ពីជាន់ទីមួយឡើងទៅ។ ប៉ុន្តែកន្លងមក ក៏មិនមានឯកសារណាមួយដែលបានចែងពីការបើកសិទ្ធិឱ្យកម្មសិទ្ធិករជាជនបរទេសកាន់កាប់កម្មសិទ្ធិលើអគារទេ ទើបតែថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ រដ្ឋសភាអនុម័ត ព្រមទាំងបានឡាយព្រះហស្តលេខាដាក់ឱ្យប្រើដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ នូវច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិ លើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស។ ដោយសារតែហេតុនេះហើយទើបធ្វើឱ្យប្រធានស្តីអំពី អគារសហកម្មសិទ្ធិនេះ ទទួលបាននូវការចាប់អារម្មណ៍ពីមជ្ឈដ្ឋានទូទៅច្រើន ពិសេសពីសំណាក់អ្នកសិក្សាស្រាវជ្រាវ និងសហកម្មសិទ្ធិករ។

យោងតាមច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៩៦ នៃព្រះរាជាណាចក្រកម្ពុជា អាចទទួលបានសញ្ជាតិខ្មែរបានតាមរយៈ ៖

- មានទីកំណើតនៅព្រះរាជាណាចក្រកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ
- សញ្ជាតូបនីយកម្ម។

ដោយសារតែការទទួលបានសញ្ជាតិខ្មែរត្រូវបានបំពេញលក្ខខណ្ឌជាច្រើន ហើយត្រូវចំណាយពេលវេលាយូរដែលបានផ្តល់នូវផលវិបាកជាច្រើន ទៅដល់ជនបរទេសដែលមានបំណងមកដាក់ទុនវិនិយោគ ហើយចង់កាន់កាប់កម្មសិទ្ធិលើអចលទ្រព្យនៅប្រទេសកម្ពុជា។

ជនបរទេសបានអនុវត្ត សិទ្ធិកាន់កាប់ដីធ្លី និងអគារផ្សេងៗរបស់ខ្លួនតាមរយៈអ្នកតំណាងដែលចំណុចនេះបាន បង្កវិវាទជាច្រើនករណី ហើយឈានដល់ការដោះស្រាយពីអំណាចតុលាការផងដែរ ស្របពេលដែលជនបរទេសមួយចំនួនធំបានគោរពតាមលក្ខខណ្ឌច្បាប់បានត្រឹមត្រូវល្អ។ ដើម្បីទប់ស្កាត់នូវភាពមិនប្រក្រតីខាងលើ ក៏ដូចជាទាក់ទាញវិនិយោគិនសម្រួលដល់ទីផ្សារអចលវត្ថុ ជម្រុញដល់ការអភិវឌ្ឍ ជួយដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ហើយដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ទើបផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ចនៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជនបានស្នើសុំឱ្យមានបញ្ញត្តិមួយអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិលើបន្ទប់ក្នុងអគារច្រើនជាន់ (អគារសហកម្មសិទ្ធិ) និងផ្អែកលើតថភាពនៃការរីកចម្រើនក្នុងវិស័យសំណង់ និងការកើនឡើងនៃសេវាកម្មលើវិស័យដីធ្លី និងទីផ្សារដីធ្លី ក្នុងព្រះរាជាណាចក្រកម្ពុជាឡើង។ ហេតុនេះហើយបានជាច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសបានលេចរូបរាងឡើង ក្នុងគោលដៅផ្តល់សិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់ និង

អាស្រ័យផលលើចំណែករួមនៃអគារសហកម្មសិទ្ធិរបស់ជនបរទេស ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់[73] និងមានកាតព្វកិច្ចគោរពតាមបញ្ញត្តិជាធរមានទាំងឡាយដែលពាក់ព័ន្ធ។[74] ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះហាក់បីដូចជាធ្វើការចង្អុលបង្ហាញទៅរកបទដ្ឋានគតិយុត្តផ្សេងៗទៀតជាច្រើន អាស្រ័យដោយការវិវត្តរបស់សង្គម ដូចនេះលិខិតគតិយុត្តមួយនេះ នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់យកទៅអនុវត្តជាក់ស្តែងដែរ ពោលគឺត្រូវការជានិច្ចប្រកាស សារាចរ សេចក្តីណែនាំរបស់ក្រសួង ឬស្ថាប័នមានសមត្ថកិច្ច ដើម្បីសម្រួលដល់ការអនុវត្តជាក់ស្តែង។

សហកម្មសិទ្ធិករពិសេស[75] នៃអគារសហកម្មសិទ្ធិ ម្ចាស់កម្មសិទ្ធិករនីមួយៗក៏នឹងទទួលបាននូវសិទ្ធិសំខាន់ៗ ដូចគ្នាទៅនឹងសហកម្មសិទ្ធិករដែលជាពលរដ្ឋខ្មែរដែរ គឺសិទ្ធិកម្មសិទ្ធិ និងសិទ្ធិគ្រប់គ្រង។ ច្បាប់បានកំណត់វិសាលភាពចំពោះសិទ្ធិដែលពួកគេនឹងទទួលបាន ព្រមទាំងបានកម្រិតនូវសិទ្ធិកម្មសិទ្ធិមួយចំនួនចំពោះសហកម្មសិទ្ធិករជាជនបរទេសនេះផងដែរ។ កាលណានិយាយដល់ សិទ្ធិកម្មសិទ្ធិជនបរទេស លើអចលនវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រាកដជានឹងថាតើជនបរទេសមានសិទ្ធិ និងកាតព្វកិច្ច និងការទទួលខុសត្រូវដូចគ្នា ឬក៏ខុសគ្នាពីសហកម្មសិទ្ធិករជាពលរដ្ឋខ្មែរ ហើយការកម្រិតសិទ្ធិរបស់ជនបរទេសនៅលើអគារសហកម្មសិទ្ធិមាននៅត្រង់ចំណុចណាខ្លះ?

### ២.២.១.១. សិទ្ធិកម្មសិទ្ធិ

សិទ្ធិកម្មសិទ្ធិរបស់សហកម្មសិទ្ធិករជាជនបរទេស ក៏មានលក្ខណៈប្រហាក់ប្រហែលទៅនឹងសិទ្ធិកម្មសិទ្ធិរបស់សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរដែរ គ្រាន់តែសិទ្ធិទាំងនោះត្រូវបានកម្រិតនៅក្នុងករណីមួយចំនួនប៉ុណ្ណោះ។ ជាក់ស្តែងមាត្រា៦ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិរបស់ជនបរទេស ចំពោះការកម្រិតសិទ្ធិលើចំណែកឯក

[55] មាត្រា ១ និង មាត្រា ៥ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ២០១០

[56] សហកម្មសិទ្ធិករពិសេសសំដៅដល់ជនបរទេសដែលមានសិទ្ធិសហកម្មសិទ្ធិពិសេស។

សហកម្មសិទ្ធិពិសេស សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបជាជនបរទេស និងជាពលរដ្ឋខ្មែរលើអាគារសហកម្មសិទ្ធិតែមួយដែលក្នុងនោះជនបរទេស និងពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និងមានសិទ្ធិកម្មសិទ្ធិអវិភាគពិសេសលើចំណែករួមនៃអាគារសហម្មសិទ្ធិ។

[57] ជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ សំដៅដល់ជនបរទេសដែលមានសមត្ថភាពតាមផ្លូវច្បាប់កម្ពុជា និងបានចូលមកព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់

ជនរបស់សហកម្មសិទ្ធិករពិសេស។ ការកម្រិតសិទ្ធិកម្មសិទ្ធិលើចំណែកឯកជនទាំងនោះមានដូចជា៖

- អាចមានសិទ្ធិកម្មសិទ្ធិចាប់ពីជាន់ទីមួយឡើងទៅ ដោយមិនអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិនៅជាន់ផ្ទាល់ដី និងជាន់ក្រោមដីទេ៖ ជាធម្មតាជនបរទេសមិនមានសិទ្ធិកម្មសិទ្ធិលើដីធ្លីនៅព្រះរាជាណាចក្រកម្ពុជាទេ នេះជាបញ្ញត្តិដែលចែងដើម្បីធានានូវអធិបតេយ្យភាពរបស់រដ្ឋ។ ហេតុនេះបានជាច្បាប់អនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកាន់កាប់លើអគារ ប៉ុន្តែសិទ្ធិកម្មសិទ្ធិនោះត្រូវបានកម្រិត គឺជនបរទេសអាចកាន់កាប់ចាប់ពីជាន់ទីមួយតែប៉ុណ្ណោះ ព្រោះបើអនុញ្ញាតឱ្យគាត់កាន់កាប់ជាន់ផ្ទាល់ដី ឬជាន់ក្រោមដី គឺដូចជាឱ្យគាត់កាន់កាប់កម្មសិទ្ធិលើដីធ្លីដែរ។
- ចំពោះសមាមាត្រ និងរបៀបគិតគូរនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេស គឺត្រូវបានកំណត់ដោយអនុក្រឹត្យដោយឡែក ដែលបានកំណត់ផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជនដល់ជនបរទេសនៃអគារសហកម្មសិទ្ធិមួយកន្លែងដោយមិនឱ្យលើសពី៧០ភាគរយ នៃទំហំផ្ទៃក្រឡានៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិនោះទេ។ ច្បាប់បានកំណត់ដូចនេះក្នុងគោលបំណងជួយអភិវឌ្ឍទីផ្សារអចលនវត្ថុក្នុងពេលបច្ចុប្បន្នដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស និងដើម្បីទាក់ទាញអ្នកវិនិយោគពីខាងក្រៅមកកាន់តែច្រើន។
- ត្រូវបានផ្តល់សិទ្ធិកម្មសិទ្ធិតែលើចំណែកឯកជននៃអគារតែប៉ុណ្ណោះ ឯចំណែករួមត្រូវបានរក្សាទុក សម្រាប់សហកម្មសិទ្ធិករទាំងអស់ប្រើប្រាស់ជារួម។
- គ្មានករណីណា ដែលសហកម្មសិទ្ធិករជាជនបរទេសអាចទទួលបានសិទ្ធិកម្មសិទ្ធិលើក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅនោះទេ។
- មិនអនុញ្ញាតសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតនៅចម្ងាយពីព្រំដែនគោក៣០គីឡូម៉ែត្រ និងតំបន់មួយចំនួនទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស[76] និងទីប្រជុំជនសំខាន់ៗ និងតំបន់មួយចំនួនទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

---

58 តំបន់សេដ្ឋកិច្ចពិសេស សំដៅដល់មជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍវិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀតហើយអាចមានតំបន់ឧស្សាហកម្មទូទៅ ឬ/និង តំបន់ពិសេសកែច្នៃនាំចេញ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលមូលដ្ឋាន និងមណ្ឌលទេសចរណ៍។

- ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទីបី នោះជនបរទេសនឹងមាន តែសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចពលរដ្ឋខ្មែរដែរ។

ដូចគ្នានឹងសហកម្មសិទ្ធិករជាពលរដ្ឋខ្មែរដែរ ដើម្បីអាចក្លាយជាសហកម្មសិទ្ធិករលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិបាន លុះត្រាតែបុគ្គលនោះមានសមត្ថភាពពេញលក្ខណៈច្បាប់ ពោលគឺ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជានីតិជន និងមានសមត្ថភាពយល់ដឹងខាងឆន្ទៈ។

សហកម្មសិទ្ធិករគ្រប់រូបទាំងជនបរទេស និងពលរដ្ឋខ្មែរ នៃអគារសហកម្មសិទ្ធិទាំងអស់ត្រូវតែប្រើប្រាស់អគារសហកម្មសិទ្ធិក្នុងគោលបំណងស្របច្បាប់ មានន័យថា គាត់មិនអាចប្រើប្រាស់ ចំណែកឯកជនរបស់ខ្លួនក្នុងគោលបំណងព្យាបាទបំពាន ឬរាំងស្ទះដល់ការប្រើប្រាស់ ឬរំខានដល់ជីវភាពរស់នៅរបស់សហកម្មសិទ្ធិករលើចំណែកឯកជនផ្សេងទៀតឡើយ។

ការផ្ទេរសហកម្មសិទ្ធិពិសេសដោយការព្រមព្រៀងមិនមានអនុភាពទេ ប្រសិនបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី។[77]

### ២.២.១.២. សិទ្ធិគ្រប់គ្រង

សិទ្ធិគ្រប់គ្រងអគារសហកម្មសិទ្ធិរបស់សហកម្មសិទ្ធិករជាជនបរទេស មិនមានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់នៅឡើយទេ តែបើយោងតាមមាត្រា១៥ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសបានកំណត់ថា ជនបរទេសដែលជាសហកម្មសិទ្ធិករគ្មានសិទ្ធិចាត់ចែងលើចំណែករួមទេ គឺគាត់មិនអាចចូលរួមសម្រេចលើកិច្ចព្រមព្រៀងផ្សេងៗស្តីពីការគ្រប់គ្រងលើអគារសហកម្មសិទ្ធិទេ។ បន្ថែមពីនេះទៀត ច្បាប់ដដែលក៏បានកម្រិតសិទ្ធិរបស់សហកម្មសិទ្ធិករលើចំណែកឯកជនទាក់ទងនឹងការគ្រប់គ្រងអគារសហកម្មសិទ្ធិផងដែរ។

### ២.២.២. កាតព្វកិច្ច និងការទទួលខុសត្រូវ

សិទ្ធិរបស់សហកម្មសិទ្ធិករជាជនបរទេស នៅលើអគារសហកម្មសិទ្ធិត្រូវបានច្បាប់កម្រិតក៏ដោយ ក៏សហកម្មសិទ្ធិករជាជនបរទេសត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវដូចគ្នាទៅនឹងសហកម្មសិទ្ធិករជាពលរដ្ឋខ្មែរដែរ លើចំណែកឯកជនរបស់ខ្លួននៃអគារសហកម្មសិទ្ធិ។ ជាក់ស្តែងមាត្រា១៤ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហ

[59] មាត្រា ៨ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស ឆ្នាំ២០១០

កម្មសិទ្ធិមានកាតព្វកិច្ច និងបន្ទុកផ្សេងៗដូចសហកម្មសិទ្ធិករខ្មែរដែរ។ សហកម្មសិទ្ធិករពិសេស ត្រូវគោរពរាល់កាតព្វកិច្ច និងបន្ទុកដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិ និងច្បាប់ជាធរមាន។

ចំណែករួមនៃអគារសហកម្មសិទ្ធិ សហកម្មសិទ្ធិករជាជនបរទេស ឬសហកម្មសិទ្ធិករពិសេស ត្រូវចូលរួមថែទាំចំណែករួម ដោយការចំណាយទៅលើការថែទាំទាំងឡាយត្រូវគិតតាមសមាមាត្រនៃតម្លៃឡូត៍នីមួយៗ លើកលែងតែមានការព្រមព្រៀងណាមួយ ឬមានចែងដោយឡែកនៅក្នុងបទបញ្ជាផ្ទៃក្នុង។ [78]

សហកម្មសិទ្ធិករពិសេស ត្រូវទទួលខុសត្រូវរួមជាមួយសហកម្មសិទ្ធិករដទៃទៀតក្នុងករណីមានវិការៈណាមួយកើតឡើងដល់តតិយជន។

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

យោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា អគារសហកម្មសិទ្ធិគឺជាអចលវត្ថុមួយ ប្រភេទ ដែលច្បាប់បានផ្តល់សិទ្ធិជាកម្មសិទ្ធិផ្តាច់មុខលើចំណែកឯកជនឱ្យទៅកម្មសិទ្ធិករជាច្រើនរួមគ្នា របស់ទាំងពលរដ្ឋខ្មែរ និងបរទេស។ ដោយឡែកមានភាពខុសបន្តិចបន្តួច ចំពោះសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរវាងសហកម្មសិទ្ធិករដែលជាពលរដ្ឋខ្មែរ និងជនបរទេស គឺថាសហកម្មសិទ្ធិករដែលជាជន បរទេសមិនបានទទួលនូវបុព្វសិទ្ធិដ៏សំខាន់បំផុតនៃកម្មសិទ្ធិរបស់ខ្លួនទៅលើចំណែករួមនៃអគារសហកម្មសិទ្ធិ ដែលខ្លួនកំពុងតែរស់នៅនោះទេ ដែលសិទ្ធិនោះជាសិទ្ធិចាត់ចែង។ ចំណែកឯសហកម្មសិទ្ធិករជាពលរដ្ឋខ្មែរវិញ មានសិទ្ធិកម្មសិទ្ធិលើចំណែករួម បានន័យថាគាត់ទទួលបានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែង គ្រាន់តែសិទ្ធិក្នុងការចាត់ចែងនេះ ត្រូវបានកម្រិត ដោយត្រូវការការយល់ព្រមដោយសំឡេងគាំទ្រពី សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរទាំងអស់នៃអគារសហកម្មសិទ្ធិ។ ទន្ទឹមនឹងនេះ ការទទួលបាននូវសិទ្ធិទាំងនៅលើចំណែកឯកជន និងចំណែករួមនេះ សហកម្មសិទ្ធិករម្នាក់ៗត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវមួយចំនួនដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់ពួកគេម្នាក់ៗដែរ ដើម្បីថែទាំអគារឱ្យបានល្អ។

ច្បាប់ក៏បានកំណត់នូវវិសាលភាពនៃការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជនទៅឱ្យជនបរទេស ដើម្បីរក្សាអធិបតេយ្យភាព និងការពារការបំពានបញ្ញត្តិរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាល

---

[60] មាត្រា១៧ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិ លើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ២០១០

និងជួយជម្រុញការរីកចំរើននៃអចលនវត្ថុ ព្រមទាំងទាក់ទាញវិនិយោគ ដោយការកម្រិតសិទ្ធិកម្មសិទ្ធិលើចំណែកនេះ។ មិនថាសហកម្មសិទ្ធិករជាពលរដ្ឋខ្មែរ ឬជាជនបរទេសអាចនឹងទទួលនូវទណ្ឌកម្មផ្សេងៗ ដូចគ្នាក្នុងករណីដែលធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងទៀតទៅលើអចលនវត្ថុ ឬធ្វើឱ្យប៉ះពាល់ដល់ចំណែករួមនៃអគារ ឬដោយធ្វើការកែប្រែដើម្បីការប្រើប្រាស់ជាលក្ខណៈឯកជន ឬសម្រាប់លក់ជាដើម។

ទាក់ទងនឹងបញ្ហាអគារសហកម្មសិទ្ធិនេះ យើងឃើញថានៅមានចំណុចខ្វះចន្លោះមួយចំនួនដែលច្បាប់ ឬបទដ្ឋានគតិយុត្ត មិនបានលើកឡើង ឬលើកឡើងដែរ ប៉ុន្តែនៅមានភាពមិនទាន់ទូលំទូលាយ ដូចជាពេលណាដែលអ្នកអភិវឌ្ឍអចលនវត្ថុត្រូវបាត់បង់សិទ្ធិរបស់ខ្លួននៅលើអគារសហកម្មសិទ្ធិនោះ ហើយច្បាប់ក៏មិនបានបញ្ជាក់ឱ្យបានច្បាស់អំពីសិទ្ធិរបស់សហកម្មសិទ្ធិករជាជនបរទេសនៅលើក្បាលដីនៃអគារសហកម្មសិទ្ធិដែលច្បាប់គ្រាន់តែបញ្ញត្តិថា ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសទេ ដែលវិវាទអាចនឹង កើតមានឡើងនៅពេលដែលអគារសហកម្មសិទ្ធិនោះត្រូវបានបាត់បង់ដូចជារលំ ឬមានអគ្គីភ័យផ្សេងៗកើតឡើងថាតើក្បាលដីនៃអគារសហកម្មសិទ្ធិនឹងត្រូវបែងចែងដោយរបៀបណា?

ជាចុងក្រោយ ជាមួយនឹងអនុសាសន៍មួយចំនួនដើម្បីសម្រេចបំណងនៃការជួយលើកស្ទួយសេដ្ឋកិច្ចជាតិ និងដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអគារសហកម្មសិទ្ធិដែលស្របទៅនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃវិនិយោគិនទាំងក្នុង និងក្រៅប្រទេស ជាពិសេសដើម្បីទាក់ទាញវិនិយោគឱ្យបានកាន់តែច្រើន គេសង្ឃឹមថាក្នុងពេលអនាគតដ៏ខ្លី រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធគប្បី៖

- រៀបចំតាក់តែងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបន្ថែម ដើម្បីបំពេញនូវភាពខ្វះចន្លោះដែលបានលើកឡើងខាងលើ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ជាមួយនឹងច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស។
- បង្កលក្ខណៈឱ្យនីតិវិធី នៃការចុះបញ្ជីចំណែកឯកជន នៃអគារសហកម្មសិទ្ធិមានភាពងាយស្រួល ព្រមទាំងចំណាយពេលតិច។
- ពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដើម្បីឱ្យវិនិយោគិនមានទំនុកចិត្តក្នុងការមកវិនិយោគនៅកម្ពុជា។

# នីតិវិធីរដ្ឋប្បវេណី

# នីតិវិធីជំនុំជម្រះក្តីលើកទី១

ដោយលោកមេធាវី ប៉ោ ហ៊ុយ*

## ជំពូកទី ១: ការដាក់ពាក្យបណ្តឹង

### ១.១ របៀបដាក់ពាក្យបណ្តឹង

នីតិវិធីបណ្តឹងរដ្ឋប្បវេណីនៅតុលាការ ត្រូវបានចាប់ផ្តើមនៅពេលដែលមានការដាក់ពាក្យបណ្តឹង។ ពាក្យបណ្តឹងដែលបានចាត់ទុកថាបានដាក់នៅពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងនោះទៅតុលាការ ហើយត្រូវបានបុគ្គលិករដ្ឋបាលផ្នែកទទួលពាក្យបណ្តឹងរដ្ឋប្បវេណី បោះត្រា និងចុះលេខចូលថាបានទទួល ។

"បណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតុលាការ[79]" លើកលែងតែមានបញ្ញត្តិផ្សេងដែលច្បាប់អនុញ្ញាតឱ្យធ្វើដោយផ្ទាល់មាត់ ជាក់ស្តែងក្នុងមាត្រា២២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ អនុញ្ញាតឱ្យធ្វើបណ្តឹងដោយផ្ទាល់មាត់ក្នុងករណីដែលដាក់ពាក្យបណ្តឹងនៃរឿងក្តីដែលមានចំនួនទឹកប្រាក់តិច (មិនលើសពី មួយលានរៀល)។[80]

#### ១.១.១ ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹង

##### ១.១.១.១ អត្តសញ្ញាណរបស់ភាគី

ពាក្យបណ្តឹងត្រូវសរសេរឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីឱ្យបានច្បាស់លាស់។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីឱ្យបានច្បាស់លាស់ គឺជាការចាំបាច់សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់ភាគីព្រមទាំងសម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹង និងឯកសារផ្សេងៗទៅភាគីចុងចម្លើយ[81] ។ ភាគីមានដូចជា ដើមចោទ និងចុងចម្លើយជាដើម ។

ចំពោះដើមចោទជាអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកតំណាងឱ្យដូចជា នីតិបុគ្គល អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅជាដើម) ពាក្យបណ្តឹងត្រូវសរសេរបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់នោះ។

---

* អ្នកនិពន្ធបច្ចុប្បន្នជាមេធាវីក្រុមហ៊ុនមេធាវី ខេ អ៊ែល អ៊េស ខេ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ អ្នកនិពន្ធក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ពី សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផងដែរ។

[79] មាត្រា៧៥ កថាខណ្ឌទី១ និងមាត្រា៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[80] មាត្រា២២៤ កថាខណ្ឌទី១នៃក្រមដដែល

[81] មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក នៃក្រមដដែល

ចំពោះអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ[82] (ដូចជាមេធាវីជាដើម) ពាក្យបណ្តឹងត្រូវសរសេរបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះ ។

**១.១.១.២ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញនិងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ[83] យោងតាមចំណុចនេះ អាចបញ្ជាក់នូវ ការទាមទារតាមផ្លូវបណ្តឹងបាន។

ការទាមទារតាមផ្លូវបណ្តឹង គឺជាកម្មវត្ថុដែលតុលាការត្រូវធ្វើការជំនុំជម្រះ និងវិនិច្ឆ័យ។ ចំពោះតុលាការចេញជាសាលក្រមនូវអ្វីដែលជាការទាមទាររបស់ភាគីដែលបានស្នើសុំ ដោយឡែកតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានស្នើសុំឡើយ ប៉ុន្តែតុលាការត្រូវចេញសេចក្តីសម្រេចអំពីករណីកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានការស្នើសុំរបស់ភាគីក៏ដោយ[84] ។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺការសម្រេចសេចក្តីអំពីអត្ថន័យនៃ សាលក្រមដែលដើមចោទចង់ឱ្យតុលាការចេញដូចក្នុងពាក្យបណ្តឹងរបស់ខ្លួន ។ ការសរសេរពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ នៅក្នុងពាក្យបណ្តឹងមានភាពខុសប្លែកគ្នាទៅតាមប្រភេទនៃបណ្តឹង ដែលរួមមានបីប្រភេទដូចជា[85]៖

**(ក) បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក**

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក គឺជាបណ្តឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារតាវកាលិកកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង ហើយទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិកមួយ ដោយផ្អែកលើសិទ្ធិនោះ។

ឧទាហរណ៍: ដើមចោទ បានទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយឈ្មោះ ខ ប្រគល់ប្រាក់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) ។

**(ខ) បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាការទាមទារតាមផ្លូវបណ្តឹង ហើយទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មី ប្តូរ ឬរំលត់នូវទំនាក់ទងគតិយុត្តដោយផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ ។

---

[82] មាត្រា ៥៣ នៃក្រមដដែល

[83] មាត្រា ៧៥ កថាខណ្ឌទី២ ចំណុចខ នៃក្រមដដែល

[84] មាត្រា ១៨២ នៃក្រមដដែល

[85] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ឆ្នាំ២០០៨ ទំព័រទី ៤៤

ឧទាហរណ៍: ដើមចោទ បានទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយឈ្មោះ ខ ផ្ទេរកម្មសិទ្ធិត្រឡប់លើដី (x) មកឱ្យដើមចោទ ដូចមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ xxxx ចុះថ្ងៃxx ខែxx ឆ្នាំxxxx។

### (គ) បណ្តឹងទាមទារឱ្យបញ្ជាក់

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងដែលដើមចោទអះអាងនូវអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទំនងគតិយុត្តកំណត់មួយ ហើយទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទំនងគតិយុត្តនោះ។ បណ្តឹងទាមទារឱ្យបញ្ជាក់នេះ ការសរសេរខ្លឹមសារនៃពាក្យបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រម នៅក្នុងបណ្តឹង(ក) និង(ខ) ខាងលើ ការសរសេរខ្លឹមសារនៃបណ្តឹងនេះ (បណ្តឹងទាមទារឱ្យបញ្ជាក់) ដើមចោទគ្រាន់តែបង្ហាញនូវអង្គហេតុដែលចាំបាច់ដើម្បីបញ្ជាក់នូវការទាមទាររួចជាការស្រេច ។

ឧទាហរណ៍ : ដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រម បញ្ជាក់ថាដើមចោទជាកម្មសិទ្ធិនៅលើផ្ទះ(x) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ xxxx ចុះថ្ងៃxx ខែxx ឆ្នាំxxxx។។

សរុបសេចក្តីមក នៅក្នុងការសរសេរពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញចាំបាច់ត្រូវបញ្ជាក់ពីខ្លឹមសារដែលខ្លួនទាមទារឱ្យបានច្បាស់លាស់ ព្រោះងាយស្រួលដល់ចៅក្រមចេញសាលក្រមតាមចំណុចដែលខ្លួនទាមទារឲ្យតុលាការចេញសាលក្រម ។

### ១.១.១.៣ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

**អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ** គឺជាអង្គហេតុដែលដើមចោទត្រូវសរសេរឱ្យបានច្បាស់លាស់ចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្តឹង។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារសំដៅទៅលើអង្គហេតុ ដែលអាចធ្វើការសម្គាល់កុំឱ្យមានការភាន់ច្រឡំ និងទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទ និងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដទៃទៀត។ មូលហេតុចាំបាច់ត្រូវសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ក្នុងពាក្យបណ្តឹង គឺដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬមានការបែងចែងមិនច្បាស់លាស់នូវការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងសម្រេចសេចក្តី ទៅនឹងការទាមទាររបស់ដើមចោទ ។

ឧទាហរណ៍ (តពីចំណុច ក ) : ដើមចោទបានលក់ដី (x) ទៅឱ្យចុងចម្លើយឈ្មោះ ខ ក្នុងតម្លៃ ៣០០.០០០$ (បីរយពាន់ដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៨ ។ ចុងចម្លើយបានប្រគល់ប្រាក់ក្នុងដំណាក់កាលទី១ និងទី២ ជូនដើមចោទរួចហើយ ប៉ុន្តែចុងចម្លើយមិនទាន់បានប្រគល់ប្រាក់បង្គ្រប់ចំនួន ១០០.០០០$(មួយ

រយពាន់ដុល្លារអាមេរិក) ក្នុងដំណាក់កាលទី៣ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ មកឱ្យដើមចោទនៅឡើយទេ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

តាមរយៈការបញ្ជាក់ទាំងនេះ គឺបានច្បាស់លាស់នូវកម្មវត្ថុនៃសិទ្ធិ ប្រភេទ និងខ្លឹមសារនៃសិទ្ធិ ព្រមទាំងមូលហេតុនៃការកកើតសិទ្ធិ គឺអាចបញ្ជាក់ឱ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្ដឹងរបស់ដើមចោទបាន ។

### ១.១.២ ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្ដឹង

#### ១.១.២.១ អង្គហេតុដែលជាមូលហេតុនៃការទាមទារ

អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្ដឹង ។ ម៉្យាងវិញទៀតអង្គហេតុនេះ ដើមចោទត្រូវសរសេរបំភ្លឺឱ្យបានច្បាស់លាស់អំពីការអះអាងនៃការទាមទារ ។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ ធ្វើឡើងដើម្បីបង្ហាញអំពីការកើតមានឡើងនៃការទាមទារតាមផ្លូវ បណ្ដឹងរបស់ដើមចោទ ។

ឧទាហរណ៍ : ដើមចោទបានផ្ទេរសិទ្ធិលើដី (x)ទៅឱ្យចុងចម្លើយរួចហើយ ប៉ុន្តែចុងចម្លើយមិនទាន់បានប្រគល់ប្រាក់បង្គ្រប់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) មកឱ្យដើមចោទនៅឡើយទេ រហូតមកដល់បច្ចុប្បន្ន ដូចមានក្នុងដំណាក់កាលទី៣ នៃកិច្ចសន្យាទិញលក់ផ្ទះចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៨ ។

#### ១.១.២.២ អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង

ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ និងភស្តុតាង ។ អង្គហេតុដែលពាក់ព័ន្ធមានដូចជាអង្គហេតុប្រយោល ។ អង្គហេតុប្រយោល គឺជាអង្គហេតុទាំងឡាយណាដែលធ្វើឱ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុចម្បង ។

វិធីដើម្បីធ្វើការបញ្ជាក់ភស្តុតាងនៃអង្គហេតុមានពីរវិធី ៖

វិធីទី១ : ការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុនោះ ដោយភស្តុតាងផ្ទាល់ ។

វិធីទី២ : ការទទួលស្គាល់នូវអង្គហេតុប្រយោល តាមរយៈភស្តុតាងប្រយោល ហើយទទួលស្គាល់នូវអង្គហេតុនោះ ដោយអង្គហេតុប្រយោលដែលបានបញ្ជាក់នេះ ដូច្នេះ គឺជាការសន្និដ្ឋាននូវអង្គហេតុនោះតាមរយៈអង្គហេតុប្រយោល ។ ប៉ុន្តែភស្តុតាងប្រយោលនេះតុលាការភាគតិចណាស់ទទួលស្គាល់ភស្តុតាងនេះ ប្រើបើភាគីមិនមានភស្តុតាងផ្ទាល់ខ្លះៗភ្ជាប់ជាមួយ ។

ប្រសិនបើជាមានកង្វះខាតនូវភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់អង្គហេតុចម្បង ដើមចោទគប្បីសរសេរក្នុងពាក្យបណ្តឹងនូវអង្គហេតុប្រយោលឱ្យបានច្រើន ។ ផ្ទុយមកវិញ ប្រសិនបើមានភស្តុតាងផ្ទាល់ច្បាស់លាស់ហើយ មិនចាំបាច់សរសេរអង្គហេតុប្រយោលក៏បានដែរ[86] ។

ឧទាហរណ៍ : អង្គហេតុចម្បង : លោក "ក" បានឱ្យប្រាក់ លោក "ខ" ខ្ចីចំនួន ៣០០០$ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ នៅវេលាម៉ោង១០ព្រឹក ។ ដើមចោទអះអាងពីអង្គហេតុប្រយោល : លោក "ក" បានដកប្រាក់ពីធនាគារ (A) ចំនួន ៣០០០$ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ នៅវេលាម៉ោង០៩ព្រឹក ក្រោយមកលោក "ខ" បានទិញម៉ូតូម៉ាកអេសហ្សេតសេរីឆ្នាំ២០១៩ មួយគ្រឿង ក្នុងតម្លៃប្រហែលជា ៣០០០$ ។ អង្គហេតុនេះ គឺបញ្ជាក់ឱ្យឃើញច្បាស់និងស៊ីសង្វាក់ជាមួយនឹងអង្គហេតុចម្បង។

[86] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ឆ្នាំ ២០០៨ ទំព័រទី ៤០ និង៦៦

**ពាក្យបណ្តឹងគំរូ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

❖ ដើមចោទ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ ......... រាជធានីភ្នំពេញ/ខេត្ត............

❖ ចុងចម្លើយ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ ......... រាជធានីភ្នំពេញ/ខេត្ត............

**សូមគោរពជូន**
**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ/ខេត្ត**..............

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ...........
២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ...................
៣. ...............
៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ៖**

..................................................................................................................................
..................................................................................................................................
..................................................................................................................................។

**គ. អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖**

..................................................................................................................................
..................................................................................................................................
..................................................................................................................................។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមពាក្យបណ្តឹងរបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ................ កើត/រោច ខែ............ ឆ្នាំ....... ............ស័ក ព.ស. ២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.................. ឆ្នាំ២០..........

**ស្នាមមេដៃស្តាំ**

**ឯកសារថតចម្លងភ្ជាប់ជាមួយ៖**

១.................
២................

## ១.២ ការទទួលពាក្យបណ្ដឹង

### ១.២.១ នីតិវិធីនៃការទទួលពាក្យបណ្ដឹង

នៅពេលដែលមានការដាក់ពាក្យបណ្ដឹងនៅតុលាការ ជាក់ស្ដែងដែលអនុវត្តប្រចាំថ្ងៃនៅសាលាដំបូងរាជធានីភ្នំពេញ អ្នកមានភារៈទទួលពាក្យបណ្ដឹងអនុវត្តតាមជំហានដូចខាងក្រោម ៖

(១) មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្ដឹងរដ្ឋប្បវេណី ជាអ្នកវាយត្រាលើពាក្យបណ្ដឹងដែលបានទទួល ហើយចុះកាលបរិច្ឆេទនៃការទទួល និងចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្ដឹង រួមទាំងចេញបង្កាន់ដៃបង់ប្រាក់ផងដែរ។

សំគាល់ : មុនពេលទទួលពាក្យបណ្ដឹងមកធ្វើចំណាត់ការដូចខាងលើ មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យ បណ្ដឹងគួរពិនិត្យមើលពាក្យបណ្ដឹងមួយត្រួសសិន ហើយបើសិនមានការខ្វះខាតមន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្ដឹង គប្បីពន្យល់ឱ្យអ្នកដាក់ពាក្យបណ្ដឹងធ្វើការកែតម្រូវពីចំណុចខ្វះខាតនោះសិន។ ចំណុចដែលមន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្ដឹង គប្បីពន្យល់ដល់អ្នកដាក់ពាក្យអំពីការសរសេរបណ្ដឹងត្រឹមត្រូវតាមមាត្រា ៧៥កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី (១. **ចំណុចត្រូវសរសេរក្នុងពាក្យបណ្ដឹង**ខាងលើ) និងសមត្ថកិច្ចសាលាជំនុំជម្រះក្ដីនៃតុលាការដែលទទួលពាក្យបណ្ដឹង(មាត្រា៨ និងមាត្រា៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

(២) មន្ត្រីរដ្ឋបាលនោះ ត្រូវបញ្ជូនពាក្យបណ្ដឹងទៅឱ្យប្រធានតុលាការ ។

(៣) ប្រធានតុលាការ ចារឈ្មោះចៅក្រម ទទួលបន្ទុកតាមលំដាប់បន្ទាប់ដែលបានកំណត់ លើសាមីនៃពាក្យបណ្ដឹងនោះ ហើយមន្ត្រីរដ្ឋបាលនោះ ត្រូវយកសាមីនៃពាក្យបណ្ដឹងនោះ ទៅឱ្យក្រឡាបញ្ជីរដ្ឋបាលនៃបន្ទាប់ចៅក្រមទទួលបន្ទុកនោះ ។

(៤) ក្រឡាបញ្ជីរដ្ឋបាលនោះ ត្រូវទទួលសាមីនៃពាក្យបណ្ដឹងនោះ ហើយយកទៅឱ្យចៅក្រមទទួលបន្ទុកនោះ និងចៅក្រមនោះត្រូវចារឈ្មោះក្រឡាបញ្ជីណាជាអ្នកកាន់ពាក្យបណ្ដឹងនោះ(រឿងក្ដី)លើសាមីនៃពាក្យបណ្ដឹងនោះ ។

(៥) ក្រឡាបញ្ជីរដ្ឋបាលនោះ ត្រូវយកសាមីពាក្យបណ្ដឹងចុះក្នុងសៀវភៅទទួលពាក្យបណ្ដឹងរបស់ខ្លួន ។

### ១.២.២ ឯកសារភ្ជាប់ជាមួយពាក្យបណ្ដឹង

ការដាក់ពាក្យបណ្ដឹង ត្រូវមានឯកសារភ្ជាប់មកជាមួយពាក្យបណ្ដឹង ដោយសារឯកសារដែលភ្ជាប់មកជាមួយ គឺបញ្ជាក់ឱ្យបានច្បាស់លាស់នូវក្នុងបណ្ដឹង។

ដោយយោងតាមមាត្រា ៧៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺទាក់ទងទៅនឹងអ្នកដាក់ពាក្យ ហើយអ្នកដាក់ពាក្យបណ្តឹងមានច្រើនប្រភេទ ដូចជា ភាគី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងនៃ នីតិបុគ្គល និងអ្នកតំណាងដោយអាណត្តិ ។ ដូច្នេះ ប្រសិនបើអ្នកតំណាងទាំងនោះ ត្រូវបានម្ចាស់បណ្តឹងប្រគល់សិទ្ធិ ឱ្យដូចនេះ ត្រូវតែមានលិខិតបញ្ជាក់សិទ្ធិតំណាងនោះ ហើយសិទ្ធិតំណាងនោះមានខាងក្រោម ៖

(១) បើជាអ្នកតំណាងដែលច្បាប់បានកំណត់ ដូចជា ឪពុកម្តាយ តំណាងឱ្យកូនជាអនីតិជន ឬអ្នកអាណាព្យាបាល គឺលិខិតបញ្ជាក់សិទ្ធិនោះ ដោយជាលាយលក្ខអក្សរ[87] ។ បើជាឪពុកម្តាយ លិខិតបញ្ជាក់នោះអាចជាសំបុត្រកំណើតរបស់កូន សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ជាដើម ។ បើជាអាណាព្យាបាល លិខិតបញ្ជាក់សិទ្ធិតំណាង គឺជាសេចក្តីសម្រេចរបស់តុលាការ ។

(២) បើជាអ្នកតំណាងនៃនីតិបុគ្គល ត្រូវ*អនុវត្តដូចអ្នកតំណាងដែលច្បាប់បានកំណត់*[88] គឺលិខិតបញ្ជាក់សិទ្ធិនោះ ដោយជាលាយលក្ខអក្សរ ។[89]

(៣) អ្នកតំណាងដោយអាណត្តិ ត្រូវមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ និងលិខិតតំណាងដោយអាណត្តិ។[90]

ម៉្យាងវិញទៀត ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើ ក៏មានឯកសារភ្ជាប់ជាមួយពាក្យបណ្តឹងផងដែរ ដូចជា ឯកសារភស្តុតាង(ឯកសារថតចម្លងពីច្បាប់ដើម)សម្រាប់ធ្វើការទាមទារ និងឯកសារពាក់ព័ន្ធផ្សេងទៀត (ឯកសារថតចម្លង) ។

### ១.២.៣ ពន្ធដាក់ពាក្យបណ្តឹង និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

#### ១.២.៣.១ ពន្ធដាក់ពាក្យបណ្តឹង

នៅពេលដាក់ពាក្យបណ្តឹងទៅតុលាការ ដើមចោទត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដល់ ១០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០ រៀល ត្រូវបង់ ១.០០០ រៀល ។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០.០០០.០០០ រៀល ដល់ ១០០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០ រៀល ត្រូវបង់ ៧០០ រៀល ។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែល

[87] មាត្រា ៣៥ កថាខណ្ឌទី៣ នៃក្រមដដែល

[88] មាត្រា ៣៨ នៃក្រមដដែល

[89] មាត្រា ៣៥ កថាខណ្ឌទី៣ នៃក្រមដដែល

[90] មាត្រា២ និងមាត្រា៣នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៤៥ និង៥២ នៃក្រមដដែល

លើស ១០០.០០០.០០០រៀល ដល់ ១.០០០.០០០.០០០រៀល ក្នុងចំនួន ១០០.០០០ រៀល ត្រូវបង់ ៣០០រៀល ។ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងលើស ១.០០០.០០០.០០០ រៀល ក្នុងចំនួន ១០០.០០០រៀល ត្រូវបង់១០០រៀល ។ ចំពោះការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបង់ពន្ធ ១,៥ដង រីឯចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខវិញ ត្រូវបង់ពន្ធ២ដង នៃថ្លៃពន្ធដែលបានគណនាក្នុងកថាខណ្ឌទី១ និងទី២ នេះទៅតុលាការ ។ ចំពោះការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវបង់១០.០០០រៀលទៅតុលាការ។ ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធចំនួន១ភាគ២ នៃប្រាក់ដោយគណនារួច ទៅតាមតម្លៃកម្មនៃការទាមទារ ។ ការដែលបង់ពន្ធលើស សងពន្ធដែលបានបង់លើសទៅវិញ ក្នុងករណីដែលមានការផ្សះផ្សាបានលទ្ធផលមុនពេលការទាញហេតុផលដោយផ្ទាល់មាត់។ ករណីដែលដកបណ្តឹងមុនពេលចប់កាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ករណីដែលសេចក្តីសម្រេចលើកចោលពាក្យបណ្តឹងដោយមិនបានឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ចូលជាស្ថាពរ គឺសងពាក់កណ្តាលនៃពន្ធដែលបានបង់ហើយទៅឱ្យដើមចោទវិញ[91]។

### ១.២.៣.២ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

បន្ទាប់ពីពន្ធដាក់ពាក្យបណ្តឹង ដើមចោទក៏ត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ។ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធមានដូចជា : ប្រាក់ចាំបាច់ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង និងឯកសារ ឬសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី និងសោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅតុលាការ។ ចំពោះប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ តុលាការត្រូវបង្គាប់ឱ្យភាគី ឬបុគ្គលដែលទាក់ទងរឿងក្តី បង់ចំនួនប្រាក់ជាមុនសិន។[92] ប៉ុន្តែនៅពេលដាក់ពាក្យបណ្តឹង ដើមចោទតែងតែត្រូវតម្រូវឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ មួយចំនួនជាមុន សម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹង ឯកសារផ្សេងៗ ដីកាកោះ និងសោហ៊ុយផ្សេងទៀតដែលចាំបាច់ ហើយដែលអាចប៉ាន់ប្រមាណបានចំនួនទឹកប្រាក់នឹងត្រូវបានកំណត់តាមសភាពជាក់ស្តែង ។ ប្រសិនបើ ដើមចោទពុំបានបង់នូវប្រាក់សម្រាប់បញ្ជូនពាក្យបណ្តឹងទុកជាមុន[93]ទេ តុលាការត្រូវលើកពាក្យបណ្តឹងចោល

[91] មាត្រា ៦១ នៃក្រមដដែល

[92] មាត្រា ៦២ នៃក្រមដដែល

[93] មាត្រា ៧៩ កថាខណ្ឌទី២ នៃក្រមដដែល

ដោយដីកាសម្រេច [94] ។ ម៉្យាងទៀត ប្រសិនបើដើមចោទ មិនព្រមបង់ប្រាក់ចាំបាច់សម្រាប់ការកោះហៅភាគីឱ្យចូលឆ្លើយមកតាមកាលបរិច្ឆេទតាមការបង្គាប់របស់តុលាការទេ តុលាការអាចលើកបណ្ដឹងចោល ដោយដីកាសម្រេច ប្រសិនបើចុងចម្លើយគ្មានការតវ៉ា[95]។

ឧទាហរណ៍ ការបញ្ជូនពាក្យបណ្ដឹងទៅឱ្យចុងចម្លើយ ត្រូវឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ (ប្រាក់បង់ពន្ធក្រៅប្រព័ន្ធ) ចំនួន ១០០.០០០រៀល ។

## ១.៣ ការបែងចែករឿងក្ដី

### ១.៣.១ ការបែងចែករឿងក្ដីតាមលំដាប់ដែលបានកំណត់

នៅតាមតុលាការ ការបែងចែករឿងក្ដី និងលំដាប់សម្រាប់ជំនួស ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ត្រូវកំណត់ជាមុននៅរៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ[96]។ ដោយសារមានដីការសម្រេចនេះចៅក្រមម្នាក់ ឬចៅក្រមប្រឹក្សាជំនុំជម្រះទទួលបន្ទុកជាស្វ័យប្រវត្តិ ដើម្បីដោះស្រាយរឿងក្ដីណាមួយតាមលំដាប់សម្រាប់ចៅក្រមម្នាក់ និងលំដាប់សម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ ។

### ១.៣.២. ការបែងចែករឿងក្ដីទៅឱ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

ចៅក្រមម្នាក់ ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ជំនុំជម្រះរឿងក្ដីមួយ អាស្រ័យទៅតាមប្រភេទនៃរឿងក្ដី ដែលច្បាប់កំណត់ឬភាពស្មុគស្មាញនៃរឿងក្ដី ដែលទទួលស្គាល់ដោយតុលាការ។ ការចែងចែករឿងក្ដីទៅឱ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមមានដូចក្រោម។

(ក) ប្រសិនបើជារឿងក្ដីដែលច្បាប់បានកំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និងជម្រះក្ដីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម រឿងក្ដីនោះត្រូវបែងចែកទៅឱ្យក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសមាសភាពចៅក្រមចំនួនបីរូប ដោយធ្វើតាមលំដាប់នៃការបែងចែករឿងក្ដីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ[97]។ រឿងក្ដីដែលមានកម្មវត្ថុនៃបណ្ដឹងមានតម្លៃមិនតិចជាងប្រាំលានរៀល ហើយដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យ និងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និងបញ្ហាផ្សេងទៀត[98]។ ក្នុងករណីនេះ ការ

---

[94] មាត្រា ៧៨ កថាខណ្ឌទី២ នៃក្រមដដែល

[95] មាត្រា ៨២ កថាខណ្ឌទី១ នៃក្រមដដែល

[96] មាត្រា ២៦ នៃក្រមដដែល

[97] មាត្រា ២៣ កថាខណ្ឌទី៣ នៃក្រមដដែល

[98] មាត្រា ២៣ កថាខណ្ឌទី២ នៃក្រមដដែល

សម្រេចថាតើរឿងក្តីនោះត្រូវវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមម្នាក់ ត្រូវតាមដីកាសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ[99]។

(ខ) គ្រប់រឿងក្តីទាំងអស់លើកលែងតែចំណុច (ក) ខាងលើ ត្រូវធ្វើការបែងចែកទៅឱ្យចៅក្រមម្នាក់ដោយត្រូវធ្វើទៅតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ចៅក្រមម្នាក់។[100]

## ១.៤ ការពិនិត្យពាក្យបណ្តឹង

### ១.៤.១ របៀបពិនិត្យពាក្យបណ្តឹង

ក្រោយពីរឿងក្តីត្រូវបានបញ្ជូនមកចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមរួចហើយ ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមត្រូវពិនិត្យពាក្យបណ្តឹង។ ក្នុងការពិនិត្យពាក្យបណ្តឹង មានលក្ខណៈពីរប្រភេទ ដូចតទៅ ៖

(១) ការពិនិត្យពាក្យបណ្តឹងចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមអាចចេញដីកាបង្គាប់ឱ្យកែតម្រូវ និងចេញដីកាសម្រេចលើកពាក្យបណ្តឹងចោល បើចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមពិនិត្យឃើញថា ការសរសេរក្នុងពាក្យបណ្តឹងមិនទាន់គ្រប់គ្រាន់នៅឡើយ ដោយផ្អែកតាមមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងដើមចោទបានបង់ពន្ធដាក់ពាក្យបណ្តឹងហើយឬនៅ ។

(២) ការពិនិត្យពាក្យបណ្តឹង គឺដើម្បីធ្វើឱ្យនីតិវិធីរឿងក្តីឱ្យបានឆាប់រហ័ស ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ត្រូវពិនិត្យមើលទៅលើ អង្គហេតុនៃការទាមទារ និងអង្គហេតុសំខាន់ដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងសំខាន់ៗជាអាទិ៍ មានសរសេរ និងភ្ជាប់មកជាមួយពាក្យបណ្តឹង។ ការពិនិត្យត្រង់ចំណុចនេះ មានគោលបំណងចាត់ការរឿងក្តីឱ្យមានប្រសិទ្ធិភាពដែលធ្វើឱ្យមានលក្ខណៈងាយស្រួលដល់ការរៀបចំចំណុចវិវាទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ ។ ការពិនិត្យពាក្យបណ្តឹងក្នុងចំណុចនេះ ទោះបីជាដើមចោទមិនព្រមកែតម្រូវក៏ដោយនូវចំណុចដែលគប្បីសរសេរ (មាត្រា ៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក៏ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមមិនអាចលើកពាក្យបណ្តឹងចោលបានទេ ។ ផ្ទុយមកវិញ ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ត្រូវតែកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយត្រូវទាមទារឱ្យដើមចោទពន្យល់បន្ថែមក្នុងកាលបរិច្ឆេទនោះប៉ុណ្ណោះ ។

[99] មាត្រា ២៣ កថាខណ្ឌទី៤ នៃក្រមដដែល

[100] មាត្រា ២៣ កថាខណ្ឌទី១ នៃក្រមដដែល

### ១.៤.២ ដីកាបង្គាប់ឱ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល

#### ១.៤.២.១ ដីការសម្រេចបង្គាប់ឱ្យកែតម្រូវ

តាមបញ្ញត្តិមាត្រា៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលពាក្យ-បណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា៧៥ នៃក្រមដដែល តុលាការកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះ។ ដោយឡែកដីកា-សម្រេចបង្គាប់ឱ្យកែតម្រូវ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលដើមចោទមិនទាន់បានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងនៅឡើយ [101]។

ឧទាហរណ៍ : ដើមចោទ បើមិនបានសរសេរអាសយដ្ឋានរបស់ចុងចម្លើយនៅក្នុងពាក្យបណ្តឹង ជាហេតុមួយធ្វើឱ្យតុលាការមិនអាចបញ្ជូនពាក្យបណ្តឹងរបស់ដើមចោទទៅឱ្យចុងចម្លើយបានទេ ដូច្នេះតុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យដើមចោទកែតម្រូវ។

#### ១.៤.២.២ ដីកាសម្រេចលើកពាក្យបណ្តឹងចោល

តាមបញ្ញតិមាត្រា៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះតាមដីកាសម្រេចបង្គាប់ឱ្យកែតម្រូវទេ (ឧទាហរណ៍៤.១.២.១) តុលាការត្រូវលើកពាក្យបណ្តឹងចោល ដោយដីកាសម្រេច។ ចំពោះដីកាសម្រេចនេះ ដើមចោទអាចប្តឹងជំទាស់បាន[102]។

## ជំពូកទី២ ដំណើរការនៃនីតិវិធីជំនុំជម្រះក្នុងរឿងក្តីរដ្ឋប្បវេណី

## ២.១ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ២.១.១ គោលបំណង នៃនីតិវិធីត្រៀមទាញសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមមួយនៃនីតិវិធីរដ្ឋ-ប្បវេណីដែលធ្វើឡើងដើម្បីផ្តល់ឱកាសដល់តុលាការក្នុងការរៀបចំនូវសេចក្តីអះអាងរបស់ភាគីបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ព្រមស្របគ្នា និងរៀបចំនូវភស្តុតាងដែលទាក់ទង និងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។ នីតិវិធីត្រៀមនេះធ្វើឡើង គឺដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តី និងភស្តុតាង និងដើម្បីកាត់បន្ថយនូវចំណុចវិវាទ ឬកុំឱ្យមានភាពស្មុគស្មាញលើចំណុចវិវាទ។

---

[101] មាត្រា ៦១ នៃក្រមដដែល

[102] មាត្រា ៧៨ កថាខណ្ឌទី៣ នៃក្រមដដែល

ជាគោលការណ៍ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ប៉ុន្តែតុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថា សមរម្យអាចចូលជាអ្នកអង្កេតការណ៍បាន ឧទាហរណ៍: មេធាវី សាច់ញាតិ ឬសហពទ្ធ័ ជាដើម ។ នីតិវិធីនេះ ត្រូវធ្វើនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ព្រោះគោលគំនិតនៃមាត្រា៣ ចំណុចទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា *ក្នុងករណីណាក៏*ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ដែលគោលកាណ៍នេះ តុលាការត្រូវតែគោរព ។

នៅពេលចាប់ផ្តើមធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតុលាការអាចពិនិត្យឃើញថា អង្គហេតុដែលបានសរសេរក្នុងពាក្យបណ្តឹង ក៏ដូចជានៅក្នុងឯកសារត្រៀមមានភាពមិនច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬឱ្យភាគីអះអាង ឬបញ្ជាក់នូវភស្តុតាងចំពោះចំណុចនោះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ។ ភាពច្បាស់លាស់នៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងគឺជាចំណុចសំខាន់ណាស់ ពីព្រោះថា ការអះអាងអំពីអង្គហេតុនោះនឹងក្លាយជាមូលដ្ឋានសម្រាប់តុលាការចេញសាលក្រម ម៉្យាងទៀតវាជាកាតព្វកិច្ចរបស់គូភាគីដែលត្រូវធ្វើការអះអាង[103]។ ដើម្បីឱ្យភាគីអាចបំពេញនូវកាតព្វកិច្ចរបស់ខ្លួនបាននោះ តុលាការអាចសួរអំពីចំណុចមិនច្បាស់លាស់នៃអង្គហេតុដែលភាគីបានអះអាងនេះជាសិទ្ធិរបស់តុលាការ[104]។

នៅពេលបានទទួលពាក្យបណ្តឹង និងក្រោយពីមានការពិនិត្យលើទម្រង់នៃពាក្យបណ្តឹង ឬចំណុចផ្សេងៗទៀតឃើញថាមានលក្ខណៈពេញលេញរួចហើយ និងតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងធ្វើការកោះហៅគូភាគីដែលអំឡុងពេលនោះត្រូវកំណត់៣០ថ្ងៃ[105] បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង លើកលែងតែមានករណីពិសេសដូចជាចៅក្រមទទួលបន្ទុកមានធុរៈ ហើយមិនអាចរកចៅក្រមមកជំនួសបានសម្រាប់អំឡុងពេលនោះ ឬក៏មានហេតុការណ៍ដូចជាគ្រោះធម្មជាតិដែលតុលាការមិនអាចបំពេញភារកិច្ចបានជាដើម ។

ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាការប្តូរកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវបានអនុញ្ញាតទេ លើកលែងតែមានមូលហេតុពិសេសមិនអាចជៀសវាងបានដូចជា ភាគីមានជម្ងឺមិនអាចចូលរួមបានជាដើម។ ប៉ុន្តែប្រសិនបើមានការព្រមព្រៀងពីសំណាក់គូភាគី ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការ

[103] មាត្រា ៩៦ នៃក្រមដដែល

[104] មាត្រា ៩០ នៃក្រមដដែល

[105] មាត្រា ៨០ កថាខណ្ឌទី២ នៃក្រមដដែល

ទាញហេតុផលលើកដំបូងអាចអនុញ្ញាតប្តូរបាន[106]។ នៅពេលផ្លាស់ប្តូរកាលបរិច្ឆេទ តុលាការត្រូវបញ្ជាក់ប្រាប់ទៅគូភាគី ហើយត្រូវកំណត់នូវកាលបរិច្ឆេទថ្មីមួយទៀតដែលគូភាគីអាចចូលរួមបាន ។ នីតិ វិធីត្រៀមសម្រាប់ការទាញហេតុផលនេះ មិនសំដៅទៅលើន័យថា តុលាការត្រូវធ្វើការសើុបសួរដោយសកម្មទៅលើបណ្តឹងនោះទេ គឺមានន័យថាត្រឹមតែឱ្យគូភាគីបំភ្លឺចំណុចវិវាទរបស់ខ្លួនដែលបានលើកឡើងមិនស្របគ្នាប៉ុណ្ណោះ និងធ្វើកិច្ចការត្រៀមមួយចំនួនដូចជា ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន ។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពុំអនុញ្ញាតឱ្យមានការសាកសួរទៅលើសាក្សី និងទៅលើភាគីទេ ប៉ុន្តែតុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង និងអាចពិនិត្យភស្តុតាងជាឯកសារបាន[107] ចំណុចនេះមិនមែនមានន័យថាតុលាការអាចធ្វើការសាកសួរទៅលើភស្តុតាងជាបុគ្គលផ្ទាល់ខ្លួននោះបានទេ តែមានន័យដូចជាការអានឯកសារភស្តុតាងនោះដោយថៅក្រមជាដើម ព្រោះថាដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីបានត្រឹមត្រូវ ភាគច្រើនតុលាការត្រូវរកភស្តុតាងជាឯកសារ ដូចនេះហើយបានជាច្បាប់អនុញ្ញាតឱ្យតុលាការពិនិត្យភស្តុតាងជាឯកសារ នៅក្នុងកម្រិតចាំបាច់ដើម្បីរៀបចំនៅចំណុចវិវាទនៃរឿងក្តីប៉ុណ្ណោះ ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចផ្តល់ឱ្យតុលាការទទួលបាននូវព័ត៌មានទាក់ទងនឹងចំណុចវិវាទដូចតទៅ :

(ក) ការអះអាងអាង និងការទាមទាររបស់ភាគី ។

(ខ) ភាគីទទួលស្គាល់ចំណុចណាខ្លះ និងចំណុចណាខ្លះដែលមិនទទួលស្គាល់ ។

(គ) ចំណុចដែលមានវិវាទត្រូវបញ្ជាក់ដោយភស្តុតាងណាខ្លះ ។

ដើម្បីរៀបចំ និងគ្រប់គ្រងការអះអាងរបស់ភាគី និងបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា[108] នោះជាកត្តាចាំបាច់ និងសំខាន់ដែលត្រូវស្តាប់នូវការអះអាងរបស់ភាគីទាំងពីរដោយផ្ទាល់។ អ្វីដែលភាគីទាំងពីរបាននិយាយក្នុងដំណាក់នេះគឺជាការអះអាង វាមិនមែនជាភស្តុតាងនៃរឿងក្តីទេ ។

[106] មាត្រា ២៤១ នៃក្រមដដែល

[107] មាត្រា ១០៦ នៃក្រមដដែល

[108] មាត្រា ១០៣ នៃក្រមដដែល

### ២.១.២ សកម្មភាពក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[109]

ក្រមនីតិវិធីរដ្ឋប្បវេណី ពុំបានកំណត់ថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ អាចធ្វើឡើងប៉ុន្មានដងនោះទេ ដូច្នេះអាចកំណត់បានថា វាអាចធ្វើឡើងច្រើនដំណាក់កាលបាន គឺអាស្រ័យទៅតាមប្រភេទនៃរឿងក្តី បើរឿងក្តីមានលក្ខណៈស្មុគស្មាញ នោះតុលាការអាចធ្វើនីតិវិធីត្រៀមនេះច្រើនដង ផ្ទុយទៅវិញបើរឿងក្តីដែលមានលក្ខណៈងាយស្រួលនោះនីតិវិធីត្រៀមនេះអាចធ្វើតែម្តងហើយចប់ក៏មានដែល ឱ្យតែតុលាការអាចកំណត់បាននូវចំណុចវិវាទនៃរឿងក្តី។ សមាសភាពចូលរួមក្នុងនីតិវិធីនេះត្រូវមាន ចៅក្រម ក្រឡាបញ្ជី ដើមចោទ និង/ឬ មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ និងចុងចម្លើយ និង/ឬមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ ជាដើម។

#### ២.១.២.១ ការសាកល្បងផ្សះផ្សា

ពន្យល់នៅជំពូកទី៣ ការសះជាតាមផ្លូវបណ្តឹង ចំណុច ៣.៣ ការសាកល្បងផ្សះផ្សា ។

#### ២.១.២.២ សេចក្តីថ្លែងការណ៍របស់គូភាគី

**ក-** ដំបូងតុលាការត្រូវឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ដូចតទៅនេះ

- សេចក្តីថ្លែងការណ៍ អំពីសាលក្រមដែលដើមចោទទាមទារ ។
- សេចក្តីថ្លែងការណ៍ អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។
- សេចក្តីថ្លែងការណ៍ អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ សេចក្តីថ្លែងការណ៍ អំពីអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលមូលហេតុនៃការទាមទារដោយផ្អែកលើបណ្តឹង ។

**ឧទាហរណ៍ :**

**១. សេចក្តីថ្លែងការណ៍ អំពីសាលក្រមដែលដើមចោទទាមទារ**

ខ្ញុំបាទឈ្មោះ "ក" ខ្ញុំបាទសូមជម្រាបជូនលោកចៅក្រមមេត្តាជ្រាបថាៈ ខ្ញុំបាទសុំឱ្យលោកចៅក្រមចេញសាលក្រមឱ្យចុងចម្លើយឈ្មោះ ខ ប្រគល់ប្រាក់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក)មកឱ្យខ្ញុំបាទវិញ ។

**២.សេចក្តីថ្លែងការណ៍ អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ**

ខ្ញុំបាទបានលក់ដី (x)ទៅឱ្យចុងចម្លើយឈ្មោះ ខ ក្នុងតម្លៃ ៣០០.០០០$ (បីរយពាន់ដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៨។ ចុងចម្លើយបានប្រគល់ប្រាក់ក្នុងដំណាក់កាលទី១ និងទី២ ជូនដើមចោទ

[109] មាត្រា ១០៤ និងមាត្រា ១១២ នៃក្រមដដែល

រួចហើយ ប៉ុន្តែចុងចម្លើយមិនទាន់បានប្រគល់ប្រាក់បង្គ្រប់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) ក្នុងដំណាក់កាលទី៣ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ មកឱ្យដើមចោទនៅឡើយទេ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

**៣.សេចក្តីថ្លែងការណ៍ អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ សេចក្តីថ្លែងការណ៍ អំពីអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលមូលហេតុនៃការទាមទារដោយផ្អែកលើបណ្តឹង**

ខ្ញុំបាទបានផ្ទេរសិទ្ធិលើដី (x) ទៅឱ្យចុងចម្លើយរួចហើយ ប៉ុន្តែចុងចម្លើយមិនទាន់បានប្រគល់ប្រាក់បង្គ្រប់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) មកឱ្យខ្ញុំបាទនៅឡើយទេ រហូតមកដល់បច្ចុប្បន្ន ដូចមានក្នុងដំណាក់កាលទី៣ នៃកិច្ចសន្យាទិញលក់ផ្ទះចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៨ ។

**ខ**-ត្រូវឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ នូវខ្លឹមសារនៃឯកសារត្រៀមរបស់ចុងចម្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារ ដោយដើមចោទ។

**គ**- ត្រូវឱ្យដើមចោទ ធ្វើសេចក្តីថ្លែងការណ៍តបនឹងឯកសារត្រៀមរបស់ចុងចម្លើយ។

**ឃ**- ត្រូវឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍តបអំពីឯកសារត្រៀមរបស់ដើមចោទវិញ។

ដូចនេះ បើសិនភាគីណាមួយដាក់ឯកសារត្រៀមផ្សេងទៀតនោះ ខ្លឹមសារនៃឯកសារនោះត្រូវលើកយកមកនិយាយដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ ការដាក់ឯកសារត្រៀមនេះ គួរឱ្យដាក់នៅមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដើម្បីឱ្យភាគីដែលជំទាស់នឹងតុលាការអាចអាន និងយល់នូវខ្លឹមសារនៃការអះអាងក្នុងឯកសារត្រៀមនោះដែលអាចធ្វើឱ្យការពិភាក្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានភាពលម្អិត ម៉្យាងវិញទៀតឯកសារត្រៀមនេះមានសារៈសំខាន់សម្រាប់ដំណើរការដោះស្រាយបណ្តឹងឱ្យបានឆាប់រហ័ស ។

ការឆ្លើយតបរបស់ចុងចម្លើយចំពោះការទាមទារដោយដើមចោទអាចមានច្រើនបែបគឺ

- ការឆ្លើយតបរបស់ចុងចម្លើយ ដោយទាមទារឱ្យច្រានចោលនូវការទាមទាររបស់ដើមចោទ ដូចនេះតុលាការត្រូវធ្វើការជំនុំជម្រះ ហើយចេញសាលក្រមស្តីពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារនោះ[110] ហេតុនេះតុលាការត្រូវធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាព នៃសិទ្ធិទាមទាររបស់ដើមបណ្តឹង ពោលគឺ តុលាការត្រូវធ្វើការទទួលស្គាល់ដោយផ្អែកលើភស្តុតាង[111] ។

---

[110] មាត្រា ១៨២ នៃក្រមដដែល

[111] មាត្រា ១២៣ ចំណុចទី១ នៃក្រមដដែល

- ចុងចម្លើយថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាព នៃអង្គហេតុដែលជាមូលហេតុនៃការទាមទារ ក្នុងករណីនេះមានន័យថាជាករណី **អង្គហេតុដែលភាគីបានសារភាព**[112] ដូច្នេះអង្គហេតុ ត្រូវទទួលស្គាល់តែម្តង ដោយមិនចាំបាច់ធ្វើការទទួលស្គាល់ដោយផ្អែកលើភស្តុតាងទេ ។
- ចុងចម្លើយថ្លែងការណ៍មិនដឹងអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលជាមូលហេតុនៃការទាមទារករណីនេះអាចសន្មត់ថា ចុងចម្លើយតវ៉ាចំពោះអង្គហេតុនោះ[113] ដូច្នេះដើម្បីធ្វើការទទួលស្គាល់អង្គហេតុនោះ តុលាការត្រូវធ្វើការទទួលស្គាល់ដោយផ្អែកលើភស្តុតាង ។
- ចុងចម្លើយមិនឆ្លើយអ្វីទាំងអស់ អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលជាមូលហេតុនៃការទាមទារជាការស្ងៀមស្ងាត់ ក្នុងករណីបើមើលតាមអាកប្បកិរិយារបស់ចុងចម្លើយទៅមិនឃើញថា មានវិវាទទេនោះអាចចាត់ទុកបានថាចុងចម្លើយបានសារភាពអង្គហេតុនោះ[114] អង្គហេតុនេះត្រូវបានទទួលស្គាល់តែម្តងដោយមិនចាំបាច់ធ្វើការទទួលស្គាល់ដោយភស្តុតាងទេ ។

នៅកាលបរិច្ឆេទនៃដំណាក់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងទៀតបានដូចជា ដីកាសម្រេចបង្គាប់ឱ្យដាក់ឯកសារដើម និងអាចពិនិត្យភស្តុតាងជាឯកសារបានក្នុងកម្រិតចាំបាច់ដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តី និងភស្តុតាង[115]។ ក្នុងដំណាក់កាលនេះដែរ ក៏តុលាការអាចបង្គាប់ឱ្យគូភាគីដាក់ឯកសារត្រៀមបានដែរ[116] គឺអាចបង្គាប់ដោយផ្ទាល់មាត់ ឬអាចបង្គាប់ជាលាយលក្ខអក្សរ ដោយកំណត់អំឡុងពេលដែលដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬឯកសារត្រៀមដែលបានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទាក់ទង និងចំណុចជាក់លាក់ណាមួយ។[117]

ជាគោលការណ៍ការពិនិត្យភស្តុតាងត្រូវធ្វើនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែភាគីអាចស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញ

[112] មាត្រា ១២៣ នៃក្រមដដែល

[113] មាត្រា ៩៦ ចំណុចទី២ នៃក្រមដដែល

[114] មាត្រា ១២៣ ចំណុចទី២ នៃក្រមដដែល

[115] មាត្រា ១០៦ នៃក្រមដដែល

[116] មាត្រា ១០១ នៃក្រមដដែល

[117] មាត្រា ១០២ នៃក្រមដដែល

ហេតុផលបាន ក៏ប៉ុន្តែក្នុងពេលនេះភស្តុតាងដែលអាចទទួលយកមកពិនិត្យបានមានតែភស្តុតាងជាឯកសារដែលចាំបាច់សម្រាប់បញ្ជាក់នូវអង្គហេតុណាមួយប៉ុណ្ណោះ ចំពោះសាក្សីតុលាការអាចចេញដីកាសម្រេចថា ទទួលសាក្សីណាមួយមកសាកសួរ តែការសាកសួរត្រូវធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ភាគីដែលស្នើសុំឱ្យសាកសួរសាក្សីត្រូវភ្ជាប់ជាមួយនូវឯកសារដែលបញ្ជាក់ពីចំណុចសាកសួរ[118]។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការបញ្ជាក់របស់គូភាគីពុំចាត់ទុកជាភស្តុតាងឡើយ គេចាត់ទុកថាជាការអះអាង។

### ២.១.៣ ការរៀបចំចំណុចវិវាទ និងការប្រើសិទ្ធិរបស់តុលាការ

សិទ្ធិបំភ្លឺនេះ តុលាការអាចប្រើបានបើយល់ឃើញថា ការអះអាងរបស់ភាគីមិនច្បាស់លាស់ ឬការអះអាងការបញ្ជាក់ភស្តុតាងមិនគ្រប់គ្រាន់ដែលធ្វើឱ្យតុលាការមិនអាចក្តាប់បានពីអត្ថន័យ ។ ការប្រើប្រាស់សិទ្ធិបំភ្លឺនេះ គឺដើម្បីឱ្យចំណុចនៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងមានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬឱ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាងចំពោះចំណុចនេះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការទាញហេតុផលដោយផ្ទាល់មាត់បាន ក៏ប៉ុន្តែនៅក្រៅពីកាលបរិច្ឆេទនេះ តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺ នៅកាលបរិច្ឆេទបន្ទាប់ ដោយបញ្ជាក់ចំណុចដែលតុលាការយល់ឃើញថា ត្រូវការឱ្យបំភ្លឺជាចាំបាច់។ ជាគោលការណ៍ ភាគីត្រូវធ្វើការអះអាងអង្គហេតុ និងដាក់ភស្តុតាងដែលជាមូលដ្ឋានសម្រាប់ចេញសាលក្រម ។

### ២.១.៤ ការស្នើសុំជូនពិនិត្យភស្តុតាង

ជាគោលកាណ៍ ការពិនិត្យភស្តុតាងត្រូវធ្វើឡើងតាមការស្នើសុំរបស់គូភាគី ប៉ុន្តែក្នុងករណីចាំបាច់តុលាការអាចពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ហើយអាចធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ។ ភស្តុតាងមានពីរប្រភេទគឺ ភស្តុតាងជាឯកសារ និងភស្តុតាងជាសាក្សី ។

ភាគីត្រូវមានករណីកិច្ចស្រាវជ្រាវឱ្យបានលម្អិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និងភស្តុតាងផ្សេងៗទៀតដើម្បីធ្វើការអះអាងក្នុងបណ្តឹងរបស់ខ្លួន។ តុលាការអាចចេញដីកាសម្រេចទាក់ទងស្នើសុំឱ្យពិនិត្យភស្តុតាងនេះ "ពាក្យដីកាសម្រេចក្នុងក្រមនេះពុំតម្រូវចាំបាច់ឱ្យសរសេរជាលាយលក្ខអក្សរទេ អាចធ្វើដោយផ្ទាល់មាត់បាន ព្រោះគូភាគីមានវត្តមានទាំងអស់គ្នាតែត្រូវចុះក្នុងកំណត់ហេតុ"។ ចំពោះភស្តុតាងដែលអាចទទួលយកមកពិនិត្យ ក្រៅពីកាលបរិច្ឆេទ

[118] មាត្រា ១៨ ចំណុចទី២ នៃក្រមដដែល

នៃការទាញហេតុផលដោយផ្ទាល់មាត់បាន **គឺមានតែភស្តុតាងជាឯកសារក្នុងកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង**ប៉ុណ្ណោះ។ [119]

**ពាក្យស្នើសុំគំរូ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំជូនពិនិត្យភស្តុតាង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ កកក អាយុ.....ឆ្នាំ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត...........

**សូមគោរពជូន**

**លោក**......................**ចៅក្រមដំបូងរាជធានីភ្នំពេញ/ខេត្ត**..............

**កម្មវត្ថុ៖** ស្នើសុំជូនពិនិត្យភស្តុតាង ។

**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី.....ខែ.....ឆ្នាំ...របស់សាលាដំបូងរាជធានី/ខេត្ត......។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជូនភស្តុតាងជាឯកសារថតចម្លង និងសាក្សីដូចមានខាងក្រោម ៖

**ក. ឯកសារថតចម្លង**

១..........................................................................................(ចំនួន០១ច្បាប់)

២..........................................................................................(ចំនួន០១ច្បាប់)

**ខ. សាក្សី**

១. ឈ្មោះ...........អាយុ......ភេទ...... មុខរបរ..............ទីលំនៅបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត...........

២. ឈ្មោះ............អាយុ......ភេទ...... មុខរបរ............ទីលំនៅបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត...........

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាទទួលពិនិត្យនូវពាក្យជូនពិនិត្យភស្តុតាងរបស់ខ្ញុំបាទ/នាងខ្ញុំតាមច្បាប់ ដោយក្តីអនុគ្រោះ ។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ................. កើត/រោច ខែ............. ឆ្នាំ....... ............ស័ក ព.ស. ២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.................. ឆ្នាំ២០..........

**ស្នាមមេដៃស្តាំ**

## ២.១.៥ ការបញ្ចប់នៃនីតិវិធីរឿងត្រៀមសម្រាប់ការទាញហេតុផល និងអានុភាព

ក្នុងករណីដែលនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីមួយ មិនអាចបញ្ចប់បានទេ នោះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមលើកទីពីរទៀត តែពេលបញ្ចប់នីតិវិធីត្រៀមនីមួយៗ តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹង

[119] មាត្រា ១០៦ នៃក្រមដដែល

ត្រូវបំភ្លឺនៅពេលក្រោយ ។ ផ្ទុយទៅវិញនៅពេលដែលភាគី និងតុលាការមានការបញ្ជាក់ថា តើអ្វីទៅដែលជាចំណុចវិវាទ ហើយតើចាំបាច់ដើម្បីធ្វើការបញ្ជាក់ភស្តុតាងយ៉ាងណាដែលពាក់ព័ន្ធនឹងចំណុចវិវាទនោះ[120] មានន័យថា ចំណុចវិវាទនៃរឿងក្តី និងភស្តុតាងត្រូវបានរៀបចំរួចហើយចំណុចវិវាទបានរកឃើញ នោះនីតិវិធីត្រៀមត្រូវបញ្ចប់។ តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីលទ្ធផលនៃការរៀបចំនេះ ដើម្បីឲ្យមានការឯកភាពគ្នា ព្រមទាំងបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺដើម្បីត្រៀមធ្វើការពិនិត្យលើភស្តុតាងឲ្យបានល្អិតល្អន់ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នាពេលខាងមុខ។ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ទាញហេតុផល តុលាការអាចសម្រេចកំណត់ឲ្យភាគីដាក់ភស្តុតាងដោយកំណត់រយៈពេលសមរម្យអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងរបស់ភាគី នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ។

ក្រោយពីនីតិវិធីនេះបានបញ្ចប់ ភាគីមិនអាចដាក់មធ្យោបាយថ្មីបានទៀតទេ[121] ដូចនេះ មុនពេលបញ្ចប់នីតិវិធីត្រៀម តុលាការត្រូវបញ្ជាក់ជាមួយគូភាគីថា តើបានដាក់មធ្យោបាយការពារ និងមធ្យោបាយតទល់គ្រប់គ្រាន់ហើយឬនៅ? ក៏ប៉ុន្តែក្នុងករណីពិសេស តុលាការអាចទទួលយកភស្តុតាងថ្មីបាន ដូចជាៈ

-ចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ។

-ការដាក់មធ្យោបាយតទល់ថ្មីមិនធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង។

-ភាគីបានបញ្ជាក់ជាមុនថា មិនអាចដាក់មធ្យោបាយនោះមុនបានបញ្ចប់ តុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគី និងសាក្សីឲ្យមកចូលរួម[122]។

---

[120] មាត្រា ១០៧ នៃក្រមដដែល

[121] មាត្រា ១០៨ នៃក្រមដដែល

[122] មាត្រា ១១៣ នៃក្រមដដែល

| រូបសញ្ញាសាលាដំបូងរាជធានី/ខេត្ត... | ព្រះរាជាណាចក្រកម្ពុជា<br>ជាតិ សាសនា ព្រះមហាក្សត្រ | នីតិវិធីត្រៀម...គំរូ |
|---|---|---|

**កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល**

| | |
|---|---|
| រឿងក្តីរដ្ឋប្បវេណីលេខ | ៖ .......ចុះថ្ងៃទី.......ខែ.......ឆ្នាំ................ |
| សញ្ញាណនៃរឿងក្តី | ៖ ប្តឹងសុំចេញសាលក្រម...................... |
| កាលបរិច្ឆេទ | ៖ ថ្ងៃទី.......ខែ..........ឆ្នាំ........... |
| ទីកន្លែង | ៖ សាលាដំបូងរាជធានី/ខេត្ត............ |
| ចៅក្រម | ៖ លោក........................... |
| ក្រឡាបញ្ជី | ៖ លោក........................... |

**ក. គូភាគីដែលបានបង្ហាញខ្លួន**

ដើមចោទ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ... ផ្លូវលេខ..... ភូមិ...... សង្កាត់...... ខណ្ឌ........ រាជធានីភ្នំពេញ/ខេត្ត...........

អ្នកតំណាងដោយអាណត្តិលោកមេធាវី .............. (ប្រសិនបើមានមេធាវីតំណាងដោយអាណត្តិឲ្យ)

ចុងចម្លើយ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ... ផ្លូវលេខ... ភូមិ........ សង្កាត់...... ខណ្ឌ........ រាជធានីភ្នំពេញ/ខេត្ត...........

អ្នកតំណាងដោយអាណត្តិលោកមេធាវី .............. (ប្រសិនបើមានមេធាវីតំណាងដោយអាណត្តិឲ្យ)

កម្មវត្ថុបណ្តឹង: ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច៖

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ...........
២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ...................
៣. ..............
៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ. ការអះអាងរបស់គូភាគី**

+ ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖.......................................................................
..........................................................................................................................
.........................................................................................................................។

+ ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖...................................................................
..........................................................................................................................
.........................................................................................................................។

+ ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍តបថា៖................................................................
..........................................................................................................................
.........................................................................................................................។

+ ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា៖...............................................................................
..................................................................................................................................................
..................................................................................................................................................។

**គ. ចំណុចវិវាទ**

១. តើការទាមទារ..........................................របស់ដើមចោទមានភាពត្រឹមត្រូវ និងមូលដ្ឋានដែលអាចឱ្យតុលាការពិចារណា និងសម្រេចដែរឬទេ?

២. តើ..................................................................................... ?

៣. តើ..................................................................................... ?

+តុលាការសម្រេចកំណត់ឱ្យភាគីដាក់ភស្តុតាងមិនឱ្យហួសថ្ងៃទី..........ខែ..........ឆ្នាំ........ វេលាម៉ោង ៥ និង ០០ នាទីល្ងាច ។

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍ចប់សព្វគ្រប់។
តុលាការសម្រេចបញ្ចប់កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនៅថ្ងៃនេះ។
បញ្ចប់កំណត់ហេតុនៅម៉ោង..............នាទី ថ្ងៃខែឆ្នាំ ដដែល។

**ស្នាមមេដៃស្តាំរបស់ដើមចោទ** **ស្នាមមេដៃស្តាំរបស់ចុងចម្លើយ**

**ក្រឡាបញ្ជី** **ចៅក្រម**

## ២.២ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង

### ២.២.១ គោលបំណង

ដើម្បីចេញសាលក្រមទៅបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់[123]។ គោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ តម្រូវឲ្យភាគីបញ្ចេញមតិរបស់ខ្លួនអំពីអង្គហេតុ និងចំណុចផ្សេងៗទៀតដែលនឹងត្រូវវិនិច្ឆ័យដោយតុលាការ និងធ្វើការឆ្លើយតបទៅនឹងមតិដែលថ្លែងដោយភាគីម្ខាងទៀតដែលបានអះអាងដោយយុត្តិធម៌ និងដោយសមធម៌ មុនពេលតុលាការសម្រេចសេចក្តីទៅលើបណ្តឹងនោះ ។

[123] មាត្រា ១១៤ នៃក្រមដដែល

ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធានាឲ្យមានប្រសិទ្ធិភាព និងឱកាសនៃសិទ្ធិទាមទារឲ្យសាកសួរដែលគូភាគីអាចមានវត្តមាននៅកាលបរិច្ឆេទចំពោះមុខគ្នាទៅវិញទៅមក និងធ្វើការថ្លែងការណ៍ និងសាកសួរដោយផ្ទាល់មាត់ក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីឲ្យតុលាការមានភាពងាយស្រួលស្វែងរកការពិតដើម្បីធ្វើការវិនិច្ឆ័យលើបណ្ដឹង។ ដូច្នេះក្នុងករណីណាក៏ដោយ *តុលាការត្រូវគោរពទៅតាមគោលការណ៍ចំពោះមុខ*[124] ហើយផ្ដល់ឱកាសឲ្យភាគីទាំងសងខាងធ្វើការអះអាងដោយខ្លួនឯង ពោលគឺតុលាការត្រូវកំណត់កាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។ ប្រសិនបើតុលាការកោះហៅភាគីតែម្ខាងសួរ និងស្ដាប់យោបល់តែភាគីម្ខាងដោយគ្មានវត្តមានរបស់ភាគីម្ខាងទៀត អាចនឹងធ្វើឲ្យការសម្រេចសេចក្ដីរបស់តុលាការពុំមានភាពត្រឹមត្រូវ។

### ២.២.២ សកម្មភាពក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់

#### ២.២.២.១ ការថ្លែងអំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ

នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងត្រូវធ្វើឡើងដោយចង្អុលបង្ហាញឲ្យបានច្បាស់លាស់ នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្ដុតាងនៅពេលក្រោយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់[125] មានន័យថាគូភាគីថ្លែងការណ៍អំពីខ្លឹមសារនៃការអះអាងអង្គហេតុរបស់ភាគី ការរៀបចំចំណុចវិវាទ និងការពិនិត្យភស្ដុតាងជាឯកសារ ដែលត្រូវបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែដោយសារ ការធ្វើសេចក្ដីថ្លែងការណ៍នេះមិនមែនជាសកម្មភាពនៃបណ្ដឹង ដូចនេះមិនចាំបាច់ដាក់កំហិតដាច់ខាតឱ្យគូភាគីធ្វើសេចក្ដីថ្លែងការណ៍នោះទេ ដោយសារគ្រប់សកម្មភាពការងារ ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលសុទ្ធតែមាននៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះស្រាប់។ ក្នុងករណីនេះ តុលាការអាចធ្វើសេចក្ដីថ្លែងការណ៍សង្ខេបពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះបានហើយសួរបញ្ជាក់គូភាគីថាតើយល់ព្រម ឬទេ ក្រោយពេលដែលតុលាការបានលើករួចមកនេះ។ នេះគឺជានីតិវិធីមួយដែលត្រូវធ្វើឡើងដោយយកសកម្មភាពដែលបានធ្វើក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទាំងស្រុង ដូចជាការអះអាងអង្គហេតុរបស់ភាគី ការរៀបចំចំណុច

---

[124] មាត្រា ៣ នៃក្រមដដែល

[125] មាត្រា ១១៦ នៃក្រមដដែល

វិវាទ និងការពិនិត្យភស្តុតាងជាឯកសារមកដាក់ក្នុងកម្មវត្ថុនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តង ដើម្បីយកមកធ្វើជាឯកសារមូលដ្ឋាននៃការចេញសាលក្រម ។

### ២.២.២.២ ការពិនិត្យភស្តុតាងដោយសមូហវិធី

#### ក. ភាពចាំបាច់នៃការពិនិត្យភស្តុតាងដោយសមូហវិធី

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និង ភស្តុតាងរួចហើយ តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាប់បាន[126]។ ការសាកសួរទៅលើសាក្សី ឬសាមីភាគី បើអាចធ្វើបានត្រូវដោយសមូហវិធី[127]។ តាមរយៈការពិនិត្យភស្តុតាងដោយសមូហវិធី តុលាការ នឹងអាចធ្វើការវិនិច្ឆ័យបានត្រឹមត្រូវ ហើយបានលឿន ដោយផ្អែកលើជំនឿចិត្តថ្មីៗ ។

ឧទាហរណ៍: នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានសាកសួរសាក្សីឈ្មោះ "គ" សាមីខ្លួនចុងចម្លើយ និងសាមីខ្លួនដើមចោទ ។

#### ខ. ការសាកសួរសាក្សី

សាក្សី គឺជាតតិយជនដែលត្រូវតុលាការបញ្ជាឲ្យធ្វើរបាយការណ៍ជូនតុលាការ ស្តីពីអង្គហេតុក្នុងអតីតកាល ដែលខ្លួនបានជួបប្រទះដោយខ្លួនឯងនៅក្រៅបណ្តឹង ។ ជាគោលការណ៍ជនដែលត្រូវបានកោះហៅជាសាក្សី ត្រូវបង្ហាញខ្លួនចំពោះមុខតុលាការ ត្រូវធ្វើសម្បថ[128]ហើយមានករណីយកិច្ចឆ្លើយជាកសិណសាក្សី ។ ក្នុងករណីដែលសាក្សីគ្មានវត្តមានចំពោះមុខតុលា-ការតាមការកោះហៅដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចបង្គាប់ឲ្យនាំខ្លួនសាក្សីនោះបាន ដោយដីកាសម្រេច[129]។ សាក្សីត្រូវឆ្លើយប្រាប់តុលាការនូវអង្គហេតុដែលខ្លួនបានជួបផ្ទាល់ ហើយមិនអាចឲ្យអ្នកផ្សេងឆ្លើយជំនួសខ្លួនបានឡើយ ។

សាក្សីអាចបដិសេធក្នុងការផ្តល់ចម្លើយជាកសិណសាក្សីបាន ចំពោះចំណុចដែលអាចធ្វើឲ្យសាមីខ្លួន ឬសហព័ទ្ធរបស់សាក្សី ឬញាតិដទៃទៀតទទួលរងគ្រោះនូវការចោទប្រកាន់ពីបណ្តឹងអាជ្ញា ឬទទួលការផ្តន្ទាទោស ឬមានការពាក់ព័ន្ធចំពោះចំណុចដែលត្រូវជាការសម្ងាត់ក្នុងមុខនាទីរបស់សាក្សី[130]។

---

[126] មាត្រា ១២៧ កថាខណ្ឌទី១ នៃក្រមដដែល

[127] មាត្រា ១២៧ កថាខណ្ឌទី ២ នៃក្រមដដែល

[128] មាត្រា ១៣៧ នៃក្រមដដែល

[129] មាត្រា ១៣២ នៃក្រមដដែល

[130] មាត្រា ១៣៤ នៃក្រមដដែល

ជាគោលការណ៍ ការសាកសួរសាក្សីត្រូវធ្វើឡើងនៅតុលាការដែលចាត់ការបណ្តឹងនោះ នៅក្នុងសាលសវនាការដែលបើកឡើងជាសាធារណៈ ក៏ប៉ុន្តែក្នុងករណីដែលសាក្សីមិនអាចបង្ហាញខ្លួនចំពោះមុខតុលាការ ដោយសារជម្ងឺ ឬដោយសារចាស់ជរា តុលាការអាចធ្វើការសាកសួរពិសេសក្រៅតុលាការបាន។ ក្នុងករណីនេះ តុលាការអាចឲ្យចៅក្រមម្នាក់ក្នុងចំណោមចៅក្រមដែលជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះ ឬក៏ឲ្យចៅក្រមនៃតុលាការផ្សេង ទៅសាកសួរសាក្សីបាន[131]។

### គ. ការសាកសួរភាគី[132]

ការសាកសួរភាគី គឺជាការពិនិត្យភស្តុតាងដែលធ្វើឡើងដោយតុលាការដើម្បីទទួលនូវភស្តុតាងលើសាមីភាគី ដោយឲ្យធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបផ្ទាល់នោះ តាមការស្នើសុំ ឬតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ក្រោមគោលការណ៍នៃការទាញហេតុផល ប្រសិនបើសាមីភាគីមិនបានអះអាងក្នុងការទាញហេតុផលទេ តុលាការមិនអាចយកសេចក្តីថ្លែងការណ៍ពីមុនមកគិតពិចារណាធ្វើការវិនិច្ឆ័យក្នុងការចេញសាលក្រមបានឡើយ ។

ចំពោះនីតិវិធីយកសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដែលច្បាប់បានកំណត់(នីតិបុគ្គល អនីតិជន ជននៅក្រោមអាណាព្យាបាល) ឬអ្នកតំណាងដោយអាណត្តិ គឺត្រូវធ្វើតាមនីតិវិធីសាកសួរភាគី ដោយចាត់ទុកថាជនទាំងនោះដូចសាមីភាគីដែរ ។

### ឃ. ការធ្វើកោសល្យវិច័យ[133]

ការធ្វើកោសល្យវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការកំណត់ឲ្យអ្នកធ្វើកោសល្យវិច័យដែលមានចំណេះវិជ្ជា និងបទពិសោធន៍ពិសេស ឲ្យធ្វើរបាយការណ៍អំពីរូបមន្តនៃបទពិសោធន៍ដែលខ្លួនបានដឹងតាមចំណេះវិជ្ជា និងបទពិសោធន៍របស់ខ្លួនចំពោះអង្គហេតុជាក់ស្តែងដែលជាបញ្ហានៅក្នុងបណ្តឹងនោះ។ តុលាការជាអ្នកកំណត់អ្នកធ្វើកោសល្យវិច័យ ហើយជនដែលមានចំណេះវិជ្ជា និងបទពិសោធន៍ត្រូវទទួលខុសត្រូវក្នុងការធ្វើកោសល្យវិច័យ ក៏ប៉ុន្តែតាមធម្មតា ក្រៅពីជនដែលតុលាការបានកំណត់ជាអ្នកធ្វើកោសល្យវិច័យនេះ ក៏មានជនផ្សេងទៀត ដែលមានចំណេះវិជ្ជា និងបទពិសោធន៍ប្រហាក់ប្រហែលគ្នាដែរ ហេតុនេះហើយ មិនចាំបាច់ធ្វើការពិនិត្យភស្តុតាងដោយមានការបង្ខំឲ្យធ្វើកោសល្យវិច័យនោះចូលតុលាការដូចសាក្សីទេ។

---

[131] មាត្រា ១៣៦ នៃក្រមដដែល

[132] មាត្រា ១៤០ និង១៤២ នៃក្រមដដែល

[133] មាត្រា ១៤៣ និង១៤៧ នៃក្រមដដែល

ដោយឡែកក្នុងករណីដែលមានហេតុរារាំងដល់សច្ចភាពនៃការធ្វើកោសល្យវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងផាត់ចោលអ្នកធ្វើកោសល្យវិច័យនោះបាន ។

### ង. ភស្តុតាងជាឯកសារ

ឯកសារមានអានុភាពសំខាន់សម្រាប់បញ្ជាក់អង្គហេតុដែលកំពុងមានវិវាទ។ គេអាចបែងចែកឯកសារជាច្រើនប្រភេទៈ

-ឯកសារសាធារណៈ និងឯកសារឯកជន

ឧទាហរណ៍ : វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ១២៣៨៤-៩៨៧៧១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ ស្ថិតនៅក្នុងភូមិ២០ សង្កាត់ បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ របស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។ កិច្ចសន្យាទិញលក់ដី រវាងលោក "ក" និងលោក "ខ" ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ ១២៣៨៤-៩៨៧៧១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ ស្ថិតនៅក្នុងភូមិ ២០ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ របស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ។

-ឯកសាររវាងឯកជន និងឯកសារយថាភូត

ឧទាហរណ៍ៈ កិច្ចសន្យាទិញលក់ដី រវាងលោក "ក" និងលោក "ខ" ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ១២៣៨៤-៩៨៧៧១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ ស្ថិតនៅក្នុងភូមិ២០ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤។ និង កិច្ចសន្យាទិញលក់ដីនេះ ដោយលោកចៅសង្កាត់ បឹងកក់ទី២ បានចុះលេខ និងហត្ថលេខា ដែលមានលេខ ២៦/តរឌ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ ។

### ច. ការត្រួតពិនិត្យ

ការត្រួតពិនិត្យ គឺជាការបញ្ជាក់ភស្តុតាងដើម្បីទទួលបាននូវឯកសារភស្តុតាង ដោយការពិនិត្យនូវភិនភាគ ឬបាតុភូតនៃវត្ថុដោយផ្ទាល់ ដោយចៅក្រម ដោយប្រើវិញ្ញាណប្រាំរបស់ខ្លួន (ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ)[134] ហើយវត្ថុ ឬមនុស្សដែលជាកម្មវត្ថុនោះគេហៅថា វត្ថុដែលត្រូវត្រួតពិនិត្យ ។

### ២.២.២.៣ ការផ្សះផ្សា

ពន្យល់នៅជំពូកទី៣ ការសះជាតាមផ្លូវបណ្តឹង ៣.៣ ការសាកល្បងផ្សះផ្សា ។

[134] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ឆ្នាំ ២០០៨ វគ្គ ៣-២-៣-៦-៦ ទំព័រទី ១២២

### ២.២.២.៤ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់[135]

នៅពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ហើយ តុលាការត្រូវធ្វើការប្រកាសអំពីសេចក្តីសម្រេច ប៉ុន្តែតុលាការអាចអនុញ្ញាតឲ្យភាគីម្នាក់ៗ ធ្វើការទាញហេតុផលចុងក្រោយបាន មុននឹងបញ្ឈប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ។

ការទាញហេតុផលចុងក្រោយ គឺជាឱកាសមួយសម្រាប់ឲ្យភាគីម្នាក់ៗ ធ្វើការបញ្ចេញមតិរបស់ខ្លួនជាចុងក្រោយស្តីពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទាររបស់ខ្លួន ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យភស្តុតាង ហេតុនេះហើយតុលាការត្រូវផ្តល់ឱកាសដល់ភាគីនីមួយៗនៃរឿងក្តីធ្វើការបញ្ចេញមតិរបស់ខ្លួន ដើម្បីតុលាការមានភាពគ្រប់គ្រាន់ដើម្បីចេញសាលក្រម ។

## ជំពូកទី៣ ការសះជាតាមផ្លូវបណ្តឹង

### ៣.១ អត្ថន័យនៃការសះជាតាមផ្លូវបណ្តឹង

ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពដែលដើមចោទ និងចុងចម្លើយធ្វើសម្បទានគ្នាទៅវិញទៅមក (លះបង់រៀងៗខ្លួន) នូវការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង និងព្រមព្រៀងបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្តឹង ហើយធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនោះ ដោយឯកភាពគ្នាចំពោះមុខតុលាការ[136]។ ហេតុនេះហើយ ការសះជាគឺជាមូលហេតុដ៏សំខាន់មួយនៃការបញ្ចប់បណ្តឹង ដូចសាលក្រមស្ថាពរដែរ ។

### ៣.២ ផលប្រយោជន៍នៃការសះជាតាមផ្លូវបណ្តឹង

ការដោះស្រាយជម្លោះរដ្ឋប្បវេណីនៅក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋ ក៏ដូចជាប្រទេសជាតិដែរ គឺបានឲ្យតម្លៃយ៉ាងខ្ពស់ទៅលើការដោះស្រាយវិវាទ ដោយប្រើនីតិវិធីផ្សះផ្សា ។

**គុណសម្បត្តិនៃការផ្សះផ្សា**

បើប្រៀបធៀបនឹងដំណោះស្រាយជម្លោះតាមសាលក្រម ការផ្សះផ្សា គឺជាដំណោះស្រាយនៃជម្លោះដែលមានគុណសម្បត្តិដូចតទៅ៖

(ក) អាចទទួលនូវខ្លឹមសារនៃការសះជាសមរម្យដែលស្របទៅនឹងលក្ខណៈ និងស្ថានភាពនៃរឿងក្តី ។

---

[135] មាត្រា ១១៦ កថាខណ្ឌទី៥ នៃក្រមដដែល

[136]សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ឆ្នាំ ២០០៨ ទំព័រទី ១៦៤

(ខ) ភាគីនឹងអនុវត្តដោយស្ម័គ្រចិត្តនូវកាតព្វកិច្ចដែលបានសន្យាក្នុងការសះជា ។

(គ) អាចរក្សានូវភាពប្រក្រតីនូវទំនាក់ទំនងរវាងភាគី នាពេលអនាគតបាន ។

## ៣.៣ ការសាកល្បងផ្សះផ្សា

នាកាលបរិច្ឆេទដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការគប្បីសាកល្បងធ្វើការផ្សះផ្សាជាមុនសិននៅពេលដែលភាគីទាំងពីរមានវត្តមាននៅកាលបរិច្ឆេទនោះ[137]។ ការផ្សះផ្សា នេះមិនត្រូវតែធ្វើនៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះទេ ប៉ុន្តែតុលាការអាចធ្វើនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី[138]។ បញ្ញត្តិនៃមាត្រានេះបានអនុញ្ញាតឱ្យតុលាការត្រូវតែធ្វើការសាកល្បងផ្សះផ្សាគូភាគីក៏ពិតមែន ប៉ុន្តែតុលាការអាចសម្រេចចិត្តថាត្រូវផ្សះផ្សា ឬមិនធ្វើការផ្សះផ្សា អាស្រ័យទៅលើស្ថានភាព និងគោលបំណងរបស់គូភាគីនៃរឿងក្តីនីមួយៗ។ បើតុលាការបានដឹងច្បាស់លាស់តាមរយៈអាកប្បកិរិយារបស់ភាគីថាពុំមានឆន្ទៈសះជាទេ ឬឃើញថាការផ្សះផ្សាមិនមានភាពសមរម្យទេនោះ មិនចាំបាច់ធ្វើការផ្សះផ្សានាពេលដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ។ ហេតុដែលអនុញ្ញាតឱ្យធ្វើបែបនេះពីព្រោះថា បើតុលាការសម្រេចធ្វើការសាកល្បងផ្សះផ្សា ហើយមិនបានសម្រេចនៅខណៈនោះក៏ដោយ ក៏តុលាការអាចធ្វើការសាកល្បងផ្សះផ្សាពេលក្រោយទៀតបានដែរ ពីព្រោះមាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា *តុលាការអាចសាកល្បងធ្វើការផ្សះផ្សារ បានទោះបីបណ្តឹងស្ថិតក្នុងដំណាក់កាលណាក៏ដោយ ។*

ដើម្បីឱ្យការផ្សះផ្សាទទួលបានលទ្ធផលល្អ តុលាការអាចប្រើប្រាស់នូវវិធីសាស្រ្តសមរម្យតាមឆន្ទានុសិទ្ធិមានដូចជា តុលាការអាចស្នើសុំឱ្យភាគីម្ខាងចេញក្រៅបន្ទប់តុលាការដោយមានការព្រមព្រៀងពីភាគីម្ខាងទៀតជាមុនសិនដើម្បីជៀសវាងនូវភាពមន្ទិលសង្ស័យថាតុលាការមានការលម្អៀង ហើយព្យាយាមធ្វើការបញ្ចុះបញ្ចូលភាគីម្ខាងទៀតដើម្បីឱ្យមានការព្រមព្រៀងគ្នា ឬតុលាការប្រើវិធីសាស្រ្តផ្សេងៗទៀតដែលតុលាការយល់ឃើញថាអាចមានប្រសិទ្ធិភាពសម្រាប់ធ្វើការផ្សះផ្សា ។ បើការផ្សះផ្សាពុំបានសម្រេចនៅក្នុងនីតិវិធីនេះទេ នោះតុលាការត្រូវបន្តនីតិវិធីតទៅទៀតដើម្បីរៀបចំចំណុចវិវាទ ។ ការរៀបចំចំណុចវិវាទនេះ គឺសំខាន់ណាស់សម្រាប់តុលាការ ពីព្រោះថាតុលាការត្រូវដឹងថាអ្វីជាអង្គហេតុដែលបានដោះស្រាយហើយ និងអង្គហេតុណាខ្លះដែលមិនទាន់បានដោះស្រាយហើយនៅក្នុងរឿងក្តីនេះ ។

[137]មាត្រា ១០៤ នៃក្រមដដែល

[138]មាត្រា ៩៧ នៃក្រមដដែល

## ៣.៤ ការផ្សះផ្សាក្រៅតុលាការ

ក្នុងករណីដែលតុលាការយល់ឃើញថាសមរម្យ តុលាការក៏អាចធ្វើការផ្សះផ្សាតាមផ្លូវបណ្តឹង នៅក្រៅតុលាការបាន[139]។

ឧទាហរណ៍: ពាក់ព័ន្ធនឹងជម្លោះព្រំដែន ឬស្តីពីការសាងសង់ អាចមានករណីដែលគួរតែផ្សះផ្សាដោយមើលតាមស្ថានភាពផ្ទាល់ទីកន្លែង ។

## ៣.៥ អានុភាព និងកំណត់ហេតុនៃការសះជា

ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រាក្នុងកំណត់ហេតុ កំណត់ហេតុនេះមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ[140]។ តុលាការមិនចាំបាច់ចេញដីកាសម្រេចទទួលស្គាល់ការសះជាទេ គ្រាន់តែសរសេរក្នុងកំណត់ហេតុ អំពីខ្លឹមសារនៃការសះជាទៅ មានដូចជា "*ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ*"[141] និង "*ការដកពាក្យបណ្តឹងការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និងការសារភាព*"[142] នោះការសះជានឹងមានអនុភាព ។

អានុភាពនេះ មានន័យដូចគ្នានឹងសាលក្រមស្ថាពរ ហើយអានុភាពនៃការសះជាអាចបញ្ចប់បណ្តឹង និងមានអានុភាពអនុវត្ត ទៅនឹងការផ្តល់តាវកាលិកជាកំណត់មួយ ។ មានន័យថាភាគីអាចយកកំណត់ហេតុដែលបានចុះអំពីការសះជានោះមកធ្វើជាលិខិតអនុវត្ត ដើម្បីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំបាន[143]។ ដូច្នេះហើយ ក្នុងករណីដែល ភាគីម្ខាងទៀតមិនបំពេញកាតព្វកិច្ច ដែលបានកំណត់នៅក្នុងកំណត់ហេតុនៃការសះជានោះទេអាចអនុវត្តដោយបង្ខំបាន ហើយនេះគឺជាចំណុចមួយដ៏សំខាន់ដើម្បីពន្យល់ណែនាំឱ្យភាគីសះជា ។

តាមធម្មតា នៅក្នុងកំណត់ហេតុនៃការសះជា ត្រូវសរសេរតែប្រការនៃការសះជា ដែលជាខ្លឹមសារនៃការសះជាដែលបានព្រមព្រៀង មិនសរសេរលម្អិតអំពីការចរចានៅក្នុងនីតិវិធីនៃការសះជាទេ ដោយសារតែនៅក្នុង ដំណាក់កាលនៃការចរចានេះ ភាគីបាននិយាយដោយ

---

139 មាត្រា ២២០ កថាខណ្ឌទី២ នៃក្រមដដែល

140 មាត្រា ២២២ នៃក្រមដដែល

141 មាត្រា ១១១ចំណុច ឃ នៃក្រមដដែល

142 មាត្រា ១១៩ កថាខណ្ឌទី១ ចំណុច ក នៃក្រមដដែល

143 មាត្រា ៣៥០ កថាខណ្ឌទី២ចំណុច ឈ នៃក្រមដដែល

ស្មោះអំពីបញ្ហានានា ហេតុនេះហើយ ភាគច្រើនគឺជាករណីដែលមានការពិបាកនឹងសរសេរជាកំណត់ហេតុទុក ។

ដូចដែលបានពន្យល់ខាងលើ ប្រការនៃការសះជាអាចមានករណីដែលអាចអនុវត្តបាន ហេតុនេះហើយ ត្រូវសរសេរឱ្យប្រយ័ត្ន និងឱ្យបានច្បាស់លាស់ព្រមទាំងកុំឱ្យមានការខ្វះខាត។ ក្រោយការសរសេរអំពីប្រការនៃការសះជា តុលាការគប្បីអានឱ្យភាគីទាំងសងខាងស្តាប់ ហើយសួរបញ្ជាក់ពីភាគីទាំងសងខាង ។

## ជំពូកទី៤ : ការសម្រេចសេចក្តីជាសាលក្រម

### ៤.១ សាលក្រមចំពោះមុខ

#### ៤.១.១ កំណើតអានុភាពនៃសាលក្រម

មាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ចែងថា "*សាលក្រមនឹងមានអនុភាពដោយការប្រកាស*" ។ សាលក្រមពុំមានអានុភាពឡើយតាមរយៈការជូនដំណឹងដោយវិធីផ្សេងស្តីពីការប្រកាស ។

#### ៤.១.២ ការប្រកាសសាលក្រម

##### ៤.១.២.១ កាលបរិច្ឆេទប្រកាសសាលក្រម

ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់[144]។ ក្នុងអំឡុងពេលនេះ តុលាការអាចមានឱកាសស្រាវជ្រាវឱ្យបានស៊ីជម្រៅអំពីអង្គហេតុ និងអង្គច្បាប់ ហើយត្រៀមសាលក្រមឱ្យបានសមស្របបាន ។ ប៉ុន្តែ ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល១ខែនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬ មានកាលៈទេសៈពិសេសផ្សេងទៀត ។

##### ៤.១.២.២ របៀបនៃប្រកាសសាលក្រម

ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមការបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ជាអ្នកអានសេចក្តីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃសាលក្រម ។ ប៉ុន្តែក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ចៅក្រមប្រឹក្សាអាចជំនួសបាន[145]។ ការប្រកាសសាលក្រមអាចធ្វើបានទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ[146] គឺដោយសារតែភាគីមិនចាំបាច់ធ្វើសកម្មភាពអ្វីទាំងអស់

[144] មាត្រា ១៨៧ នៃក្រមដដែល

[145] មាត្រា ១៨៨ កថាខណ្ឌទី១ នៃក្រមដដែល

[146] មាត្រា ១៨៨ កថាខណ្ឌទី២ នៃក្រមដដែល

នៅពេលប្រកាសសាលក្រមនេះទេ ។ ទោះបីជាភាគីអវត្តមាននៅកាលបរិច្ឆេទនៃការប្រកាសសាលក្រមក៏ដោយ ក៏វាមិនមែនជាសាលក្រមកំបាំងមុខ ។

ពេលប្រកាសសាលក្រម គ្រាន់តែអានសេចក្តីសម្រេចបញ្ចប់ ជាការគ្រប់គ្រាន់ ក៏ប៉ុន្តែ *ប្រសិនបើយល់ឃើញថាសមរម្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន* [147]។ នៅក្នុងចំណុចនេះ ដើមចោទក្តី ឬចុងចម្លើយក្តី តែងតែចង់ឱ្យតុលាការអានសំអាងហេតុនៃសាលក្រម ឬពន្យល់ខ្លឹមសារនៃសំអាងហេតុណាស់ ព្រោះដើម្បីដោយបានដឹងថា តើខ្លួនចាញ់ក្តីដោយមូលហេតុអ្វី និងខ្លួនឈ្នះក្តីដោយសារហេតុផលបែបណា ។

### ៤.១.៣ លិខិតសាលក្រម

ការប្រកាសាលក្រមត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ហេតុនេះហើយ មុននឹងប្រកាសសាលក្រម ត្រូវធ្វើលិខិតសាលក្រមជាមុនសិន ។

នៅក្នុងលិខិតសាលក្រម ត្រូវសរសេរចំណុច ដូចមានចែងក្នុងមាត្រា១៨៩នៃក្រមដដែល។ ការសរសេរលិខិតសាលក្រម ដោយផ្អែកលើចំណុចចាំបាច់ ហេតុនេះហើយគប្បីពិចារណាដល់ទម្រង់សម្រាប់អនុវត្តជាក់ស្តែង ។

ទម្រង់នៃលិខិតសាលក្រមមួយ ដូចតទៅ:

(១) តុលាការ

(២) ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

(៣) ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

(៤) ចំណុចនៃបណ្តឹង និងភាគី

(៥) អង្គហេតុ

(i) ស្តីពីការទាមទារ

ក. ការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ

ខ. ចម្លើយរបស់ចុងចម្លើយ ចំពោះការទាមទារនោះ

(ii) ស្តីពីការអះអាង

ក. អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ

[147] មាត្រា ១៨៨ កថាខណ្ឌទី៣ នៃក្រមដដែល

ខ. ការទទួលស្គាល់ ឬមិនទទួលស្គាល់ដោយចុងចម្លើយចំពោះអង្គហេតុទាំងនេះ

គ. ការតវ៉ារបស់ចុងចម្លើយ (បើសិនជាមាន)

........... (ក្នុងករណីដែលដើមចោទបានតវ៉ាតប ត្រូវសរសេរដូចគ្នាទៀត)

(iii) ស្តីពីចំណុចវិវាទ

(៦). សំអាងហេតុ

ការវិនិច្ឆ័យចំពោះចំណុចវិវាទ (វិនិច្ឆ័យថា តើអង្គហេតុដែលជាចំណុចវិវាទត្រូវបានបញ្ជាក់ដោយភស្តុតាងដែរឬទេ? )

(៧). សេចក្តីសម្រេចបញ្ចប់

លិខិតសាលក្រម គឺជាសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ហើយជាការវិនិច្ឆ័យទៅលើការទាមទាររបស់ដើមចោទ ។ ចុងបញ្ចប់គឺឈ្មោះចៅក្រមដែលបានចូលរួមក្នុងការជំនុំជម្រះ ហត្ថលេខា ព្រមទាំងប្រថាប់ត្រា ។

មាត្រា ៩៥ នៃក្រមដដែលចែងថា "*តុលាការមិនអាចយកអង្គហេតុណាដែលភាគីណាមួយមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ*" ។ មានន័យថា តុលាការមិនត្រូវធ្វើការទទួលស្គាល់នូវ "អង្គហេតុដែលជាមូលហេតុនៃការទាមទារ អង្គហេតុតវ៉ា អង្គហេតុតវ៉ាតប ដែលភាគីមិនបានអះអាង នៅពេលជំនុំជម្រះ ទោះបីមានភស្តុតាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

### ៤.១.៤. ការបញ្ជូនលិខិតសាលក្រម

តុលាការត្រូវបញ្ជូនលិខិតសាលក្រមទៅឱ្យភាគី ក្នុងអំឡុងពេលពីរសប្តាហ៍ បន្ទាប់ពីថ្ងៃបានប្រកាសសាលក្រមនោះ[148]។ ការបញ្ជូនត្រូវធ្វើដោយអនុសារសាលក្រម។ អំឡុងពេលប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ នៅក្នុងអំឡុងពេលមួយខែ ដោយគិតចាប់តាំងពីថ្ងៃដែលភាគីបានទទួលការបញ្ជូនលិខិតសាលក្រម[149]។

## ៤.២ សាលក្រមកំបាំងមុខ

### ៤.២.១ សាលក្រមកំបាំងមុខចំពោះភាគីអវត្តមាន

សាលក្រមកំបាំងមុខចំពោះភាគីអវត្តមាន មានការបែងចែកជាពីរករណីមានដូចជា សាលក្រមកំបាំងមុខដើមចោទ និងសាលក្រមកំបាំងមុខចុងចម្លើយ។

---

[148] មាត្រា ១៩០ នៃក្រមដដែល

[149] មាត្រា ២៦៤ នៃក្រមដដែល

### ៤.២.១.១ សាលក្រមកំបាំងមុខដើមចោទ

សាលក្រមកំបាំងមុខដើមចោទ គឺដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ។ ម៉្យាងវិញទៀត បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាក់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយតុលាការកំណត់នូវកាលបរិច្ឆេទលើកទី១នៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះដោយសាលក្រមកំបាំងមុខ[150]។

សាលក្រមកំបាំងមុខដើមចោទ ក៏មិនអាចចេញបានដែរ ទោះដើមចោទអវត្តមាននៅក្នុងកាលបរិច្ឆេទខាងលើដែលបានរៀបរាប់ដោយមូលហេតុដូចជា ៖

(ក) ដើមចោទដែលមិនបានបង្ហាញខ្លួន ដែលមិនបានទទួលការកោះហៅស្របច្បាប់ពីតុលាការ ។

(ខ) បណ្តឹងមិនស្របច្បាប់ ។

(គ) ដើមចោទដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន[151]។

(គ) ការពន្យាពេលកាលបរិច្ឆទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បើដើមចោទយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬយល់ឃើញថា ដើមចោទមិនអាចបង្ហាញខ្លួនបានដោយគ្មានកំហុសទេ[152]។

"បណ្តឹងមិនស្របច្បាប់" មានលក្ខខណ្ឌដូចខាងក្រោម៖

(១) តុលាការនៃព្រះរាជាណាចក្រកម្ពុជាមិនមានសមត្ថកិច្ចជំនុំជម្រះ[153]។

(២) តុលាការ មិនមានសមត្ថកិច្ចលើរឿងក្តីនោះ[154]។

---

150 មាត្រា ២០០ នៃក្រមដដែល

151 មាត្រា ២០២ ចំណុច ក និងខ នៃក្រមដដែល

152 មាត្រា ២០៣ កថាខណ្ឌទី១ នៃក្រមដដែល

153 មាត្រា ៧ និងមាត្រាបន្តបន្ទាប់ នៃក្រមដដែល

154 ដូច មាត្រា ៥៩

(៣) មិនមានភាគីពិតប្រាកដ ហើយភាគីដែលអសមត្ថភាព (អនីតិជន ឬជននៅក្រោយអាណាព្យាបាលជាដើម)[155]។

(៤) បណ្តឹងដែលច្បាប់បានហាមឃាត់: ចំពោះរឿងក្តីកំពុងចាត់ការភាគីមិនអាចប្តឹងទៀតបានទេ[156] និងការហាមមិនឱ្យធ្វើបណ្តឹងតបនៅក្នុងរឿងក្តីដែលមានចំនួនទឹកប្រាក់តិច[157] ។

### ៤.២.១.២ សាលក្រមកំបាំងមុខចុងចម្លើយ

សាលក្រមកំបាំងមុខចុងចម្លើយ គឺចុងចម្លើយមិនបានបង្ហាញខ្លួននៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយតុលាការកំណត់នូវកាលបរិច្ឆេទលើកទី១នៃការទាញហេតុផលដោយផ្ទាល់មាត់[158]។ ម៉្យាងវិញទៀត បើចុងម្លើយមិនបានបង្ហាញខ្លួននូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុនៃការទាមទារមានហេតុផលត្រឹមត្រូវតាមសេចក្តីថ្លែងការណ៍ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំង ។ ផ្ទុយមកវិញ បើសិនការទាមទាររបស់ដើមចោទ ពុំមានហេតុផលត្រឹមត្រូវតាមសេចក្តីថ្លែងការណ៍ទេ តុលាការត្រូវចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ។ ក្នុងករណីដែលនៅកាលបរិច្ឆេទមុនៗ ចុងចម្លើយមានវិវាទចំពោះការអះអាងរបស់ដើមចោទ ដូចនេះការបកស្រាយខាងលើនេះមិនត្រូវយកមកអនុវត្តបានឡើយ[159]។

សាលក្រមកំបាំងមុខចុងចម្លើយ ក៏មិនអាចចេញបានដែរ ទោះចុងចម្លើយអវត្តមាននៅក្នុងកាលបរិច្ឆេទខាងលើដែលបានរៀបរាប់នេះ ដោយមូលហេតុដូចជាៈ

(ក) ចុងចម្លើយដែលមិនបានបង្ហាញខ្លួន ដែលមិនបានទទួលការកោះហៅស្របច្បាប់ពីតុលាការ ។

(ខ) ចុងចម្លើយដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ។

(គ) បណ្តឹងមិនស្របច្បាប់ ។

---

155 មាត្រា ៣២ នៃក្រមដដែល

156 មាត្រា ៨៣ នៃក្រមដដែល

157 មាត្រា ២២៧ នៃក្រមដដែល

158 មាត្រា ២០១ កថាខណ្ឌទី១ នៃក្រមដដែល

159 មាត្រា ២០១ កថាខណ្ឌទី២ នៃក្រមដដែល

(ឃ) ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះ តុលាការមិនបានជូនដំណឹងទៅ ចុងចម្លើយ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់[160]។

(គ) ការពន្យាពេលកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បើចុងចម្លើយយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬយល់ឃើញថា ចុងចម្លើយមិនអាចបង្ហាញខ្លួនបានដោយគ្មានកំហុសទេ[161]។

### ៤.២.២ បណ្តឹងទាស់

បណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខ ដើម្បីការពារផលប្រយោជន៍នៃការជម្រះក្តីរបស់អ្នកអវត្តមាន ហើយបើសិនជាទទួលការយល់ព្រមឱ្យប្តឹងទាស់ រឿងក្តីនោះត្រូវចាត់ការម្តងទៀតនៅតុលាការថ្នាក់ដដែល ។ បណ្តឹងទាស់អាចធ្វើដោយភាគីបង្ហាញហេតុផលដែលខ្លួនបានអវត្តមាន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយសារមូលហេតុដែលមិនអាចព្យាករបាន ឬហេតុដែលមិនអាចជៀសវាងបាន ហើយទទួលបានសាលក្រមកំបាំងមុខ។ បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងរយៈពេលពីរសប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ប៉ុន្តែ បើសាលក្រមកំបាំងមុខ ត្រូវបានបញ្ជូនតាមរយៈការបិទប្រកាសជាសាធារណៈ ឬតាមរយៈការបញ្ជូនទៅបរទេស តុលាការត្រូវកំណត់ពេលដែលអាចប្តឹងទាស់ នៅក្នុងសាលក្រមកំបាំងមុខនោះ[162]។

ពាក្យបណ្តឹងទាស់ត្រូវធ្វើដូចខាងក្រោម[163]៖

(១) ការប្តឹងទាស់ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខ ។

(២) ក្នុងពាក្យបណ្តឹងទាស់ត្រូវសរសេរឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។ សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។ បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលបានក្នុងកម្មវត្ថុនៃសាលក្រមកំបាំងមុខ។ មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាល

[160] មាត្រា ២០២ នៃក្រមដដែល

[161] មាត្រា ២០៣ កថាខណ្ឌទី១ នៃក្រមដដែល

[162] មាត្រា ២០៤ នៃក្រមដដែល

[163] មាត្រា ២០៥ នៃក្រមដដែល

បរិច្ឆេទទាន់ពេលវេលា ។

ក្នុងករណីដែលពាក្យបណ្ដឹងទាស់នេះ ត្រូវបានធ្វើខុសតាម (១) និង(២)ខាងលើនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាត។ ក្នុងករណីដែលភាគីមិនបានកែតម្រូវនូវចំណុចខ្វះខាតក្នុងអំឡុងពេលកំណត់នោះទេ តុលាការត្រូវលើកពាក្យបណ្ដឹងទាស់នោះចោលដោយចេញដីកាសម្រេច[164] ចំពោះដីកាសម្រេចលើកចោលនេះអាចប្ដឹងជំទាស់បាន[165]។

តុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីវិធី និងមូលហេតុនៃបណ្ដឹងទាស់ព្រមទាំងភាពត្រឹមត្រូវនៃមូលហេតុនៃបណ្ដឹងទាស់ ។ ក្នុងករណីដែលបណ្ដឹងទាស់មិនស្របនឹងច្បាប់ ដូចមានចែងក្នុងមាត្រា ២០៤ កថាខណ្ឌទី១ នៃដដែលតុលាការត្រូវលើកបណ្ដឹងទាស់ចោលដោយចេញដីកាសម្រេច[166]។ ប្រសិនបើជាការដាក់បណ្ដឹងទាស់នោះស្របច្បាប់ ហើយមានមូលហេតុត្រឹមត្រូវ បណ្ដឹងត្រូវទៅសភាពមុនពេលភាគីអវត្តមានវិញ[167] ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទធ្វើឡើងវិញនូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវជូនដំណឹងទៅឱ្យភាគី[168] ។

ស្ដីពីសាលក្រមថ្មីដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី ក្រោយពេលចាប់ផ្ដើមនីតិវិធីឡើងវិញ ក្នុងករណីដែលទទួលស្គាល់នូវបណ្ដឹងទាស់ ពេលមានលទ្ធផលដូចសាលក្រមកំបាំងមុខពីមុន តុលាការត្រូវចេញ សាលក្រមថ្មីដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ[169] ។ ផ្ទុយមកវិញ បើគ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះ នៅក្នុងសាលក្រមថ្មី[170]។

ក្នុងករណីដែលភាគីដែលបានដាក់ពាក្យបណ្ដឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញទេ តុលាការត្រូវច្រានចោលបណ្ដឹងទាស់ ដោយសាលក្រមកំបាំងមុខម្ដងទៀត លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ២០២ និងមាត្រា២០៣ នៃក្រមដដែល[171]។ ចំពោះសាលក្រមកំបាំងមុខលើកទី២នេះ ភាគីមិន

---

164 មាត្រា ២០៦ នៃក្រមដដែល

165 មាត្រា ២០៦ កថាខណ្ឌទី៣ នៃក្រមដដែល

166 មាត្រា ២០៧ កថាខណ្ឌទី២ នៃក្រមដដែល

167 មាត្រា ២០៨ កថាខណ្ឌទី១ នៃក្រមដដែល

168 មាត្រា ២០៨ កថាខណ្ឌទី១ នៃក្រមដដែល

169 មាត្រា ២០៩ កថាខណ្ឌទី១ នៃក្រមដដែល

170 មាត្រា ២០៩ កថាខណ្ឌទី២ នៃក្រមដដែល

171 មាត្រា ២១១ កថាខណ្ឌទី១ នៃក្រមដដែល

អាចប្ដឹងទាស់បានទៀតទេ។[172]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹងទាស់**

❖ **ដើមបណ្ដឹង**

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

❖ **ចុងបណ្ដឹង**

ឈ្មោះ ១១១ ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

**សូមគោរពជូន**
**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ/ខេត្ត**......

**កម្មវត្ថុ៖** សុំប្ដឹងទាស់ចំពោះសាលក្រមកំបាំង លេខ ............. ចុះថ្ងៃទី..... ខែ........ ឆ្នាំ២០១...... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត...........។

**យោង៖** - សំណុំរឿងរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី...... ខែ........... ឆ្នាំ២០...... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត...........

- សាលក្រមកំបាំងមុខលេខ ................. ចុះថ្ងៃទី........ ខែ............ ឆ្នាំ២០១....... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត...........

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបអំពីសញ្ញាណនៃសាលក្រមកំបាំងមុខ បំណងនៃការប្ដឹងទាស់ និងមូលហេតុនៃបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខលេខ ........... ចុះថ្ងៃទី.... ខែ......... ឆ្នាំ២០១.... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត........... ដូចខាងក្រោម៖

**ក. សញ្ញាណនៃសាលក្រមកំបាំងមុខ**

សាលក្រមកំបាំងមុខលេខ ........... ចុះថ្ងៃទី.... ខែ......... ឆ្នាំ២០១.... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត........... មានខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់ ដូចខាងក្រោម៖

១. ..........
២. ..........
៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ/ចុងចម្លើយ។

**ខ. បំណងនៃការប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ**

ខ្ញុំបាទសូមប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខលេខ ........... ចុះថ្ងៃទី.... ខែ......... ឆ្នាំ២០១.... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត........... ត្រង់ចំណុចសេចក្ដីសម្រេចបញ្ចប់ទាំងមូល។

ទំព័រ **1** នៃ **2**

[172] មាត្រា ២១១ កថាខណ្ឌទី២ នៃក្រមដដែល

**គ. មូលហេតុដែលមិនអាច មកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា**

..........................................................................................................................................................

..........................................................................................................................................................។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាជួយចាត់ការតាមនីតិវិធីដោយក្ដីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃ.......... ខែ...... ឆ្នាំ..... ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី..... ខែ...... ឆ្នាំ.........

**ស្នាមមេដៃស្ដាំ**

**ឯកសារជូនភ្ជាប់៖**

- សាលក្រមកំបាំងមុខលេខ...... ចុះថ្ងៃទី.... ខែ......... ឆ្នាំ២០១.... របស់សាលាដំបូងរាជធានីភ្នំពេញ/ខេត្ត.......... ចំនួន ០១ ច្បាប់ ( ច្បាប់ថតចម្លង )
- ............................
- .........................

## សេចក្ដីសន្និដ្ឋាន

ក្រោយបានធ្វើការបកស្រាយខាងលើរួចមក នីតិវិធីជំនុំជម្រះក្ដីលើកទី១ គឺជានីតិវិធីដែលមានច្រើនដំណាក់កាល ដោយហេតុថាដំណាក់កាលទាំងអស់នេះមានសារៈសំខាន់ទាំងអស់ ។

ដំណាក់កាលដំបូង គឺការដាក់ពាក្យបណ្ដឹង ប្រសិនបើមិនមានពាក្យបណ្ដឹងទេ រឿងក្ដីរដ្ឋប្បវេណីក៏មិនមានការជំនុំជម្រះដែរ ហើយការដាក់នោះលុះត្រាណាអ្នកដែលដាក់ពាក្យបណ្ដឹងត្រូវសរសេរដោយបានត្រឹមត្រូវតាមលក្ខខណ្ឌដែលច្បាប់តម្រូវ និងតម្រូវបង់ពន្ធជាដើម ទើបពាក្យបណ្ដឹងនេះត្រូវបានតុលាការយកមកចាត់ការ ។

ដំណាក់កាលបន្ទាប់ពីការដាក់ពាក្យបណ្ដឹងរួច ពាក្យបណ្ដឹងត្រូវបានតុលាការយកមកចាត់ការ ដូចនេះតុលាការចាប់ផ្ដើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ដំណាក់កាលនេះ

គឺតុលាការចាប់រៀបចំចំណុចវិវាទ ដោយភាគីធ្វើសេចក្តីថ្លែងការណ៍ និងការពិនិត្យភស្តុតាងជាឯកសារជាដើម ប៉ុន្តែក្នុងដំណាក់កាលនេះ តុលាការមិនអាចសាកសួរសាក្សីបានទេ ។

ដំណាក់កាលបន្ទាប់ គឺនីតិវិធីទាញហេតុហេតុដោយផ្ទាល់មាត់ តុលាការអាចធ្វើការសាកសួរភាគី សាក្សី និងការពិនិត្យភស្តុតាងជាឯកសារអំពីភាពត្រឹមត្រូវ និងឱ្យភាគីបញ្ចេញមតិរបស់ខ្លួនជាចុងក្រោយ ដើម្បីតុលាការចេញសាលក្រម ។

ចំណែកការសះជា តុលាការអាចធ្វើបាននៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងដំណាក់កាលនីតិវិធីទាញហេតុហេតុដោយផ្ទាល់មាត់ ឬនៅក្រៅតុលាការ ហើយការសះជាមានអានុភាពស្មើនឹងសាលក្រមស្ថាពរ ។

រីឯដំណាក់កាលចុងក្រោយ គឺការចេញសាលក្រម ដែលសាលក្រមនោះ មានពីរ គឺសាលក្រមចំពោះមុខ និងសាលក្រមកំបាំងមុខ ហើយសាលក្រមទាំងនេះមានអានុភាពនៅពេលដែលសាលក្រមទាំងនោះ បានចូលជាស្ថាពរ ។

ដូច្នេះ ទាក់ទងទៅ នីតិវិធីជំនុំជម្រះក្តីលើកទី១ គឺជាដំណើរការនីតិវិធីរឿងក្តីរដ្ឋប្បវេណីដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ រួមទាំងការអនុវត្តជាក់ស្តែងនៅព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ ។

## អនុសាសន៍

ចំពោះរឿងក្តីរដ្ឋប្បវេណីនៅក្នុងប្រទេសកម្ពុជាភាគច្រើន គឺកើតឡើងនៅទំនាស់ផលប្រយោជន៍ដោយសារអ្នកខ្លះលោភលន់ អ្នកខ្លះកេងប្រវ័ញ្ច ចង់មានចង់បានដោយមិនគិតជាកម្មសិទ្ធិរបស់អ្នកដទៃ ឬទ្រព្យសម្បត្តិអ្នកដទៃ ដូច្នេះបើសិនជាអាចបោះបង់បាន រឿងក្តីរដ្ឋប្បវេណីប្រហែលមិនមានច្រើនទេ ។

ប្រសិនបើមានរឿងក្តីរដ្ឋប្បវេណីកើតឡើង គួរមានការផ្សះផ្សាជាគ្នាជាមុនសិន មុននឹងសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការ។ ប្រសិនបើមានការផ្សះផ្សា គូភាគីគួមានការសម្ប-ទានគ្នាទៅវិញទៅមក ដើម្បីបញ្ចប់វិវាទនោះ ព្រោះពេលមានរឿងក្តីបណ្តឹងរដ្ឋប្បវេណីកើតឡើងហើយ គឺខាតបង់ប្រយោជន៍ច្រើនណាស់ ដូចជា ទ្រព្យសម្បត្តិ ពេលវេលា ការប៉ះពាល់ដល់មុខជំនួញ ឬអាជីវកម្មរបស់ខ្លួនទៀតផង ។

## ឯកសារយោង


- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
- សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្ដឹង, រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរប្បវេណីកម្ពុជា
- សៀវភៅ ស្ដីពី ការពន្យល់អំពីនីតិវិធីជម្រះក្ដីលើកទី១បោះពុម្ពលើកទី២ ខែវិច្ឆិកា ឆ្នាំ ២០០៩
- មេរៀនឆ្នាំទី៣មុខវិជ្ជា នីតិវិធីរដ្ឋប្បវេណីបង្រៀនដោយលោកសាស្ត្រាចារ្យ គង់ ស្រ៊ីម ឆ្នាំសិក្សា២០១១-២០១២
- ការផ្ដល់យោបល់អំពីនីតិវិធីជំនុំជម្រះលើកទី១ពីលោកមេធាវី ហ៊ាង ហុង
- ការផ្ដល់យោបល់អំពីនីតិវិធីជំនុំជម្រះលើកទី១ពីលោកមេធាវី អ៊ុក ស៊ីរឿន
- ការផ្ដល់យោបល់របស់លោកមេធាវី ខៀវ សិន
- ឯកសារបានមកពី លោកមេធាវី ទេព បញ្ញា
- ការផ្ដល់យោបល់ និងឯកសារពាក់ព័ន្ធពីលោកក្រឡាបញ្ជី ប៉ែន ស៊ីណូ
- សៀវភៅបញ្ចេកទេសសវនាការនៃមេធាវីរដ្ឋប្បវេណី, និពន្ធនិងរៀបរៀងដោយលោកមេធាវី អៀវ ប៊ុនវ៉េង, បោះពុម្ពលើកទី១ ឆ្នាំ២០១១

# សកម្មភាពគណៈមេធាវីប្រចាំ
# ត្រីមាសទី១ ឆ្នាំ២០១៩

# ១.ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១.ទំនាក់ទំនងជាតិ

### កិច្ចពិភាក្សាការងារ រវាងគណៈមេធាវី ជាមួយនឹងសាលាដំបូង និងអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ

នៅថ្ងៃពុធ ១១កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ នៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ លោកសួន វិសាល ប្រធានគណៈមេធាវីបានដឹកនាំសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី និងបុគ្គលិកគណៈមេធាវីដើម្បីចូលរួមពិភាក្សាការងារជាមួយលោក តាំង ស៊ុនឡាយ ប្រធានសាលាដំបូងរាជធានីភ្នំពេញ។

នៅក្នុងកិច្ចពិភាក្សានេះមានការចូលរួមពី សហភាតាមេធាវី លោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដើម្បីពិភាក្សា ពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ក្នុងប្រព័ន្ធតុលាការ។ របៀបវារៈនៃកិច្ចប្រជុំផ្តោតបួនចំណុចសំខាន់ៗគឺ

(១) សកម្មភាពការងាររបស់គណៈមេធាវីកន្លងមក

២) តួនាទីរបស់ប្រតិភូគណៈមេធាវីប្រចាំសាលាដំបូង ខេត្ត/ក្រុង

៣) យន្តការនៃការការពារក្តីជូនជនក្រីក្រ និង

៤) បញ្ហាប្រឈមនានាក្នុងការប្រកបវិជ្ជាជីវៈមេធាវី និងចៅក្រម ព្រះរាជអាជ្ញា

នៅក្នុងកិច្ចពិភាក្សានេះ លោកមេធាវី សួន វិសាលប្រធានគណៈមេធាវីបានធ្វើបទបង្ហាញអំពី សមិទ្ធផលសំខាន់ៗដែលសម្រេចបាននៅក្នុងអាណត្តិនៃការដឹកនាំរបស់លោករួមមានកំណែទម្រង់ផ្ទៃក្នុងអង្គភាពគណៈមេធាវីឲ្យការងារកាន់តែប្រសើរឡើង ជាពិសេសការធ្វើទំនើបកម្មក្នុងវិស័យរដ្ឋបាល និងការគ្រប់គ្រងរឿងក្តីក្រីក្រតាមប្រព័ន្ធបច្ចេកវិទ្យាជាដើម។

នៅក្នុងកិច្ចពិភាក្សានេះ អ្នកចូលរួមបានផ្តល់នូវសំណួរ និងយោបល់យ៉ាងផុសផុលដែលពាក់ព័ន្ធនឹងការប្រឈមមុខនៃការអនុវត្តការងារកន្លងមក។

ជាកិច្ចបញ្ចប់កម្មវិធី ថ្នាក់ដឹកនាំស្ថាប័នទាំងពីរបានទទួលយកនូវចំណុចទាំងឡាយបានលើកឡើងនៅក្នុងកិច្ចពិភាក្សានេះ ហើយនឹងធ្វើការដោះស្រាយបញ្ហាទាំងនោះប្រកបដោយប្រសិទ្ធភាពខ្ពស់





## លោកកុយនាម អគ្គលេខាធិការរងគណៈមេធាវី ជួបជជែកពិភាក្សាការងារមួយអង្គការសកម្មភាពដើម្បីកុមារ (APLE)

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី កុយ នាម អគ្គលេខាធិការរងនៃគណៈមេធាវី បានអនុញ្ញាតឲ្យអ្នកស្រី ហ៊ឹម សោភ័ណ្ឌ ប្រធានផ្នែកគាំទ្រតុលាការនៃអង្គការសកម្មភាពសម្រាប់កុមារ Action Pour Les Enfants (APLE)

ដើម្បីសុំការសហការជាមួយគណៈមេធាវីដើម្បីគាំទ្រលើវិស័យច្បាប់ក្នុងការការពារកុមារដែលរងគ្រោះ ដោយសារការរំលោភបំពានផ្លូវភេទ។ នៅក្នុងកិច្ចប្រជុំនេះ លោកមេធាវី កុយ នាម បានបង្ហាញអំពី ការិយាល័យគាំពារកុមារដែលស្ថិតនៅក្នុងនាយកដ្ឋានជំនួយផ្នែកច្បាប់នៃគណៈមេធាវីផងដែរ។ អង្គការសកម្មភាពសម្រាប់កុមារនឹងដាក់សំណើរមកគណៈមេធាវីអំពី សិក្ខាសាលារួមគ្នា ស្តីពី ការគាំពារកុមារក្នុងវិស័យច្បាប់។



## លោកមេធាវីសួន វិសាល ប្រធានគណៈមេធាវី បានជួបប្រជុំជាមួយប្រធានមណ្ឌលអប់រំកែប្រែទី១ និងប្រធានមណ្ឌលអប់រំកែប្រែទី២

នៅថ្ងៃពុធ ៨រោច ខែមាឃ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានដឹកនាំសមាជិក-សមាជិកាក្រុមការងារសាងសង់បន្ទប់មេធាវីនៅតាមពន្ធនាគារ បានជួបពិភាក្សាការងារជាមួយប្រធានមណ្ឌលអប់រំកែប្រែទី១ និងប្រធានមណ្ឌលអប់រំកែប្រែទី២ (ព្រៃស) រាជធានីភ្នំពេញ។

លទ្ធផលនៃកិច្ចប្រជុំសម្រេចបាន គឺប្រធានមណ្ឌលអប់រំកែប្រែទី១ និងប្រធានមណ្ឌលអប់រំកែប្រែទី២បានផ្តល់ទីកន្លែងសម្រាប់គណៈមេធាវីក្នុងការសាងសង់បន្ទប់សម្រាប់មេធាវីក្នុងប្រាស្រ័យទាក់ទងជាមួយកូនក្តីខ្លួន ដោយរក្សាបាននូវការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួន។





## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីស្ត្រី

នារសៀលថ្ងៃអង្គារ ៧កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ នៅសណ្ឋាគារ HIMAWARI គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចុះអនុស្សារណៈយោគយល់ជាមួយក្រុមប្រឹក្សាជាតិដើម្បីស្ត្រី (ក.ជ.ក.ស)។

ក្នុងកិច្ចសហប្រតិបត្តិការផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សា និងផ្តល់ការអប់រំលើវិស័យច្បាប់ដល់មន្ត្រីអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ ក.ជ.ក.ស និងមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីរាជធានី/ខេត្ត។

នៅក្នុងពិធីនេះមានការចូលរួមពីថ្នាក់ដឹកនាំនៃអង្គភាពទាំងពីរ រួមមាន លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិដើម្បីស្ត្រី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី សមាជិក-សមាជិការក្រុមប្រឹក្សាគណៈមេធាវី និងបុគ្គលគណៈមេធាវី ព្រមទាំងមន្ត្រីអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ក.ជ.ក.ស អគ្គនាយកដ្ឋានពាក់ព័ន្ធ និងបុគ្គលិក។ ពិធីបានបញ្ចប់ដោយបរិយាកាសរីករាយ និងស្និតស្នាលយ៉ាងក្រៃលែង។




ពិធីចុះហត្ថលេខាលើ
ស្ដីពី



## ប្រធានគណៈមេធាវី រួមដំណើរដោយអគ្គលេខាគណៈមេធាវី ព្រមទាំងសមាជិក-សមាជិកាក្រុមប្រឹក្សា បានចូលរួម កិច្ចប្រជុំក្រុមការងារធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

នៅថ្ងៃព្រហស្បតិ៍ ទី៩កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៩ព្រឹក នៅទីស្តីការក្រសួងយុត្តិធម៌ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី រួមដំណើរដោយលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាគណៈមេធាវី ព្រមទាំងសមាជិក-សមាជិកាក្រុមប្រឹក្សាបានចូលរួមកិច្ចប្រជុំក្រុមការងារធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខ-ន្តិកៈមេធាវី ក្រោមអធិបតីភាពឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងជាប្រធានក្រុមការងាររៀបចំការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និង ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

កិច្ចប្រជុំនោះក៏មានការចូលរួមពីតំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងតំណាងមកពីក្រសួងពាណិជ្ជកម្មផងដែរ។

ជាលទ្ធផលក្រុមការងារបានសម្រេចឯកភាពតាមក្រុមការងារជំនាញដែលបានស្នើ។ ចំពោះចំណុចសេសសល់មួយចំនួនទៀត នឹងធ្វើការបញ្ជាក់ជាមួយអង្គការពាណិជ្ជកម្មពិភពលោកឡើងវិញ រួចដាក់ជូនអង្គប្រជុំពិនិត្យ និងសម្រេចជាចុងក្រោយនាពេលខាងមុខ។





## លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី ចូលរួមប្រជុំពិភាក្សា និងផ្តល់ធាតុចូលលើកម្រងសំណួរសម្រាប់វាយតម្លៃសមាជិកភាពកម្ពុជា

នៅថ្ងៃពុធ ទី០៧រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីកម្ពុជាបានចូលរួមប្រជុំពិភាក្សា និងផ្តល់ធាតុចូលលើកម្រងសំណួរសម្រាប់វាយតម្លៃសមាជិកភាពកម្ពុជាពី "វេទិការសកល ស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មាន ដើម្បីគោលបំណងពន្ធ(Global Forum)" ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៧-២៩ ខែមីនា ឆ្នាំ២០១៩ នៅអគ្គនាយកដ្ឋានពន្ធដារ។





## ១.២.ទំនាក់ទំនងអន្តរជាតិ

### ប្រធានគណៈមេធាវីនៃបណ្តាប្រទេសអាស៊ាន និងប៉ាស៊ីហ្វិក លើកសរសើរពីការដឹកនាំគណៈមេធាវីបច្ចុប្បន្ន

ប្រធានគណៈមេធាវីនៃបណ្តាប្រទេសអាស៊ាន រួមទាំងគណៈមេធាវី ចិន តៃវ៉ាន់ អូស្ត្រាលី និងញូវែលសេឡង់បានថ្លែងកោតសរសើរពីការដឹកនាំរបស់ប្រធានគណៈមេធាវីបច្ចុប្បន្ន ហើយបានលើកឡើងថា នឹងយកបទពិសោធន៍ល្អៗមួយចំនួនពីគណៈមេធាវីកម្ពុជាមកសិក្សាជាគំរូ។ ការថ្លែងកោតសរសើរនេះ គឺឆ្លើយតបនឹងការលើកឡើងរបស់លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី ក្នុងកិច្ចប្រជុំប្រធានគណៈមេធាវីនៃបណ្តាប្រទេសអាស៊ាន ចិន តៃវ៉ាន់ អូស្ត្រាលី និងញូវហ្សូសវែល ពិភាក្សាលើប្រធានបទស្តីពីបច្ចេកវិទ្យានីតិកម្ម នៅទីក្រុងសាយបើចាយ៉ា ប្រទេសម៉ាឡេស៊ី កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។ ក្នុងកិច្ចប្រជុំនោះ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា បានឡើងថ្លែងថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នបានធ្វើទំនើបកម្មការដឹកនាំគណៈមេធាវីតាមបច្ចេកវិទ្យាព័ត៌មានវិទ្យាទំនើប មានជាអាទិ៍៖

១.ការចាត់តាំង និងបញ្ជូនឯកសារការពារក្តីជូនជនក្រីក្រតាមកម្មវិធីតេឡេក្រាម ក្រោមកិច្ចសហការពីស្ថាប័នតុលាការ និងក្រសួងយុត្តិធម៌ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជា។

២. ការគ្រប់គ្រងសំណុំរឿងក្តីជនក្រីក្រតាមប្រព័ន្ធដាតាបេស (Database) តាមយន្តការប្រតិភូគណៈមេធាវីតាមបណ្តារាជធានីខេត្ត។

៣. ការបង្កើតអ៊ីម៉ែល សម្រាប់សហភាតាមេធាវីទាំងអស់ដើម្បីបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី។

៤.ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលគណៈមេធាវីតាមប្រព័ន្ធព័ត៌មានវិទ្យា។

៥. ការគ្រប់គ្រងវត្តមានមេធាវី និងការរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី តាមប្រព័ន្ធព័ត៌មានវិទ្យា នាពេលមហាសន្និបាតប្រចាំឆ្នាំ។

នៅក្នុងកិច្ចប្រជុំនោះ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី ក៏បានលើកឡើងផងដែរថា កិច្ចប្រជុំនេះមិនត្រឹមតែចែករំលែកបទពិសោធន៍ និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវីកម្ពុជា ជាមួយនឹងគណៈមេធាវីនៃបណ្តាប្រទេសអាស៊ាននិងអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងជួយរកទីផ្សារការងារឱ្យមេធាវីកម្ពុជាព្រមទាំងឱ្យមេធាវីកម្ពុជាមានកេរ្តិ៍ឈ្មោះនៅលើឆាកអន្តរជាតិថែមទៀតផង ដែលនេះជាជោគជ័យថ្មីមួយទៀតសម្រាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងអាណត្តិទី១២នេះ។



## លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អញ្ជើញចូលរួមបើកកម្មវិធី “Opening of the Legal Year 2019” នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

ឆ្លើយតបទៅនឹងការអញ្ជើញរបស់ប្រធានតុលាការយុត្តិធម៌ និងប្រធានគណៈមេធាវីម៉ាឡេស៊ី លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី បានអញ្ជើញចូលរួមបើកកម្មវិធី “Opening of the Legal Year 2019” នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី កាលពីថ្ងៃសុក្រ ៦កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩។

នៅក្នុងពិធីនោះមានការចូលរួមពីសំណាក់ចៅក្រម និងព្រះរាជអាជ្ញានៃប្រទេសម៉ាឡេស៊ី ព្រមទាំងប្រធាន និងសមាជិក សមាជិកាគណៈមេធាវីនៃបណ្ដាប្រទេសអាស៊ាន ចិន តៃវ៉ាន់ អូស្ត្រាលី និងញូវហ្សេឡង់ផងដែរ។ គួសបញ្ជាក់ថា ប្រទេសម៉ាឡេស៊ី តែងតែរៀបចំពិធីនេះជារៀងរាល់ឆ្នាំ សម្រាប់ក្រុមនីតិបុគ្គលដែលបម្រើការងារក្នុងវិស័យយុត្តិធម៌ ធ្វើការប្ដេជ្ញាចិត្តថ្មីដើម្បីបម្រើជាតិមាតុភូមិក្នុងឆ្នាំថ្មីឆ្នាំ២០១៩ ជាពិសេស ប្រមូលផ្ដុំនូវបទពិសោធន៍ និងសកម្មភាពអសកម្មមួយចំនួនក្នុងឆ្នាំចាស់ រួចធ្វើការកែតម្រូវ និងដាក់ចេញជាអនុសាសន៍សម្រាប់ឆ្នាំថ្មី។



## លោកកុយនាម អគ្គលេខាធិការរងគណៈមេធាវី ជួបជជែកពិភាក្សាការងារមួយអង្គការចាយការ (JICA)

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី កុយ នាម អគ្គលេខាធិការរងនៃគណៈមេធាវី បានអនុញ្ញាតឲ្យលោក Yokoyama Hiroshi ជាអនុប្រធានក្រុមការងារច្បាប់ និងយុត្តិធម៌ នៃនាយកដ្ឋានអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងគោលនយោបាយសាធារ-ណៈរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ដើម្បីស្វែងយល់ពីការងាររបស់គណៈមេធាវី ជាពិសេស លើជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។ នៅក្នុងកិច្ចប្រជុំនេះ លោកមេធាវី កុយ នាម បានលើកឡើងការវិវត្តន៍ថ្មីនៃកិច្ចខិតខំប្រឹងប្រែងរបស់គណៈមេធាវីដែលបានចូលរួមនៅក្នុងកិច្ចការ កំណែទម្រង់ក្នុងវិស័យយុត្តិធម៌តាមរយៈការផ្តល់នូវសេវាមេធាវីដោយមិនយកកម្រៃដល់ជនក្រីក្រ។ ភាគី JICA មានចំណាប់អារម្មណ៍លើការងារជំនួយផ្នែកច្បាប់នេះ ហើយនឹងយកចំណុចនៃកិច្ចពិភាក្សានេះដើម្បីទៅជជែកជាមួយថ្នាក់ដឹកនាំខ្លួនបន្តទៀត។



## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានអនុញ្ញាតឲ្យគណៈប្រតិភូមកពីសាកលវិទ្យាល័យ District of Columbia ដើម្បីសំដែងការគួរសម និងពិភាក្សាការងារ

នាព្រឹកថ្ងៃសៅរ៍ ១៤ កើត ខែបុស្ស ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានអនុញ្ញាតឲ្យគណៈប្រតិភូមកពីសាកលវិទ្យាល័យ **District of Columbia** ដឹកនាំដោយលោកស្រី Katerine S. Broderick ចូលជួបដើម្បីសំដែងការគួរសម និងផ្លាស់ប្តូរបទពិសោធន៍ការងារ។

គណៈប្រតិភូនេះមានសមាសភាពជាមេធាវីដែលបម្រើការងារនៅការិល័យមេធាវីឯកជន និងមេធាវីសម្រាប់បម្រើក្នុងវិស័យសាធារណៈ នៅក្នុងរដ្ឋផ្សេងៗនៃសហរដ្ឋអាមេរិក និងជាសាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យនានាផងដែរ។ នៅក្នុងកិច្ចពិភាក្សានេះ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានបង្ហាញអំពីសកម្មភាពការងារសម្រេចបានកន្លងមក និងតម្រូវការជាក់ស្តែងរបស់គណៈមេធាវី ជាពិសេស គម្រោងជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រដែលរាជរដ្ឋាបាលភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភថវិកាជាច្រើនសម្រាប់ផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រតាមរយៈគណៈមេធាវី។

គណៈប្រតិភូនៃសាកលវិទ្យាល័យ **District of Columbia** ក៏បានបង្ហាញពីបទសោធន៍ការងារល្អៗ និងការគៀងគរមូលនិធិសម្រាប់ជួយដល់ជនក្រីក្រនៅសហរដ្ឋអាមេរិកផងដែរ។ ថ្នាក់ដឹកនាំគណៈប្រតិភូបានបញ្ជាក់ថា នឹងយកបទពិសោធន៍ និងតម្រូវការជាក់ស្តែងរបស់គណៈមេធាវីកម្ពុជាដើម្បីជជែកពិភាក្សាជាមួយថ្នាក់ដឹកនាំខ្លួនដើម្បីបន្តកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរកាន់តែប្រសើរឡើងថែមទៀត។



## លោកមេធាវី សួន វិសាលបានជួបពិភាក្សាការងារជាមួយតំណាងគណៈមេធាវី នៃទីក្រុង Marseille សាធារណរដ្ឋបារាំង នៅទីស្នាក់ការគណៈមេធាវី

នារសៀលថ្ងៃចន្ទ ១រោច ខែបុស្ស ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានអនុញ្ញាតឲ្យលោកស្រីមេធាវី Delphine Gallin តំណាងឲ្យគណៈមេធាវី នៃទីក្រុង Marseille សាធារណរដ្ឋបារាំង ព្រមទាំងគណៈប្រតិភូអមដំណើរ ដើម្បីចូលជួបសម្តែង ការគួរសម និងពិភាក្សាអំពី កិច្ចសហប្រតិបត្តិការរវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងគណៈមេធាវីនៃទីក្រុង Marseille សាធារណរដ្ឋបារាំង។

នៅក្នុងកិច្ចពិភាក្សានេះ លោកប្រធានគណៈមេធាវីកម្ពុជាបានស្នើដល់តំណាង ប្រធានគណៈមេធាវី Marseille របស់សាធារណៈរដ្ឋបារាំងរួមមានផ្តល់ការគាំទ្រលើកម្មវិធីមូលនិធិជំនួយផ្នែកច្បាប់ ការពង្រឹងសមត្ថភាពដល់មេធាវីកម្ពុជាលើច្បាប់អន្តរជាតិ និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។ សមភាគីទាំងពីរបានឯកភាពក្នុងការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកតាមរយៈការបញ្ជូនគណៈប្រតិភូទៅទស្សនកិច្ចសិក្សាពីការអនុវត្តជាក់ស្តែងនៃគណៈមេធាវីកម្ពុ-ជា និងគណៈមេធាវីទីក្រុង Marseille សាធារណរដ្ឋបារាំង។

គណៈប្រតិភូបារាំងបានទទួលយកសំណើរបស់ប្រធានគណៈមេធាវីដើម្បីយកទៅពិចារណា និង ដាក់នៅក្នុងសេចក្តីព្រាងចុះអនុស្សារណៈយោគយល់រវាងគណៈមេធាវីកម្ពុជា និងគណៈមេធាវីបារាំងដើម្បីចុះហត្ថលេខានាពេលអនាគត។





## លោកមេធាវី កុយ នាម អគ្គលេខាធិការរងគណៈមេធាវីបានជួបពិភាក្សាការងារជាមួយលោកស្រី Claudia De La FUENTE

នៅថ្ងៃអង្គារ ២រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី កុយ នាម អគ្គលេខាធិការរងនៃគណៈមេធាវី បានពិភាក្សាការងារជាមួយលោកស្រី Claudia De La FUENTE ជាមន្ត្រីសិទ្ធិមនុស្ស និងប្រធានផ្នែកនីតិរដ្ឋ នៃការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

ដើម្បីជជែកពិភាក្សាការងារពាក់ព័ន្ធនឹងគម្រោងគាំពារការពង្រឹងសមត្ថភាពដល់មេធាវីនៅកម្ពុជា។ នៅក្នុងកិច្ចប្រជុំនេះលោកស្រីFUENTEបានលើកឡើងកិច្ចសហការជាមួយគណៈមេធាវីកន្លងមកដែលបានរៀបចំសិក្ខាសាលាស្ដីពីកិច្ចសន្ទនាផ្នែកច្បាប់។នៅក្នុងឆ្នាំ២០១៩ នេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស សុំការសហការជាមួយគណៈមេធាវីដើម្បីរៀបចំវគ្គសិក្ខាសាលាអំពីកិច្ចសន្ទនាផ្នែកច្បាប់នេះជាថ្មីម្ដង។

នៅក្នុងកិច្ចប្រជុំនេះផងដែរ លោកមេធាវី កុយ នាម បានស្វាគមន៍ និងអរគុណដល់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដែលបានជួយពង្រឹងសមត្ថភាពដល់មេធាវី

កម្ពុជាកន្លងមក។ គណៈមេធាវីនឹងនៅតែបន្តកិច្ចសហការជាមួយអង្គការដែលបានជួយពង្រឹងសមត្ថភាពដល់មេធាវីកម្ពុជា។





## អគ្គលេខាធិការគណៈមេធាវីទទួលជួបមេធាវីគ្មានព្រំដែនបារាំង

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៩ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា បានទទួលជួបប្រតិភូមកពីទីក្រុងទូលូ ប្រទេសបារាំង ដឹកនាំដោយលោកស្រីចៅក្រម Helene Diribarne ដែលជាប្រធានគម្រោង មេធាវីគ្មានព្រំដែនបារាំង។ លោកស្រីចៅក្រម Helene បានស្នើសុំការគាំទ្រពីគណៈមេធាវីលើ គម្រោងកសាងសមត្ថភាពមន្ត្រីជាពិសេសមន្ត្រីនៃមន្ទីរកិច្ចការនារីប្រចាំខេត្តបាត់ដំបង លើកិច្ចការការពារស្ត្រី និងកុមាររងគ្រោះដែលត្រូវការជំនួយមេធាវី។

ឆ្លើយតបនឹងសំណើនេះ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា បានស្វាគមន៍រាល់សកម្មភាព ជួយសង្គមរបស់មេធាវីគ្មានព្រំដែនបារាំងនឹងបានលើកទឹកចិត្តឱ្យបន្តសកម្មភាពជួយជនក្រីក្រពី ការរំលោភបំពាន ជាពិសេសលោកមេធាវី ព្រហ្ម វិចិត្រអក្ខរាបានស្នើឱ្យមេធាវីគ្មានព្រំដែនបារាំង សហការឱ្យបានជិតស្និតជាមួយនឹងប្រតិភូគណៈមេធាវីប្រចាំខេត្តបាត់ដំបង និងអាជ្ញាធរដែនដី។ ជំនួបរវាងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី និងក្រុមមេធាវីគ្មានព្រំដែនបារាំងបានបញ្ចប់នៅក្រោមបរិយាកាសយោគយល់និងស្និទ្ធស្នាល។



## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានទទួលជួបមន្ត្រីជាន់ខ្ពស់សេដ្ឋកិច្ចរបស់ធនាគារពិភពលោក និងសហការី ដើម្បីជួបពិភាក្សាការងារ

នៅព្រឹកថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានទទួលជួបលោក Miguel Eduardo S’anchez Mart’in ជាមន្ត្រីជាន់ខ្ពស់សេដ្ឋកិច្ចរបស់ធនាគារពិភពលោក និងសហ-ការី ដើម្បីជួបពិភាក្សាការងារ។

នៅក្នុងកិច្ចប្រជុំនេះលោកមេធាវី សួន វិសាល បានលើកយកសមិទ្ធផលសំខាន់ៗដែលសម្រេចបាននៅក្នុងអាណត្តិនៃការដឹកនាំរបស់លោក ដូចជា ការបង្កើននូវម៉ោងសិក្សា និងមុខវិជ្ជាជំនាញអនុវត្តជាក់ស្តែងសម្រាប់សុក្រឹតការមេធាវី ការបង្កើតប្រតិភូគណៈមេធាវីនៅតាមសាលាដំបូងរាជធានី/ខេត្ត ការធ្វើទំនើបកម្មនៃការគ្រប់គ្រងអង្គភាពគណៈមេធាវីតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាដើម លោកប្រធានគណៈមេធាវីក៏បានបង្ហាញពីតម្រូវការចាំបាច់របស់គណៈមេធាវីនាពេលបច្ចុប្បន្ន ជាពិសេស កង្វះនូវឱកាសសម្រាប់ជួយរឿងក្តីក្រីក្រ ការពង្រឹងសមត្ថភាពបន្ថែមដែលពាក់ព័ន្ធនឹងវិធានពាណិជ្ជកម្មអន្តរជាតិនិងបទដ្ឋានគតិយុត្តផ្សេងៗទៀត ជាដើម។ លោក Miguel Eduardo S’anchez Mart’in បានឆ្លើយតបថា លោកនឹងយកតម្រូវការរបស់គណៈមេធាវីទៅជជែក ពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់ខ្លួនបន្តទៀត។



## ២.ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា

### សិក្ខាសាលាស្តីពី ការចាត់ចែងរក្សាការពារ

នៅថ្ងៃពុធ ៨កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ចាប់ពីម៉ោង០៨: ០០ ព្រឹក ដល់ម៉ោង ១៧:០០ រសៀល គណៈមេធាវីបានសហការជាមួយសហព័ន្ធគណៈមេធាវីជប៉ុន (JFBA) និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ជប៉ុន (ICD)បានរៀបចំសិក្ខាសាលាក្រោមប្រធានបទស្តីពី“ការចាត់ចែងរក្សាការពារ” ក្រោមអធិបតីភាពរបស់ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី នៅទីស្នាក់ការរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងអង្គសិក្ខាសាលានេះ គណៈមេធាវីក៏បានធ្វើការផ្សាយបន្តផ្ទាល់ចេញពីអង្គសិក្ខាសាលាតាមរយៈបណ្តាញសង្គមហ្វេសប៊ុកជាផ្លូវការរបស់គណៈមេធាវីផងដែរ។




### ពិធីបើកវគ្គបណ្តុះបណ្តាលសុក្រឹតការវិជ្ជាជីវៈមេធាវី វគ្គទី ៧

នៅថ្ងៃសុក្រ ទី១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៨:៣០ព្រឹក មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីនៃគណៈមេធាវីបានរៀបចំវគ្គបណ្តុះបណ្តាលសុក្រឹតការវិជ្ជាជីវៈមេធាវីវគ្គទី៧ ជូនដល់សមាជិក-សមាជិកាមេធាវីដែលបាន

ចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២  នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីដែលបានប្រព្រឹត្តទៅនៅ ទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី និងឯកឧត្តម ជីវ សុងហាក់ ជាអតីតប្រធានគណៈមេធាវី ។






## សិក្ខាសាលាស្តីពី "ការអនុវត្តបែបកុមារមេត្រីក្នុងនីតិវិធីយុត្តិធម៌ដើម្បីការការពារជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ"

នៅថ្ងៃព្រហស្បតិ៍ ទី០៨រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានឡើងថ្លែងចំណាប់អារម្មណ៍ តំណាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គសិក្ខាសាលា ស្តីពី "ការអនុវត្តបែបកុមារមេត្រីក្នុងនីតិវិធីយុត្តិធម៌ដើម្បីការការពារជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ"។

## សិក្ខាសាលា ស្តីពី "ការអនុវត្តបែបកុមារមេត្រីក្នុងនីតិវិធីយុត្តិធម៌ដើម្បីការការពារជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ"

លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី បានថ្លែងថា អង្គសិក្ខាសាលានេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់មេធាវី និងអ្នកអនុវត្តច្បាប់ពាក់ព័ន្ធ ក្នុងការបង្កើនចំណេះដឹងពាក់ព័ន្ធនឹងការអនុវត្តវិធានព្រហ្មទណ្ឌលើ កុមារដែលប្រព្រឹត្តល្មើសនឹងច្បាប់ដោយអនុវត្តនូវយន្តការកុមារមេត្រី។

គួសបញ្ជាក់ថា សិក្ខាសាលានេះប្រព្រឹត្តធ្វើឡើងនៅសណ្ឋាគារសុខា រាជធានីភ្នំពេញ ក្រោមកិច្ចសហការរវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងមហាផ្ទៃ) និងអង្គការ APLE ដោយមានការចូលរួមពីមេធាវីខ្មែរ និងអន្តរជាតិ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងសាលាឧទ្ធរណ៍ និងអង្គការអន្តរជាតិនានា ព្រមទាំងដៃគូសហការផ្សេងៗ។



នាថ្ងៃអាទិត្យ ៥កើត ខែផល្គុន ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលពាណិជ្ជកម្មកោះពេជ្រ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំពិធីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិ៨ មីនា ខួបទី១០៨ នៅមជ្ឈមណ្ឌលពាណិជ្ជកម្មកោះពេជ្រ ក្រោមប្រធានបទ "លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស"

ក្រោមអធិបតីភាពរបស់លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងកិច្ចស្វាគមន៍នៃកម្មវិធីនេះ លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌បានលើកអំពីតួនាទីស្ត្រីនៅក្នុងវិស័យដឹកនាំជាតិ និងជម្រុញឲ្យស្ត្រីមានភាពក្លាហានក្នុងការប្រើសិទ្ធិរបស់ខ្លួន។ លោកជំទាវក៏បានអាននូវព្រះរាជសាររបស់សម្តេចព្រះមហាក្សត្រនរោត្តម មុនីនាថសីហនុ ផងដែរ។

នៅក្នុងមតិសំណេះសំណាលនៃកម្មវិធីនេះដែរ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានថ្លែងថា នៅក្នុងអាណត្តិនៃការដឹកនាំរបស់លោក លោកតែងតែរៀបចំពិធីទិវាអន្តរជាតិនារី ៨ មីនា នេះជារៀងរាល់ឆ្នាំ ដោយមិនប្រើថវិកាពីគណៈមេធាវីឡើយ គឺលោកប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងជំនួយឧបត្ថម្ភពីសមាជិក-សមាជិកក្រុមប្រឹក្សាគណៈមេធាវី ព្រមជំនួយឧបត្ថម្ភពីសំណាក់សហភាតាមេធាវីផងដែរ។ លោកប្រធានគណៈមេធាវីក៏បានថ្លែងអំណរគុណចំពោះកិច្ចគាំពារជាថវិកា និងសម្ភារៈពីសំណាក់សហភាតាមេធាវី និងស្ថាប័នជាតិជាច្រើនទៀតដែលបានជួយឧបត្ថម្ភសម្រាប់ការរៀបចំពិធីនេះ។

កម្មវិធីនេះប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយ និងភាពស្និទ្ធស្នាលក្រៃលែង ដោយមានការចូលរួមពីសំណាក់សមាជិក-សមាជិការគណៈមេធាវី រួមទាំងអតីតប្រធានគណៈមេធាវី លោក លោកស្រី នាងកញ្ញាជាចៅក្រម ព្រះរាជអាជ្ញា អង្គភាពប្រឆាំងអំពើពុករលួយ និងស្ថាប័នជាតិក៏បានអញ្ជើញចូលរួមកម្មវិធីយ៉ាងច្រើនកុះករផងដែរ។


គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
អបអរសាទរទិវាអន្តរជាតិនារី ៨ មីនា លើកទី១០៨
ក្រោមប្រធានបទ៖
"លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស"
លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី




គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
អបអរសាទរទិវាអន្តរជាតិនារី ៨ មីនា លើកទី១០៨
ក្រោមប្រធានបទ៖
“លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស”


គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
អបអរសាទរទិវាអន្តរជាតិនារី ៨ មីនា លើកទី១០៨
ក្រោមប្រធានបទ៖
“លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស”

# ៣.កិច្ចប្រជុំបុគ្គលិក

## កិច្ចប្រជុំបុគ្គលិកប្រចាំខែនិងលើកទិសដៅការងារប្រចាំខែថ្មី

កិច្ចប្រជុំបុគ្គលិកប្រចាំខែនិងលើកទិសដៅការងារប្រចាំខែថ្មី នៅថ្ងៃព្រហស្បតិ៍១២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រជុំខែមករា។





## ៤.កិច្ចប្រជុំគណៈកម្មការជំនាញ

### គណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិការគណៈកម្មការកិច្ចការការងារ នៃគណៈមេធាវី

នៅថ្ងៃសុក្រ ៦កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំកិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការកិច្ចការការងារលើកទី០៤ ក្រោមការដឹកនាំប្រជុំដោយ លោកស្រីមេធាវី អាន វីរៈ ប្រធានគណៈកម្មការ។

នៅក្នុងកិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការបានពិភាក្សាលើការបែងចែកសមាជិកគណៈកម្មការជាក្រុម ដើម្បីធ្វើការស្រាវជ្រាវលើប្រធានបទទាក់ទងនឹងវិស័យច្បាប់ការងារសម្រាប់កម្មវិធីផ្សព្វផ្សាយច្បាប់តាមរយៈ ទូរទស្សន៍ វិទ្យុ សិក្ខាសាលា និងព្រឹត្តិបត្រគណៈមេធាវី។




### កិច្ចប្រជុំគណៈកម្មការកិច្ចការងារប្រចាំខែកុម្ភៈ

នៅរសៀលថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំកិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការកិច្ចការការងារ ក្រោមការដឹកនាំប្រជុំដោយលោកស្រីមេធាវី អាន វីរៈ ប្រធានគណៈកម្មការ។

នៅក្នុងកិច្ចប្រជុំនោះបានសម្រេចធ្វើការបែងចែកសមាជិកគណៈកម្មការ ជាក្រុមតូចៗ និងកែសម្រួលសមាសភាពសមាជិកក្រុមឡើងវិញ។ កិច្ចប្រជុំក៏បានកំណត់អំពីប្រធានបទ

សម្រាប់សិក្ខាសាលាថ្នាក់ជាតិទាក់ទងនឹងវិស័យច្បាប់ការងារ ដែលនឹងប្រព្រឹត្តនៅក្នុងដើមខែមេសាខាងមុខនេះផងដែរ។ ចំពោះប្រធានបទសម្រាប់សិក្ខាសាលានេះ អង្គប្រជុំបានសម្រេចផដែត និងពិភាក្សាគ្នាលម្អិតទៀតនៅកិច្ចប្រជុំ លើកក្រោយ។




តំណាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងប្រតិភូមេធាវីប្រចាំខេត្តបាត់ដំបង បានធ្វើដំណើរទៅចូលរួមពិធីបុណ្យសពរបស់ លោកមេធាវី យ៉ាំ យ៉េត

កាលពីថ្ងៃអាទិត្យ ១២ កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៨ តំណាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងប្រតិភូមេធាវីប្រចាំខេត្តបាត់ដំបង បានធ្វើដំណើរទៅចូលរួមពិធីបុណ្យសពរបស់ លោកមេធាវី យ៉ាំ យ៉េត។

បានទទួលមរណភាព កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៩:០០ នាទីព្រឹក ក្នុងជន្មាយុ៧២ឆ្នាំ ដោយគ្រោះថ្នាក់ចរាចរណ៍នៅស្រុកបរិបូរណ៍ខេត្តកំពង់ឆ្នាំង។ ពិធីបុណ្យសពលោកមេធាវី យ៉ាំ យ៉េត ប្រារព្ធធ្វើនៅគេហដ្ឋាននៃសព នៅភូមិរការ សង្កាត់អូរ ម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី កែ ប៊ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៣-លោក ឃឹម ច័ន្ទធឿន | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៥-លោក ខន សុខេង | ប្រធានការិ.ស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ |
| ៦-លោក ថា ប៊ុនថៃ | ប្រធានការិ.ព័ត៌មានវិទ្យា |
| ៧- លោក ស្រេង សីហាប៊ុននុត | ជំនួយការ ការិ.ព័ត៌មានវិទ្យា |
| ៨- កញ្ញា តាន់ ចរណី | បណ្ណារក្ស |
| ៩-លោកមេធាវី ហួត សុវណ្ណ | បុគ្គលិកស្ម័គ្រចិត្ត |
| ១០-លោក ជុំ ប៉ុនណារាយ | បុគ្គលិកហាត់ការ |
| ១១-លោក នួន វ៉ា | បុគ្គលិកហាត់ការ |

# បោះពុម្ពផ្សាយដោយ

## សម្តេចវិបុលសេនាភក្តី សាយ ឈុំ

## លោកមេធាវី សារិន ដេណូរ៉ា

## DFDL

## គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា